# ព្រឹទ្ធសភា

# SENATE MAGAZINE

ទស្សនាវដ្តីខែតុលា

នីតិកាលទី៥








លេខ ៣០០ ឆ្នាំទី២៥ ព.ស.២៥៦៩ គ.ស.២០២៥
Issue 300 Volume 25 BC 2569 BE 2025

# មាតិកា







## សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា ( ១-៣៦ )


- សម្តេចតេជោ **ហ៊ុន សែន** អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីសម្រេចលើរបៀបវារៈចំនួន៣ ..................... ១
- ព្រឹទ្ធសភាបន្តពង្រឹងសកម្មភាពការទូតសភា កាន់តែសកម្មឡើង ..................... ២
- សម្តេចតេជោ **ហ៊ុន សែន** អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីសម្រេចលើរបៀបវារៈចំនួន៦ ..................... ៥
- សម្តេចតេជោ **ហ៊ុន សែន** អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីសម្រេចលើរបៀបវារៈចំនួន៧ ..................... ៦
- ព្រឹទ្ធសភាឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ចំនួន៥..................... ៧
- សម្តេចតេជោ **ហ៊ុន សែន** អញ្ជើញចូលរួមពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៧៦ នៃថ្ងៃបង្កើតសាធារណរដ្ឋប្រជាមានិតចិន......... ១២
- សម្តេចតេជោ **ហ៊ុន សែន** អនុញ្ញាតឱ្យសមាជិកព្រឹទ្ធសភាម៉ាឡេស៊ី និងគណៈប្រតិភូសហព័ន្ធសភាសន្តិភាពពិភពលោក ចូលជួបសម្តែងការគួរសម..................... ១៤
- កម្ពុជានិងកុំមិនវែលដូមីនីក ត្រូវតែពង្រីកនូវចំណងមិត្តភាព តាមរយៈវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយគ្នា ឱ្យកាន់តែទូលំទូលាយបន្ថែមទៀត ..................... ១៦
- ភាពរីកចម្រើនរបស់កម្ពុជា មិនអាចកាត់ផ្តាច់ចេញពីតួនាទីរបស់ជប៉ុនបានឡើយ ..................... ១៨
- កម្ពុជាមិនត្រូវការឱ្យប្រទេសណាថ្កោលទោសប្រទេសណាទេ ប៉ុន្តែអ្វីដែលកម្ពុជាចង់បានគឺធ្វើយ៉ាងណាជំរុញឱ្យភាគីទាំងពីរគោរពបទឈប់បាញ់ឱ្យមានប្រសិទ្ធភាព..................... ២០
- ឯកឧត្តម **អ៊ុច បូររិទ្ធ** ដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ចុះជួបសំណេះសំណាលជាមួយមន្ត្រីរាជការ និងប្រជាពលរដ្ឋនៅស្រុកកោះសូទិន និងស្រុកស្រីសន្ធរ ខេត្តកំពង់ចាម..................... ២២
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អញ្ជើញចូលរួមសន្និសីទគ្រឿងបរិក្ខារសមុទ្រពិភពលោក នៅសាធារណរដ្ឋប្រជាមានិតចិន..................... ២៤
- កម្ពុជាគ្មានបំណងចង់មានទំនាស់ជាមួយប្រទេសណាមួយឡើយ..................... ២៦
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អញ្ជើញជួបពិភាក្សាការងារជាមួយអគ្គលេខាធិការ IPU នៅប្រទេសស្វីស ..................... ២៨
- មិត្តភាពកម្ពុជា-ជប៉ុន គឺពោរពេញដោយការគោរពស្រឡាញ់ និងការពារគ្នាទៅវិញទៅមក ..................... ២៩
- កម្ពុជានិងហ្វីលីពីន នឹងបន្តរីកចម្រើនជាមួយគ្នានៅលើវិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម និងបច្ចេកវិទ្យា ..................... ៣០
- ឯកឧត្តមបណ្ឌិត **ឆន់ ទឡ្ហនា** គាំទ្រយ៉ាងពេញទំហឹងសម្រាប់ដៃគូសហការរវាងវិស័យឯកជន និងគ្រឹះស្ថានសាធារណៈរដ្ឋបាល......... ៣១
- សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ..................... ៣២


## សកម្មភាពគណៈកម្មការនានារបស់ព្រឹទ្ធសភា ( ៣៧-៦៨ )


- គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា អញ្ជើញទស្សនកិច្ចឈ្វេងយល់ក្រុមហ៊ុន អេអាយ ហ្វាម ..................... ៣៧
- គណៈប្រតិភូព្រឹទ្ធសភា អញ្ជើញសួរសុខទុក្ខនិងនាំយកអំណោយគ្រឿងឧបភោគ បរិភោគ សម្ភារៈប្រើប្រាស់ ជូនវីរកងទ័ពជួរមុខនៅបញ្ជាការដ្ឋានកងពលតូចអន្តរាគមន៍លេខ៩ និងកងវរសេនាតូចលេខ៣៩៤..................... ៣៩
- គណៈកម្មការទី៩ព្រឹទ្ធសភា អញ្ជើញទស្សនកិច្ចឈ្វេងយល់អំពីវិស័យរបស់ខ្លួន នៅអាកាសយានដ្ឋានអន្តរជាតិតេជោ និងវិទ្យាស្ថានបណ្តុះបណ្តាលចំនួន៤..................... ៤១
- គណៈកម្មការទី១០ព្រឹទ្ធសភា ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយសមាគមពេទ្យព្យាបាលដោយចលនាកម្ពុជា ......... ៤៣
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ សហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តប្រទេសបារាំង ចុះពិនិត្យព្យាបាលជំងឺទូទៅដោយមិនយកកម្រៃជូនប្រជាពលរដ្ឋនៅខណ្ឌឫស្សីកែវ និងខណ្ឌពោធិ៍សែនជ័យ ..................... ៤៥
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ អញ្ជើញជួបសំណេះសំណាលជាមួយអាជ្ញាធរស្រុកឈូក ខេត្តកំពត..................... ៤៧
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ អញ្ជើញឈ្វេងយល់អំពីសភាពការណ៍ថ្មីៗ នៅខេត្តពោធិ៍សាត់ និងខេត្តកោះកុង..................... ៤៩
- កិច្ចប្រជុំគណៈកម្មការទាំង១០ ក្រុមភូមិភាគ និងក្រុមនានានៃព្រឹទ្ធសភា..................... ៥១
- ការទទួលពាក្យបណ្តឹង..................... ៥៥
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស ..................... ៥៥
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨..................... ៥៦
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ ..................... ៦៤


## សកម្មភាពអគ្គលេខាធិការដ្ឋាន ( ៦៩-៧៣ )


- ការប្រមាថមកលើ**សម្តេចតេជោ** និងឥស្សរជនកម្ពុជា គឺជាការប្រមាថយ៉ាងធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ តម្លៃ សីលធម៌ និងការគោរពគ្នាទៅវិញទៅមករវាងប្រជាជាតិនិងប្រជាជាតិ..................... ៦៩
- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ ..................... ៧១



**អ្នកគ្រប់គ្រងទូទៅ**
ឯកឧត្តម ឡាយ សំកុល

**អ្នកសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**
ឯកឧត្តម ខេង សិទ្ធិគុណ
ឯកឧត្តម ជាម សុផលមករា
ឯកឧត្តម ជួន ណា
លោក ជួន សុខជី
លោក ទេព មករា
លោក កុក វ៉ៃ
លោក សុង សុខភារ័ត្ន

**អ្នកគ្រប់គ្រងផ្ទាល់**
លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**
ការិយាល័យព័ត៌មាន

**ការីកុំព្យូទ័រ**
លោក ជុំ ច័ន្ទរតនា
លោក ធុន គីមជី
លោកស្រី សុខ សុជាតា


**គ្របមុខ**

- *សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងឯកឧត្តមបណ្ឌិត Roosevelt Skerrit នាយករដ្ឋមន្ត្រីកុំមិនវែលដូមីនីក។*
- *ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ឡើងថ្លែងសុន្ទរកថាក្នុងមហាសន្និបាតលើកទី១៥១ នៃសហភាពអន្តរសភា (IPU) នៅប្រទេសស្វីស។*
- *ឯកឧត្តមបណ្ឌិត **ឆន់ ទឡ្ហនា** អនុប្រធានទី២ព្រឹទ្ធសភា អញ្ជើញថតរូបអនុស្សាវរីយ៍ជាមួយឯកឧត្តម UENO Atsushi ឯកអគ្គរាជទូតជប៉ុន នៅស្ថានទូតជប៉ុន រាជធានីភ្នំពេញ៕*

# សម្តេចតេជោ ហ៊ុន សែន អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីសម្រេចលើរបៀបវារៈចំនួន៣



*សម្តេចតេជោ ហ៊ុន សែន ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*



*ទិដ្ឋភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី១៦ ខែតុលា ឆ្នាំ២០២៥ គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ បានរៀបចំកិច្ចប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៣ មានដូចខាងក្រោម៖

**១-ពិនិត្យនិងសម្រេចលើបាយការណ៍សង្ខេបស្តីពី សកម្មភាពនិងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៣និងលើកទី៤ នីតិកាលទី៥។**

**២-កំណត់កាលបរិច្ឆេទ របៀបវារៈនិងសមាសភាពលេខាធិការសម័យប្រជុំលើកទី៤ ព្រឹទ្ធសភានីតិកាលទី៥។**

**៣-ផ្សេងៗ។**

បន្ទាប់ពីបានពិនិត្យនិងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានកំណត់យកថ្ងៃព្រហស្បតិ៍ ទី១៦ ខែតុលា ឆ្នាំ២០២៥ ដើម្បីបើកសម័យប្រជុំលើកទី៤ ព្រឹទ្ធសភានីតិកាលទី៥ ដើម្បីស្តាប់របាយការណ៍សង្ខេបរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពី សកម្មភាពនិងលទ្ធផលការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី៣និងលើកទី៤ នីតិកាលទី៥៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# ព្រឹទ្ធសភាបន្តពង្រឹងសកម្មភាពការទូតសភា កាន់តែសកម្មឡើង




*សម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា និងឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អនុប្រធានទី២ព្រឹទ្ធសភា*



*សម្តេចតេជោ ហ៊ុន សែន មានប្រសាសន៍ក្នុងអង្គប្រជុំ*



*ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា ឡើងអានរបាយការណ៍*

អនុលោមតាមស្មារតីនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នាព្រឹកថ្ងៃព្រហស្បតិ៍ ទី១៦ ខែតុលា ឆ្នាំ២០២៥ នៅថ្ងៃដដែលនោះ ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានបើកសម័យប្រជុំលើកទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដែលមានវត្តមានសមាជិកព្រឹទ្ធសភាចូលរួមចំនួន៦០រូប ដោយមានរបៀបវារៈតែមួយគឺ ស្តាប់របាយការណ៍សង្ខេបរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ស្តីពីសកម្មភាពនិងលទ្ធផលការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី៣និងលើកទី៤ នីតិកាលទី៥។

ក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញឡើងអានរបាយការណ៍សង្ខេបរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ស្តីពីសកម្មភាពនិងលទ្ធផលការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី៣និងលើកទី៤ នីតិកាលទី៥ ថា ក្នុងអំឡុងពេលបីខែ នៃចន្លោះសម័យប្រជុំនេះ (៧ កក្កដា-៦តុលា ២០២៥) ថ្នាក់ដឹកនាំ គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ក្រុមសមាជិកាព្រឹទ្ធសភានិងសមាជិក សមាជិកាព្រឹទ្ធសភា បានខិតខំបំពេញការងារជាប្រក្រតីក្នុងព្រឹទ្ធសភានិងសកម្ម

ក្នុងការចុះប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋនិងអាជ្ញាធរដែនដីក្នុងភូមិភាគរបស់ខ្លួន ព្រមទាំងរួមចំណែកយ៉ាងសកម្ម ក្នុងការលើកកម្ពស់ស្មារតីរួមគ្នាជាធ្លុងមួយ សាមគ្គីភាព និងឯកភាពជាតិ តាមរយៈការជួយឧបត្ថម្ភគាំទ្រនិងលើកទឹកចិត្ត ដល់កងកម្លាំងវីរយុទ្ធជនការពារជាតិជួរមុខ និងជនភៀសសឹកនៅតាមបណ្តាខេត្តនៅព្រំដែន ដោយសម្រេចបានលទ្ធផល ផ្លែផ្កាជាគុណប្រយោជន៍ដល់ជាតិនិងប្រជាពលរដ្ឋ មានជាអាទិ៍៖

មុខងារនីតិកម្ម គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានបើកកិច្ចប្រជុំចំនួន៧លើកនិងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ ចំនួន៤លើក ដើម្បីពិនិត្យហើយឱ្យយោបល់លើសេចក្តីស្នើច្បាប់ចំនួន១ សេចក្តីព្រាងច្បាប់ចំនួន៣ និងបោះឆ្នោតជ្រើស តាំងសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយតំណាងឱ្យព្រឹទ្ធសភាចំនួន១រូប។

ក្រៅពីបំពេញការងារលើមុខងារនីតិកម្ម គណៈកម្មការនានារបស់ព្រឹទ្ធសភាបានយកចិត្តទុកដាក់បំពេញការងារ យ៉ាងសកម្មដោយបានជួបពិភាក្សាការងារជាមួយក្រសួង ស្ថាប័ននានា និងការចុះតាមបណ្តាខេត្ត រាជធានី ចំនួន៣០ លើក ដើម្បីតាមដានវឌ្ឍនភាពនៃការអនុវត្តច្បាប់ និងគោលនយោបាយនានា ស្របតាមកម្មវិធីនយោបាយរបស់ រាជរដ្ឋាភិបាល។

ក្នុងការអនុវត្តមុខងារតំណាង ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ បានរៀបចំពិធីសំណេះសំណាលចំនួន ៣២លើក មានអ្នកចូលរួមសរុបចំនួន៦.៣៥៣នាក់ ដើម្បីតាមដានវឌ្ឍនភាពការងារ បញ្ហាប្រឈម សំណូមពរ និងតាមដាន ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន គោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព និងការផ្សព្វផ្សាយ អំពីសកម្មភាពឈ្លានពានរបស់ថៃ។ ជាមួយគ្នានេះ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ បានសហការជាមួយ អង្គការសង្គ្រោះវេជ្ជសាស្ត្រអន្តរជាតិ (IMR) ប្រចាំនៅកម្ពុជានិងសម្ព័ន្ធក្រុមគ្រូពេទ្យសហភាពសហព័ន្ធយុវជនកម្ពុជា ដើម្បីចុះទៅពិនិត្យព្យាបាលជំងឺដោយឥតគិតថ្លៃជូនប្រជាពលរដ្ឋចំនួន៤១០នាក់ នៅខណ្ឌកំបូលនិងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ជួសជុលអគារសិក្សា១ខ្នង មាន៥បន្ទប់ នៅសាលាបឋមសិក្សាឫទ្ធីសែនជ័យ ឃុំអូរស្វាយ ស្រុកបុរីអូរ ស្វាយសែនជ័យ ខេត្តស្ទឹងត្រែង និងចុះទៅប្រាស្រ័យទាក់ទង គោរពវិញ្ញាណក្ខន្ធ សួរសុខទុក្ខនិងចែកអំណោយជូន ក្រុមគ្រួសារយុទ្ធជនពលី និងពិការ ក្នុងបុព្វហេតុជាតិមាតុភូមិ ជនភៀសសឹក ពលករខ្មែរវិលត្រឡប់មកពីប្រទេសថៃ ប្រជាពលរដ្ឋ និងអាជ្ញាធរដែនដីក្នុងភូមិភាគរបស់ខ្លួន ព្រមទាំងចូលរួមក្នុងកម្មវិធីនានា នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងបានជួយអន្តរាគមន៍ទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីដោះស្រាយសំណូមពរនិងសំណើផ្សេងៗជូនប្រជាពលរដ្ឋសរុប ចំនួន៤២៥លើក។

ទន្ទឹមនឹងនេះ ក្រុមសមាជិកាព្រឹទ្ធសភាបានជួបប្រជុំជាមួយថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន និងអង្គភាពពាក់ព័ន្ធ ដើម្បីស្តាប់របាយការណ៍វឌ្ឍនភាពនិងឈ្វេងយល់អំពីតម្រូវការ បញ្ហាប្រឈមរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ជាស្ត្រី នៅតាមបណ្តាខេត្តទាំង៥ ក្នុងភូមិភាគទី៧ និងចុះសំណេះសំណាល សួរសុខទុក្ខ និងចែកចង្ក្រាន សន្សំសំចៃថាមពលនិងផ្តល់អំណោយជូនប្រជាពលរដ្ឋ គ្រួសារយុទ្ធជនពលី ពិការ ប្រជាជនភៀសសឹក ចាស់ជរា ស្ត្រី និងកុមារ នៅតាមមូលដ្ឋានចំនួន១២លើកនិងចូលរួមកម្មវិធីផ្សេងៗចំនួន៣៧លើក។

ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន២០បណ្តឹង និងបានបញ្ជូនទៅក្រសួង ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ និងក្រុម មេធាវីស្ម័គ្រចិត្តសម្តេចតេជោសែនចំនួន១២បណ្តឹងដើម្បីមុខការ តម្កល់ទុកមិនចាត់ការចំនួន១បណ្តឹង កំពុងពិនិត្យសិក្សា ចំនួន៩បណ្តឹង ទទួលលិខិតឆ្លើយតបការដោះស្រាយពីស្ថាប័នពាក់ព័ន្ធចំនួន៦បណ្តឹង ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹង ចំនួន២០បណ្តឹង រម្លើកនិងជំរុញការដោះស្រាយចំនួន៧បណ្តឹងនិងទទួលឯកសារពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមក គណៈកម្មការនានារបស់ព្រឹទ្ធសភាចំនួន៣៣បណ្តឹង។

ដោយឡែកក្នុងមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ ព្រឹទ្ធសភានីតិកាលទី៥ ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប៉ិនប្រសប់ និងប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា សកម្មភាព





*ទិដ្ឋភាពក្នុងសម័យប្រជុំលើកទី៤ ព្រឹទ្ធសភា នីតិកាលទី៥*

ការទូតសភាត្រូវបានបន្តពង្រីកកាន់តែសកម្មឡើង ដើម្បីរួមចំណែកដល់រាជរដ្ឋាភិបាល ក្នុងកិច្ចខិតខំពង្រឹងការងារការទូត ដើម្បីសន្តិភាព ស្ថិរភាព និងវិបុលភាពយូរអង្វែងរបស់កម្ពុជា តំបន់ និងពិភពលោក ក្នុងពេលដែលសភាពការណ៍តំបន់ និងពិភពលោកកំពុងមានភាពច្របូកច្របល់ខ្លាំងនិងហានិភ័យខ្ពស់ ដែលកើតចេញពីការបន្តប្រកួតប្រជែងយុទ្ធសាស្ត្រ-ភូមិសាស្ត្ររបស់ប្រទេសមហាអំណាច ភាពតានតឹងនៃជម្លោះ ការរីកសាយនៃសង្គ្រាម ក្នុងតំបន់មួយចំនួននៅលើពិភពលោក និងជម្លោះព្រំដែនកម្ពុជា-ថៃ ដែលបង្កដោយភាគីថៃ។

ក្នុងរយៈពេល៣ខែនៃចន្លោះសម័យប្រជុំនេះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ក្នុងនាមជាប្រមុខរដ្ឋស្តីទី និងជាប្រធានព្រឹទ្ធសភា បានទទួលជួបសវនាការ និងពិភាក្សាការងារជាមួយភ្ញៀវអន្តរជាតិ ឯកអគ្គរាជទូត/រដ្ឋទូតនិងស្ថាប័ននានា ចំនួន២៤លើក ព្រមទាំងអញ្ជើញបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋសង្គមនិយមវៀតណាម។

នៅចំពោះមុខភាពគឃ្លើននៃការឈ្លានពានរបស់ថៃទាំងកំរោលមកលើបូរណភាពទឹកដីកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ** បានបង្ហាញឫសគល់និងស្ថានភាពពិតនៃជម្លោះព្រំដែន ការព្យាយាមអត់ធ្មត់ និងការប្រកាន់គោលជំហររបស់កម្ពុជា ក្នុងការដោះស្រាយជម្លោះដោយសន្តិវិធី ដោយអនុលោមតាមច្បាប់អន្តរជាតិ និងបានស្នើឱ្យភាគីមិត្ត ជួយអន្តរាគមន៍ទប់ស្កាត់ការពង្រីកជម្លោះ គោរព និងអនុវត្តនូវបទឈប់បាញ់ដែលបានឯកភាពព្រមព្រៀងគ្នា ដើម្បីអាចវិលទៅរកប្រក្រតីភាពនៃទំនាក់ទំនងឡើងវិញ។

ព្រមជាមួយគ្នានេះ ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បានជួបពិភាក្សាការងារជាមួយភ្ញៀវជាតិ និងអន្តរជាតិ ក្នុងគោលបំណងពង្រឹងវិស័យការទូតសភា ពង្រីកចំណងមិត្តភាព និងសហប្រតិបត្តិការលើគ្រប់វិស័យ ក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី ព្រមទាំងចូលរួមពិធីផ្លូវការផ្សេងៗ សរុបចំនួន៤៥លើក និងបានអញ្ជើញចូលរួមដោយផ្ទាល់និងតាមប្រព័ន្ធនិម្មិតក្នុងកិច្ចប្រជុំនិងវេទិកានានា ក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី ចំនួន២៨លើក។

ក្នុងឱកាសនេះផងដែរ ព្រឹទ្ធសភាសូមសម្តែងនូវការដឹងគុណជូនវីរកងទ័ពជួរមុខដ៏អង់អាចក្លាហានទាំងអស់ ដែលបានខិតខំតស៊ូការពារបូរណភាពទឹកដីជូនជាតិ មាតុភូមិ និងប្រជាពលរដ្ឋ និងសូមថ្លែងនូវការគោរព និងកោតសរសើរយ៉ាងជ្រាលជ្រៅចំពោះវីរភាពដឹកនាំប្រកបដោយភាពវាងវៃនិងមនសិការស្នេហាជាតិដ៏ស្មោះសរខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចមហាបវរធិបតី** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចអគ្គមហាសេនាបតីតេជោ** ប្រធានព្រឹទ្ធសភានិងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ដែលមានភាពប៉ិនប្រសប់ក្នុងការដឹកនាំ គ្រប់គ្រងសភាពការណ៍ របស់ប្រទេសជាតិ និងតែងតែស្ថិតនៅរួមសុខរួមទុក្ខជាមួយប្រជាពលរដ្ឋគ្រប់កាលៈទេសៈទាំងអស់៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# សម្តេចតេជោ ហ៊ុន សែន អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីសម្រេចលើរបៀបវារៈចំនួន៦



សម្តេចតេជោ ហ៊ុន សែន ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

នាព្រឹកថ្ងៃអង្គារ ទី២១ ខែតុលា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៦ មានដូចខាងក្រោម៖

**១-ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ក្របខ័ណ្ឌបទប្បញ្ញត្តិសុវត្ថិភាពម្ហូបអាហារអាស៊ាន។**

**២-ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងអាស៊ានស្តីពីបម្លាស់ទីរូបវន្តបុគ្គល។**

**៣-ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទីមួយ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន។**

**៤-ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទីពីរ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់។**

**៥-ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញា ស្តីពីការបង្កើតអង្គការអន្តរជាតិសម្រាប់សន្ទានកម្ម។**

**៦-ផ្សេងៗ។**

បន្ទាប់ពីបានពិនិត្យនិងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានសម្រេចបញ្ជូនសេចក្តីព្រាងច្បាប់ទាំង៥ខាងលើ ទៅឱ្យគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន ដោយសហការជាមួយគណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ប្រៃសណីយ៍ទូរគមនាគមន៍ ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៃព្រឹទ្ធសភា ដើម្បីពិនិត្យសិក្សា និងផ្តល់យោបល់៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



ទិដ្ឋភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

# សម្តេចតេជោ ហ៊ុន សែន អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីសម្រេចលើរបៀបវារៈចំនួន៧






*ទិដ្ឋភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

នាព្រឹកថ្ងៃសុក្រទី២៤ ខែតុលា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៧ មានដូចខាងក្រោម៖

១-ពិនិត្យនិងសម្រេចលើសំណើរបស់គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន នៃព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ក្របខ័ណ្ឌបទប្បញ្ញត្តិសុវត្ថិភាពម្ហូបអាហារអាស៊ាន ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៤ ព្រឹទ្ធសភា នីតិកាលទី៥។

២-ពិនិត្យនិងសម្រេចលើសំណើរបស់គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន នៃព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងអាស៊ានស្តីពីបម្លាស់ទីរូបវន្តបុគ្គល ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៤ ព្រឹទ្ធសភា នីតិកាលទី៥។

៣-ពិនិត្យនិងសម្រេចលើសំណើរបស់គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន នៃព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទីមួយ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៤ ព្រឹទ្ធសភា នីតិកាលទី៥។

៤-ពិនិត្យនិងសម្រេចលើសំណើរបស់គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន នៃព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទីពីរ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៤ ព្រឹទ្ធសភា នីតិកាលទី៥។

៥-ពិនិត្យនិងសម្រេចលើសំណើរបស់គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន នៃព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពី ការបង្កើតអង្គការអន្តរជាតិសម្រាប់សន្ទានកម្ម ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៤ ព្រឹទ្ធសភា នីតិកាលទី៥។

៦-កំណត់កាលបរិច្ឆេទនិងរបៀបវារៈបន្តសម័យប្រជុំលើកទី៤ ព្រឹទ្ធសភា នីតិកាលទី៥។

៧-ផ្សេងៗ។

បន្ទាប់ពីបានពិនិត្យ និងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានកំណត់យកថ្ងៃដដែល វេលាម៉ោង ៩:០០នាទី បន្តសម័យប្រជុំលើកទី៤ ព្រឹទ្ធសភា នីតិកាលទី៥ ដើម្បីពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន៥ ខាងលើនេះ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# ព្រឹទ្ធសភាឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ចំនួន៥




*សម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា និងឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អនុប្រធានទី២ព្រឹទ្ធសភា*

នាព្រឹកថ្ងៃសុក្រ ទី២៤ ខែតុលា ឆ្នាំ២០២៥ ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានបន្តសម័យប្រជុំលើកទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលមានវត្តមានសមាជិកព្រឹទ្ធសភាចូលរួមចំនួន៥៥រូប។

មុននឹងដំណើរការអង្គប្រជុំ **សម្តេចតេជោ** បានលើកឡើងថា កាលពីម្សិលមិញនេះ គឺជាថ្ងៃអបអរសាទរខួបលើកទី៣៤ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស។ **សម្តេច** បានរលឹកប្រវត្តិនៃការចរចារវាង**សម្តេច** និងសម្តេចព្រះ **នរោត្តម សីហនុ** ដែលបានចាប់ផ្តើមដំបូងបង្អស់ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៨៧ នៅ Fère-en-Tardenois នៅប្រទេសបារាំង ហៅថា «ជំនួប សីហនុ-ហ៊ុន សែន» និងកិច្ចចរចាជាច្រើនដង នៅទីកន្លែងផ្សេងៗគ្នា ពោរពេញដោយឧបសគ្គជាច្រើន ទម្រាំសម្រេចបានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដើម្បីបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា។ **សម្តេច** បានរំលឹកអំពីការរិះគន់លើការប្រើប្រាស់អង្គរក្សកូរ៉េខាងជើងការពារ សម្តេចព្រះ **នរោត្តម សីហនុ**។ **សម្តេចតេជោ** បានលើកឡើងអំពីព្រះរាជបន្ទូលរបស់ **ព្រះបរមរតនកោដ្ឋ** ដែលស្នើឱ្យសម្តេចការពារសុវត្ថិភាពរបស់ព្រះអង្គនៅក្នុងដំណាក់កាលនៃជំនួបចរចា។ **សម្តេចតេជោ** បានបញ្ជាក់ថា **សម្តេច**បានបដិសេធសំណើរបស់ថៃ ក្នុងការបញ្ជូនមួយកងវរសេនាតូចទៅការពារព្រះរាជសុវត្ថិភាពរបស់**ព្រះបរមរតនកោដ្ឋ** ដែលការណ៍នេះគឺប្រៀបដូចជា «ខាងកើតចេញខាងលិចចូល»។ **សម្តេច**បានបន្ថែមថា **សម្តេច**ជាអ្នកបានស្នើទៅ**ប្រធានាធិបតីកូរ៉េខាងជើង** ក្នុងការរៀបចំអង្គរក្សការពារសម្តេចព្រះ **នរោត្តម សីហនុ** នៅក្នុងអំឡុងពេលទស្សនកិច្ចមួយនៅទីក្រុងព្យុងយ៉ាង ហើយនាពេលនោះ **សម្តេច** និងសម្តេចព្រះ **នរោត្តម សីហនុ** ក៏បានក្លាយជា កូនធម៌ និងឪពុកធម៌។ **សម្តេចតេជោ**បានសង្កត់ធ្ងន់ថា **សម្តេច**គឺជាអ្នកទៅទីក្រុងប៉េកាំងដោយផ្ទាល់ ដើម្បីដង្ហែ**ព្រះបរមរតនកោដ្ឋ** និង**ហ្លួងម៉ែ** ចូលមកប្រទេសកម្ពុជា នៅខែវិច្ឆិកា ឆ្នាំ១៩៩១ ហើយរហូតមកដល់ពេលនេះ **សម្តេច**ក៏នៅតែបន្តការពារសុវត្ថិភាពនៃរាជវង្សសានុវង្ស និងភាពគង់វង្សនៃរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។

ទន្ទឹមនឹងនេះ **សម្តេចតេជោ** បានលើកឡើងថា មានអ្នកដែលចង់ឱ្យយកបញ្ហាព្រំដែនកម្ពុជា-ថៃ ប្តឹងទៅសហប្រធាននៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស និងចង់ឱ្យមានការកោះប្រជុំបន្ទាន់នៃប្រទេសហត្ថលេខី អំពីបញ្ហា



*សម្តេចតេជោ ហ៊ុន សែន មានប្រសាសន៍ក្នុងអង្គប្រជុំ*

ព្រំដែននេះ។ **សម្តេចតេជោ** បានអះអាងថា បញ្ហាព្រំដែនរវាងកម្ពុជា-ថៃ បានដើរហួសពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសហើយ ពីព្រោះរាជរដ្ឋាភិបាលកម្ពុជា បានយកបញ្ហានេះទៅកាន់តុលាការយុត្តិធម៌អន្តរជាតិ (ICJ) និងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ព្រមទាំងវេទិកាអន្តរជាតិដទៃទៀត។ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស មិនមានចែងពីការដោះស្រាយ ឬសម្របសម្រួលបញ្ហាព្រំដែនរវាងកម្ពុជា-ថៃឡើយ ហើយខ្លឹមសារសំខាន់ៗរបស់កិច្ចព្រមព្រៀងនេះ បានដាក់បញ្ចូលក្នុងរដ្ឋធម្មនុញ្ញរបស់កម្ពុជាផងដែរ។ **សម្តេចតេជោ** បានលើកឡើងថា តាមរយៈកិច្ចប្រជុំនាពេលចុងក្រោយនេះ បញ្ហាព្រំដែនកម្ពុជា-ថៃ បានឈានដល់ដំណាក់កាលស្រុះស្រួល ហើយនឹងឈានទៅការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពមួយ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ ខាងមុខនេះ។

បន្ទាប់មក អង្គប្រជុំបានដំណើរការដោយមានរបៀបវារៈចំនួន៥ ដូចខាងក្រោម៖

**របៀបវារៈទី១៖ពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីក្របខ័ណ្ឌបទប្បញ្ញត្តិសុវត្ថិភាពម្ហូបអាហារអាស៊ាន។**

សេចក្តីព្រាងច្បាប់នេះ រៀបចំឡើងដើម្បីបង្កើតឱ្យមានអភិក្រមរួមនិងសហប្រតិបត្តិការ ក្នុងក្របខ័ណ្ឌអាស៊ានដើម្បីធានាសុវត្ថិភាពម្ហូបអាហារនៅក្នុងខ្សែច្រវាក់ផលិតកម្ម ស្របតាមទស្សនវិស័យនៃផែនការលម្អិតនៃសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥ និងដើម្បីអនុវត្តគោលនយោបាយសុវត្ថិភាពម្ហូបអាហារអាស៊ាន (គ.ស.ម.អ.) និងក្របខ័ណ្ឌបទប្បញ្ញត្តិសុវត្ថិភាពម្ហូបអាហារអាស៊ាន ដែលបានអនុម័តនៅឆ្នាំ២០១៥ និងឆ្នាំ២០១៦ ដោយរដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកវិស័យកសិកម្មនិងរុក្ខាប្រមាញ់ រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាននិងកិច្ចប្រជុំរដ្ឋមន្ត្រីសុខាភិបាលអាស៊ាន។

សេចក្តីព្រាងច្បាប់នេះ នឹងផ្តល់អត្ថប្រយោជន៍ដល់កម្ពុជា និងបណ្តាសមាជិកអាស៊ាន រួមមាន៖ ១-ធានាការពារសុខភាពអ្នកប្រើប្រាស់ ២-សម្រួលការធ្វើពាណិជ្ជកម្ម ធ្វើឱ្យមានលំហូរម្ហូបអាហារមានសុវត្ថិភាពដោយសេរី នៅក្នុងរដ្ឋសមាជិក ៣-ពង្រឹងសមត្ថភាពសហគ្រាសធុនតូច និងមធ្យមរបស់កម្ពុជា ៤-កាត់បន្ថយការខាតបង់ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច ដែលកើតឡើងបណ្តាលមកពីម្ហូបអាហារគ្មានគុណភាពនិងសុវត្ថិភាព ៥-ជំរុញឱ្យមានការធ្វើពាណិជ្ជកម្មម្ហូបអាហារប្រកបដោយសមធម៌ និងលើកកម្ពស់ការប្រកួតប្រជែងដោយសុចរិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សេចក្តីព្រាងច្បាប់នេះ រៀបចំឡើងមាន៣មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមលើកដំបូងចំនួន១០៦សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៧។

**របៀបវារៈទី២៖ពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងអាស៊ានស្តីពី បម្លាស់ទីរូបវន្តបុគ្គល។**

សេចក្តីព្រាងច្បាប់នេះ រៀបចំឡើងដើម្បីធ្វើបច្ចុប្បន្នភាពលើតារាងសន្យាបម្លាស់ទីរូបវន្តបុគ្គល ក្រោមកិច្ចព្រមព្រៀងអាស៊ានស្តីពី បម្លាស់ទីរូបវន្តបុគ្គលរបស់ប្រទេសសមាជិកអាស៊ាននីមួយៗឱ្យមានលក្ខណៈនិងទម្រង់រួមគ្នា ដែលនឹងបង្កភាពងាយស្រួលក្នុងការស្វែងយល់ដោយសាធារណជនទូទៅនិងរួមចំណែកបង្ហាញអំពីការប្តេជ្ញាចិត្តរបស់អាស៊ាន ដើម្បីធ្វើការរួមគ្នាឆ្ពោះទៅរកការលុបបំបាត់ភាពរឹតត្បិតនានាទៅលើបម្លាស់ទីឆ្លងកាត់ព្រំដែនជាបណ្តោះអាសន្ន នៃរូបវន្តបុគ្គល

ពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មទំនិញ ពាណិជ្ជកម្មសេវាកម្ម និងការវិនិយោគ។

សេចក្តីព្រាងច្បាប់នេះ នឹងផ្តល់អត្ថប្រយោជន៍ដល់កម្ពុជា ដូចជា៖ ១-សម្រួលដល់បម្លាស់ទីនិងវំហូរនៃបុគ្គលជំនាញនិងអ្នកចូលមកទស្សនកិច្ចក្នុងគោលបំណងធ្វើពាណិជ្ជកម្មក្នុងចំណោមប្រទេសសមាជិកអាស៊ាន ដែលជាផ្នែកសំខាន់មួយរបស់ផែនការលម្អិតសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥ ក្នុងការសម្រេចបាននូវការធ្វើសមាហរណកម្មសេដ្ឋកិច្ចខ្ពស់ និងការផ្សារភ្ជាប់សេដ្ឋកិច្ចជាធ្លុងមួយ ២-ធ្វើឱ្យតារាងសន្យាបម្លាស់ទីរូបវន្តបុគ្គលកាន់តែមានលក្ខណៈសាមញ្ញនិងមានទម្រង់រួមដែលបង្កភាពងាយស្រួលដល់សាធារណជន ជាពិសេសធុរជនក្នុងការស្វែងយល់អំពីការសន្យារបស់ប្រទេសជាសមាជិកនីមួយៗ ដើម្បីអាចទាញផលប្រយោជន៍ពេញលេញ។

សេចក្តីព្រាងច្បាប់នេះ រៀបចំឡើងមាន៣មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមលើកដំបូងចំនួន១០៦សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៧។

**របៀបវារៈទី៣៖ពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទីមួយ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន។**

សេចក្តីព្រាងច្បាប់នេះ រៀបចំឡើងដើម្បីធ្វើវិសោធនកម្មជំពូកទី៣ស្តីពី វិធានដើមកំណើតទំនិញ ដោយផ្តោតសំខាន់លើបទប្បញ្ញត្តិពាក់ព័ន្ធវិធានជាក់លាក់សម្រាប់ផលិតផលនិងដាក់បញ្ចូលលទ្ធផលនៃការចរចាវិធានជាក់លាក់សម្រាប់ផលិតផលថ្មី ទៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន សំដៅអនុវត្តវិធានដើមកំណើតទំនិញប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈសម្រួលពាណិជ្ជកម្ម។

សេចក្តីព្រាងច្បាប់នេះ នឹងផ្តល់អត្ថប្រយោជន៍ដល់កម្ពុជា រួមមាន៖ ១-ចូលរួមចំណែកលើកកម្ពស់តម្លាភាពនិងប្រសិទ្ធភាព នៅក្នុងការអនុវត្តជំពូកស្តីពី វិធានដើមកំណើតទំនិញ ជាពិសេសវិធានជាក់លាក់សម្រាប់ផលិតផល សំដៅជំរុញការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង ២-បង្កលក្ខណៈកាន់តែងាយស្រួលដល់ពាណិជ្ជករក្នុងការស្វែងរកលក្ខខណ្ឌដើមកំណើតទំនិញសម្រាប់ផលិតផលរបស់ខ្លួន ជាពិសេសសហគ្រាសធុនតូចនិងមធ្យម ៣-ចូលរួមពង្រឹងនិងធ្វើឱ្យប្រសើរឡើងនូវកិច្ចសម្រួលពាណិជ្ជកម្មក្នុងតំបន់ សំដៅជានាវំហូរទំនិញដោយរលូននិងឆាប់រហ័សរវាងប្រទេសជាសមាជិក ដើម្បីឆ្លើយតបតាមតម្រូវការនិងការវិវត្តនៃសេដ្ឋកិច្ចតំបន់ និងសកល។

សេចក្តីព្រាងច្បាប់នេះ រៀបចំឡើងមាន៣មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមលើកដំបូងចំនួន១០៦សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៧។





*ទិដ្ឋភាពក្នុងសម័យប្រជុំលើកទី៤ព្រឹទ្ធសភា នីតិកាលទី៥*

**របៀបវារៈទី៤៖ពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទីពីរ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់។**

សេចក្តីព្រាងច្បាប់នេះ នឹងផ្តល់អត្ថប្រយោជន៍ដល់កម្ពុជា មានជាអាទិ៍៖ ១-ពង្រីកកាលានុវត្តភាពសេដ្ឋកិច្ច ដែលទទួលបានពីការធ្វើឱ្យកាន់តែស៊ីជម្រៅនូវសមាហរណកម្មទីផ្សារ ការពង្រឹងខ្សែច្រវាក់ផ្គត់ផ្គង់តំបន់ និងសាកល ការសម្រួលដល់ពាណិជ្ជកម្មនិងវិនិយោគ និងការធានាភាពប្រកួតប្រជែង ប្រកបដោយតម្លាភាពជាដើម ដែលអនុវត្តដោយគ្រប់បណ្តាភាគី ២-ទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសកាន់តែទូលំទូលាយ ដែលជាកត្តាវិជ្ជមានក្នុងការបង្កើតឱកាសការងារថ្មីៗនៅក្នុងប្រទេស បង្កើនចំណូលជាតិ និងរួមចំណែកដល់កំណើនផលិតផលជាតិសរុប តាមរយៈការកសាងទំនុកចិត្តទៅលើបរិយាកាសធុរកិច្ចនិងបទប្បញ្ញត្តិនិងការកសាងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ៣-បង្កើនថវិកាជាតិតាមរយៈចំណូលសារពើពន្ធ ការប្រមូលពន្ធអាករពីសកម្មភាពពាណិជ្ជកម្មនានានៅក្នុងប្រទេស ៤-ពង្រឹងសក្តានុពលកម្លាំងពលកម្មនិងសហគ្រិនភាពក្នុងស្រុក តាមរយៈឱកាសកាន់តែច្រើន ក្នុងការទទួលបានបទពិសោធ ការផ្ទេរចំណេះដឹងជំនាញ បច្ចេកវិទ្យា និងបំណិនអាជីវកម្ម ៥-ទទួលបាននូវជម្រើសទំនិញ និងសេវាកម្មកាន់តែច្រើនសម្រាប់អ្នកប្រើប្រាស់ប្រកបដោយតម្លៃសមរម្យ និងភាពប្រកួតប្រជែង។

សេចក្តីព្រាងច្បាប់នេះ រៀបចំឡើងមាន៣មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមលើកដំបូងចំនួន១០៦សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៧។

**របៀបវារៈទី៥៖ពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពី ការបង្កើតអង្គការអន្តរជាតិសម្រាប់សន្ទានកម្ម។**

សេចក្តីព្រាងច្បាប់នេះ រៀបចំឡើងដើម្បីលើកស្ទួយ និងសម្រួលការដោះស្រាយវិវាទអន្តរជាតិ ប្រកបដោយសន្តិវិធី និងបង្កើតទំនាក់ទំនងនិងសហប្រតិបត្តិការប្រកបដោយមិត្តភាពរវាងរដ្ឋនិងរដ្ឋ តាមរយៈសន្ទានកម្ម នៅក្រោមអង្គការអន្តរជាតិសម្រាប់សន្ទានកម្ម ដែលជាអង្គការអន្តរជាតិមួយមានបុគ្គលភាពគតិយុត្តអន្តរជាតិ និងមានសមត្ថភាពទទួលសិទ្ធិពេញលេញ។

សេចក្តីព្រាងច្បាប់នេះ នឹងផ្តល់អត្ថប្រយោជន៍ដល់កម្ពុជា៖ ១-គាំទ្រគោលនយោបាយនិងនិន្នាការរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការដោះស្រាយវិវាទអន្តរជាតិដោយសន្តិវិធីតាមរយៈយន្តការសន្ទានកម្ម សម្របសម្រួលដោយភាគីទីបី ២-ផ្តល់ភាពបត់បែន និងជម្រើសបន្ថែមដល់កម្ពុជាក្នុងការនាំវិវាទរបស់ខ្លួនទៅដោះស្រាយនៅក្រោមក្របខ័ណ្ឌអន្តរជាតិ ដោយហេតុថា ដំណើរការសន្ទានកម្មរបស់អង្គការអន្តរជាតិសម្រាប់សន្ទានកម្ម ត្រូវផ្តើមឡើងតាមការព្រមព្រៀងគ្នារវាងគូភាគីវិវាទមុន ឬក្រោយវិវាទកើតឡើង និងស្របតាមគោលការណ៍ស្ម័គ្រចិត្ត មិនលម្អៀង សុទ្ធចិត្ត ប្រសិទ្ធផល និងប្រសិទ្ធភាព នៃការចំណាយ ៣-ព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិចាត់តាំងតំណាងរបស់ខ្លួនចូលរួមជាសមាជិកក្រុមប្រឹក្សាភិបាល ដែលជាអង្គសម្រេចចិត្តរបស់អង្គការអន្តរជាតិសម្រាប់សន្ទានកម្ម ហើយដែលមានសិទ្ធិចូលរួមប្រជុំ បោះឆ្នោត និងចូលរួមការសម្រេចចិត្តនានារបស់អង្គការនេះស្របតាមបទប្បញ្ញត្តិរបស់អនុសញ្ញានេះ ៤-ជួយសម្រាលបន្ទុកនៅតាមសាលាជម្រះក្តីតុលាការ តាមរយៈការបង្វែរការដោះស្រាយវិវាទមួយចំនួនចេញពីតុលាការ ជាពិសេស វិវាទពាណិជ្ជកម្ម និងវិនិយោគ ៥-ផ្តល់ជម្រើសបន្ថែមសម្រាប់ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ៦-ផ្តល់នូវភាពប្រាកដប្រជាសម្រាប់ការដោះស្រាយវិវាទតាមសន្ទានកម្មក្នុងក្របខ័ណ្ឌអន្តរជាតិ ៧-ជួយសម្រួលដល់ការអនុវត្តកិច្ចព្រមព្រៀងសះជាដែល

សម្រេចបានតាមរយៈសន្ធានកម្ម ៨-ជំរុញឱ្យសន្ធានកម្មក្លាយទៅជាយន្តការដោះស្រាយវិវាទដ៏មានប្រសិទ្ធភាព ៩-ជួយបង្កើនភាពប្រកួតប្រជែងនិងផ្តល់នូវការទាក់ទាញដោយប្រយោលលើវិស័យពាណិជ្ជកម្ម និងវិនិយោគ តាមរយៈការផ្តល់យន្តការដោះស្រាយវិវាទដែលកំពុងពេញនិយម ១០-ទទួលបានការបណ្តុះបណ្តាល កសាងសមត្ថភាព ការចែករំលែកបទពិសោធ និងឧត្តមានុវត្តអន្តរជាតិ ពាក់ព័ន្ធនឹងការធ្វើសន្ធានកម្មអន្តរជាតិ។

សេចក្តីព្រាងច្បាប់នេះរៀបចំឡើងមាន៣មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមលើកដំបូងចំនួន១០៦សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៧។


*ឯកឧត្តមបណ្ឌិត ចែម វីឌ្យ៉ា ឡើងអានរបាយការណ៍*


*លោកជំទាវ ចម និម្មល ឡើងការពារសេចក្តីព្រាងច្បាប់*

ឯកឧត្តមបណ្ឌិត **ចែម វីឌ្យ៉ា** ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន នៃព្រឹទ្ធសភា បានអញ្ជើញឡើងរាយការណ៍អំពីលទ្ធផលនៃការពិនិត្យសិក្សាសេចក្តីព្រាងច្បាប់ទាំង៥នេះ និងការឡើងមានយោបល់ពិភាក្សារបស់សមាជិកព្រឹទ្ធសភាតាមរបៀបវារៈនីមួយៗ ព្រមទាំងមានការឆ្លើយបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភាពីសំណាក់លោកជំទាវ **ចម និម្មល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម តំណាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

អង្គប្រជុំព្រឹទ្ធសភា បានពិនិត្យហើយឱ្យយោបល់ឯកភាពទាំងស្រុងដោយឥតកែប្រែនិងចាត់ទុកជាការប្រញាប់លើសេចក្តីព្រាងច្បាប់ទាំង៥ខាងលើមានចំនួន៥៥សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន




*សមាជិក សមាជិកាព្រឹទ្ធសភាលើកដៃអនុម័តច្បាប់*

## សម្តេចតេជោ ហ៊ុន សែន អញ្ជើញចូលរួមពិធីអបអរសាទរ ខួបអនុស្សាវរីយ៍លើកទី៧៦ នៃថ្ងៃបង្កើតសាធារណរដ្ឋប្រជាមានិតចិន

នាល្ងាចថ្ងៃសុក្រ ទី២៦ ខែកញ្ញា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមក្នុងពិធីជប់លៀងអបអរសាទរខួបលើកទី៧៦ នៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិន ដែលរៀបចំដោយស្ថានទូត នៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសុខាភ្នំពេញ។



សម្តេចតេជោ ហ៊ុន សែន និងឯកឧត្តម វ៉ាង វិនពីន

នៅក្នុងឱកាសនោះ ឯកឧត្តម **វ៉ាង វិនពីន** ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា បានសម្តែងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជានិងភ្ញៀវកិត្តិយសទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងពិធីនាថ្ងៃនេះ និងសូមជូនពរចំពោះបងប្អូនជនរួមជាតិនិងបងប្អូនប្រជាពលរដ្ឋខ្មែរជាប់សែស្រឡាយចិនទាំងអស់ដែលកំពុងបម្រើការងារនិងរស់នៅក្នុងប្រទេសកម្ពុជា។ ឯកឧត្តមឯកអគ្គរដ្ឋទូតបានមានប្រសាសន៍ថា ឆ្នាំនេះគឺជាឆ្នាំសម្រាប់ដំណើរការអភិវឌ្ឍប្រជាជនចិននិងមនុស្សជាតិ ដើម្បីលើកកម្ពស់ប្រព័ន្ធអភិបាលកិច្ចសកលឱ្យកាន់តែល្អ ហើយរួមគ្នាឆ្ពោះទៅរកសហគមន៍ជោគវាសនារួម។ ជាពិសេសឆ្នាំនេះ ក៏ជាឆ្នាំដ៏សំខាន់មួយក្នុងប្រវត្តិសាស្ត្រទំនាក់ទំនងចិននិងកម្ពុជាផងដែរ។



ឯកឧត្តម វ៉ាង វិនពីន ឡើងមានប្រសាសន៍ស្វាគមន៍ក្នុងអង្គពិធី

**ឯកឧត្តមឯកអគ្គរដ្ឋទូត** បានរំលឹកថា ឆ្នាំនេះឯកឧត្តម **ស៊ី ជីនពីង** ប្រធានាធិបតីចិន បានអញ្ជើញបំពេញទស្សនកិច្ចផ្លូវរដ្ឋនៅកម្ពុជាសារជាថ្មី បន្ទាប់ពីរយៈពេល៩ឆ្នាំ ដោយបានលើកកម្ពស់ទំនាក់ទំនងទ្វេភាគីដល់កម្រិតថ្មីមួយទៀត តាមរយៈការកសាងសហគមន៍ជោគវាសនារួមចិន-កម្ពុជា គ្រប់រដូវកាលក្នុងយុគសម័យថ្មី។ ជាមួយគ្នានោះ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជានិងសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក៏បានយាងនិងអញ្ជើញបំពេញទស្សនកិច្ចទៅកាន់ប្រទេសចិន ជាបន្តបន្ទាប់ផងដែរ។

ក្នុងឱកាសដ៏ប្រពៃថ្លៃថ្លានោះ សម្តេចតេជោ **ហ៊ុន សែន** បានគូសបញ្ជាក់ថា ក្នុងរយៈពេល៧៦ឆ្នាំ ប្រទេសចិន

សម្រេចបាននូវសមិទ្ធផលយ៉ាងធំធេងលើគ្រប់វិស័យ និងបានជម្នះឧបសគ្គ ព្រមទាំងបញ្ហាប្រឈមនានាប្រកបដោយជោគជ័យ ក្នុងដំណើរការកសាងប្រទេស។ ប្រទេសចិនបានក្លាយជាមជ្ឈមណ្ឌលសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ ហិរញ្ញវត្ថុ ផលិតកម្ម ឧស្សាហកម្ម វិទ្យាសាស្ត្រ និងនវានុវត្តន៍របស់ពិភពលោក ដែលបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចរបស់តំបន់ និងពិភពលោក។ ទន្ទឹមនឹងនេះ សម្តេចតេជោ ក៏បានចូលរួមអបអរសាទរជាមួយមិត្តចិន ដែលសម្រេចបានការអភិវឌ្ឍប្រទេសយ៉ាងលឿនបំផុត ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តចិន ដែលមានឯកឧត្តមប្រធានាធិបតី **ស៊ី ជីនពីង** ជាស្នូល រួមមាន៖ ការសម្រេចបានគោលដៅ១០០ឆ្នាំទី១ នៅឆ្នាំ២០២១ កំណើនសេដ្ឋកិច្ច ៥% នៅឆ្នាំ២០២៤។ **សម្តេច**មានសុទិដ្ឋិនិយមថា មិត្តចិននឹងសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់នៅឆ្នាំ២០២៥នេះ និងគោលដៅ១០០ឆ្នាំទី២ នៅឆ្នាំ២០៤៩ ដើម្បីប្រែក្លាយទៅជាប្រទេសសង្គមនិយមដ៏ទំនើបរុងរឿង ខ្លាំងក្លា ប្រជាធិបតេយ្យ វប្បធម៌ជឿនលឿន និងសុខដុមរមនា។


*សម្តេចតេជោ ហ៊ុន សែន មានប្រសាសន៍ក្នុងអង្គពិធី*

**សម្តេចតេជោ** ក៏បានគូសបញ្ជាក់ថា ចាប់តាំងពីការបង្កើតទំនាក់ទំនងការទូតកម្ពុជា-ចិននៅក្នុងឆ្នាំ១៩៥៨ រហូតមកដល់ពេលបច្ចុប្បន្ន ទំនាក់ទំនងមិត្តភាពរវាងប្រទេសទាំងពីរ ត្រូវបានពូនជ្រុំដោយយកចិត្តទុកដាក់ពីសំណាក់ថ្នាក់ដឹកនាំជំនាន់ក្រោយ នៃប្រទេសទាំងពីរ និងកំពុងបន្តរីកចម្រើនកាន់តែរឹងមាំឥតឈប់ឈរ រហូតក្លាយទៅជាភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងជាមិត្តដែកថែប។ **សម្តេចតេជោ** បានបង្ហាញក្តីរីករាយក្រៃលែង ដោយឃើញប្រទេសទាំងពីរមានកិច្ចសហប្រតិបត្តិការជិតស្និទ្ធ និងប្រកបដោយផ្លែផ្កាលើគ្រប់វិស័យ ដែលឆ្លុះបញ្ចាំងអំពីសាមគ្គីភាពជាប្រពៃណី និងកិច្ចសហប្រតិបត្តិការឈ្នះឈ្នះ៕

ប្រភព៖ Telegram Channel សម្តេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន


*ទិដ្ឋភាពក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៧៦ នៃថ្ងៃបង្កើតសាធារណរដ្ឋប្រជាមានិតចិន*

# សម្តេចតេជោ ហ៊ុន សែន អនុញ្ញាតឱ្យសមាជិកព្រឹទ្ធសភាម៉ាឡេស៊ី និងគណៈប្រតិភូសហព័ន្ធសភាសន្តិភាពពិភពលោក ចូលជួបសម្តែងការគួរសម

នារសៀលថ្ងៃព្រហស្បតិ៍ ទី២ ខែតុលា ឆ្នាំ២០២៥សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យឯកឧត្តមបណ្ឌិត Datuk Wira Dr. Mohd Hatta Bin Md Ramli សមាជិកព្រឹទ្ធសភាម៉ាឡេស៊ី និងគណៈប្រតិភូសហព័ន្ធសភាសន្តិភាពពិភពលោក (PFWP) ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា។

**សម្តេចតេជោ** បានស្វាគមន៍និងចាត់ទុកវត្តមានរបស់ប្រតិភូមកកាន់កម្ពុជានៅពេលនេះ នឹងធ្វើឱ្យទំនាក់ទំនងរវាងសហព័ន្ធសភាសន្តិភាពពិភពលោក ជាមួយស្ថាប័ននីតិប្បញ្ញត្តិកម្ពុជា ព្រមទាំងពង្រឹងពង្រីកទំនាក់ទំនងរវាងប្រទេសទាំងពីរ កម្ពុជា-ម៉ាឡេស៊ី ឱ្យកាន់តែល្អប្រសើរថែមទៀត។



*ឯកឧត្តមបណ្ឌិត Datuk Wira Dr. Mohd Hatta Bin Md Ramli និងសម្តេចតេជោ ហ៊ុន សែន*

នៅក្នុងឱកាសនោះ ឯកឧត្តម Mohd Hatta បានសម្តែងនូវក្តីរីករាយដែលបានជួប**សម្តេចតេជោ** សារជាថ្មី និងបានសរសើរអំពីការដឹកនាំរបស់**សម្តេចតេជោ** នាពេលកន្លងទៅ ដែលបានធ្វើឱ្យប្រទេសកម្ពុជាមានការរីកចម្រើនជាបន្តបន្ទាប់។ ឯកឧត្តមនិងគណៈប្រតិភូ រីករាយនិងរង់ចាំស្តាប់នូវការចែករំលែកនូវបទពិសោធប្រកបដោយគតិបណ្ឌិតពី**សម្តេចតេជោ** ដែលមានបទពិសោធយ៉ាងច្រើន នៅក្នុងអាជីពជាអ្នកនយោបាយ និងជាអ្នកដឹកនាំកំពូល។

**សម្តេចតេជោ** បានចែករំលែកអំពីស្ថានភាពរបស់ប្រទេសកម្ពុជាកាលពីអតីតកាល ជាពិសេសការដឹកនាំកម្ពុជាចេញពីរបបប្រល័យពូជសាសន៍ប៉ុលពតនិងបានបញ្ចប់សង្គ្រាមទាំងស្រុងនៅឆ្នាំ១៩៩៨ ធ្វើឱ្យកម្ពុជាទទួលបាននូវសុខសន្តិភាពពេញផ្ទៃប្រទេស និងមានការអភិវឌ្ឍរីកចម្រើនជាបន្តបន្ទាប់រហូតដល់សព្វថ្ងៃនេះ។ បច្ចុប្បន្ន កម្ពុជាមានមេដឹកនាំថ្មីដែលជាអ្នកជំនាន់ក្រោយ កំពុងតែបន្តដឹកនាំប្រទេសយ៉ាងស្វាហាប់ និងដើរយ៉ាងលឿនក្នុងការដឹកនាំកម្ពុជាឱ្យមានការរីកចម្រើនទៅមុខ។

ក្នុងឱកាសនោះផងដែរ **សម្តេចតេជោ** ក៏បានចែករំលែកអំពីបញ្ហាប្រឈមនៅពេលបច្ចុប្បន្ន គឺបញ្ហាព្រំដែនកម្ពុជា-ថៃ។ **សម្តេច**បានពន្យល់អំពីរឿងរ៉ាវដែលបានកើតឡើង និងបញ្ហាប្រឈមនាពេលបច្ចុប្បន្ន ដែលជំហររបស់កម្ពុជា និងអ្វីដែលកម្ពុជាចង់បាន គឺការរក្សានូវបទឈប់បាញ់ឱ្យបាន និងរកដំណោះស្រាយឱ្យវិលមករកប្រក្រតីភាពឡើងវិញ ដែលប្រទេសទាំងពីរធ្លាប់មានកន្លងទៅ។ ជាមួយគ្នានោះ **សម្តេចតេជោ** ក៏បានអរគុណចំពោះតួនាទីដ៏សកម្មរបស់ម៉ាឡេស៊ី ក្នុងការសម្របសម្រួលដោះស្រាយបញ្ហាព្រំដែនរវាងកម្ពុជានិងថៃ ជាពិសេសឯកឧត្តម **អាន់វ៉ា អ៊ីប្រាហ៊ីម**





*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

ដែលបានបំពេញតួនាទីយ៉ាងសកម្មនិងទាន់ពេលវេលាក្នុងការសម្របសម្រួលដោះស្រាយបញ្ហាព្រំដែនរវាងកម្ពុជានិងថៃ។

ឯកឧត្តម Mohd Hatta បានថ្លែងអំណរគុណចំពោះ**សម្តេចតេជោ** ដែលបានចែករំលែកនិងពន្យល់យ៉ាងក្បោះក្បាយនិងគ្រប់ជ្រុងជ្រោយអំពីទិដ្ឋភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជាពីអតីតកាលនិងបញ្ហាវិវាទព្រំដែនកម្ពុជានិងថៃ នាពេលបច្ចុប្បន្ន។ ឯកឧត្តមសង្ឃឹមថា បញ្ហាព្រំដែនកម្ពុជា-ថៃ នឹងអាចដោះស្រាយបានដោយសន្តិវិធី នាពេលខាងមុខ ហើយសន្តិភាពនឹងកើតមានឡើងវិញសម្រាប់ប្រទេសទាំងពីរ។ ជាមួយគ្នានោះផងដែរ ឯកឧត្តមក៏បានសម្តែងការកោតសរសើរចំពោះភាពរីកចម្រើន និងការអភិវឌ្ឍរបស់កម្ពុជា ជាពិសេសឯកឧត្តមពិតជាមានសំណាង ដែលបានធ្វើដំណើរចុះចតនៅអាកាសយានដ្ឋានអន្តរជាតិតេជោ ដែលជាអាកាសយានដ្ឋានអន្តរជាតិថ្មីរបស់កម្ពុជា ដែលមានភាពធំទូលាយ ដែលបញ្ជាក់អំពីការរីកចម្រើនរបស់កម្ពុជា។ ទន្ទឹមនឹងនេះ ឯកឧត្តមបានកោតសរសើរចំពោះភាពរីកចម្រើននៃរាជធានីភ្នំពេញ ដែលមានការអភិវឌ្ឍរីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេសផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្មតែម្តង៕

ប្រភព៖ Telegram Channel សម្តេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

# កម្ពុជានិងកុំមិនវែលដូមីនីក ត្រូវតែពង្រីកនូវចំណងមិត្តភាព តាមរយៈវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយគ្នា ឱ្យកាន់តែទូលំទូលាយបន្ថែមទៀត



*ឯកឧត្តមបណ្ឌិត Roosevelt Skerrit និងសម្តេចតេជោ ហ៊ុន សែន*

ក្នុងឱកាសទទួលជួបសម្តែងការគួរសមពី ឯកឧត្តមបណ្ឌិត Roosevelt Skerrit នាយករដ្ឋមន្ត្រីកុំមិនវែលដូមីនីក នៅវិមានព្រឹទ្ធសភា នាព្រឹកថ្ងៃសុក្រ ទី១០ ខែតុលា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានគូសបញ្ជាក់ថា ប្រទេសទាំងពីរ ត្រូវតែពង្រីកនូវចំណងមិត្តភាព តាមរយៈវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយគ្នា ឱ្យកាន់តែទូលំទូលាយបន្ថែមទៀត។

**សម្តេចតេជោ** បានលើកឡើងអំពីសក្តានុពលនៃទំនាក់ទំនងរវាងកម្ពុជានិងកុំមិនវែលដូមីនីក ហើយប្រទេសទាំងពីរគួរតែមានកិច្ចសហប្រតិបត្តិការរវាងគណបក្សនយោបាយឱ្យមានភាពស្អិតរមួតនឹងគ្នា ដើម្បីឱ្យទំនាក់ទំនងរវាងរដ្ឋ និងប្រជាជននៃប្រទេសទាំងពីរកាន់តែមានភាពល្អប្រសើរ និងជាកត្តាជំរុញដល់វិស័យផ្សេងៗទៀត។

**សម្តេចតេជោ** បានចាត់ទុកដំណើរទស្សនកិច្ចរបស់**ឯកឧត្តមនាយករដ្ឋមន្ត្រី**មកកាន់ព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសនេះ គឺជាប្រកដ៏សំខាន់ក្នុងការពង្រឹងពង្រីកទំនាក់ទំនងរវាងកម្ពុជា និងកុំមិនវែលដូមីនីក ឱ្យមានភាពរីកចម្រើនបន្ថែមទៀត។

នៅក្នុងជំនួបនោះ **ឯកឧត្តមនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះ**សម្តេចតេជោ** ដែលបានផ្តល់ឱកាស





*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

ឱ្យឯកឧត្តមនិងគណៈប្រតិភូបានជួបសម្តែងការគួរសម និងបានជម្រាបសម្តេចតេជោជ្រាបថា កាលពេលឯកឧត្តមនៅជានិស្សិត ឯកឧត្តមបានសិក្សាអំពីប្រវត្តិរបស់សម្តេចតេជោ ដែលបានតស៊ូជាច្រើនក្នុងការរំដោះប្រទេសកម្ពុជា ក៏ដូចជាការដឹកនាំប្រទេសឱ្យមានការរីកចម្រើន។ ឯកឧត្តមបានកោតសរសើរសម្តេចតេជោយ៉ាងខ្លាំងចំពោះភាពជាអ្នកដឹកនាំ និងបានហៅសម្តេចតេជោថា ជាស្ថាបត្យកររបស់កម្ពុជា ដែលនាំកម្ពុជាឱ្យមានសន្តិភាព និងមានភាពរីកចម្រើន។

នៅក្នុងឱកាសនោះ **សម្តេចតេជោ** បានអរគុណ**ឯកឧត្តមនាយករដ្ឋមន្ត្រី**ដែលបានចាប់អារម្មណ៍អំពីប្រវត្តិរបស់**សម្តេច**។ **សម្តេច**ក៏បានរៀបរាប់បន្ថែមអំពីការតស៊ូរបស់**សម្តេច** ក្នុងបុព្វហេតុនៃការរំដោះប្រទេសជាតិ តាំងពីការរំដោះប្រទេសពីរបបប្រល័យពូជសាសន៍ និងការនាំប្រទេសជាតិមករកសុខសន្តិភាព ឯកភាពទឹកដី ក្រោមនយោបាយឈ្នះ-ឈ្នះ នាំមកនូវសន្តិភាពពេញលេញនៅចុងឆ្នាំ១៩៩៨។ ជាមួយគ្នានោះ **សម្តេចតេជោ**ក៏បានចែករំលែកជាច្រើនទៀត ទាក់ទងនឹងបទពិសោធ ក្នុងការស្វែងរកសុខសន្តិភាពនិងការអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើនជាបន្តបន្ទាប់។

ក្នុងឱកាសនោះផងដែរ **សម្តេចតេជោ** បានលើកឡើងនិងពន្យល់អំពីរឿងរ៉ាវស្ថានភាពព្រំដែនកម្ពុជា-ថៃ ដែលបានកើតឡើងនាពេលកន្លងទៅ។ អ្វីដែលកម្ពុជាចង់បាន គឺការរក្សានូវបទឈប់បាញ់មួយដែលមានប្រសិទ្ធភាព និងការបញ្ចប់នូវវិបត្តិ ដើម្បីឈានទៅរកដំណោះស្រាយ និងទៅរកប្រក្រតីភាពឡើងវិញដូចប្រទេសទាំងពីរធ្លាប់មានពីមុនមក។

**ឯកឧត្តមនាយករដ្ឋមន្ត្រី** បានអរគុណ**សម្តេចតេជោ** ដែលបានចែករំលែកនូវបទពិសោធយ៉ាងពិស្តារ ជាពិសេសការតស៊ូការរំដោះប្រទេសជាតិ និងការស្វែងរកសន្តិភាពរបស់**សម្តេច**។ ឯកឧត្តមបានចាត់ទុក**សម្តេចតេជោ** ជាវចនានុក្រមអត្ថាធិប្បាយមួយរបស់ពិភពលោក និងជាមេដឹកនាំមួយដែលធ្វើឱ្យកម្ពុជាមានសុខសន្តិភាព និងជាផ្នែកមួយធ្វើឱ្យពិភពលោកមានសុខសន្តិភាពផងដែរ។ ទាក់ទងនឹងបញ្ហាព្រំដែនរវាងកម្ពុជានិងថៃ ឯកឧត្តមបានបង្ហាញអំពីការគាំទ្រចំពោះការដោះស្រាយបញ្ហាដោយសន្តិវិធី ហើយសង្ឃឹមថា បញ្ហាព្រំដែននេះនឹងអាចដោះស្រាយបានក្នុងពេលឆាប់ៗ និងវិលមករកប្រក្រតីភាពឡើងវិញ។ ឯកឧត្តមបានទទួលយកនូវសំណើរបស់**សម្តេចតេជោ** ក្នុងការជំរុញឱ្យមានកិច្ចសហប្រតិបត្តិការរវាងគណបក្សនៃប្រទេសទាំងពីរ ដែលឯកឧត្តមនឹងធ្វើកិច្ចការនេះ ព្រមទាំងបន្តកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា ជាបន្តបន្ទាប់ទៀត៕

ប្រភព៖ Telegram Channel សម្តេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

# ភាពរីកចម្រើនរបស់កម្ពុជា មិនអាចកាត់ផ្តាច់ចេញពីតួនាទីរបស់ជប៉ុនបានឡើយ





*ឯកឧត្តម TANAKA Akihiko និងសម្តេចតេជោ ហ៊ុន សែន*





*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

នារសៀលថ្ងៃចន្ទ ទី១៣ ខែតុលា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យឯកឧត្តម TANAKA Akihiko ប្រធានទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា។

នៅក្នុងជំនួបនោះ **សម្តេចតេជោ** បានបង្ហាញនូវក្តីរីករាយដែលបានជួបឯកឧត្តម TANAKA Akihiko ជាថ្មីម្តងទៀត បន្ទាប់ពីបានជួបគ្នាកាលពី១០ឆ្នាំមុន នៅពេលដែលឯកឧត្តមបានអញ្ជើញមកកាន់កម្ពុជា ដើម្បីសម្ពោធស្ពានមិត្តភាពកម្ពុជា-ជប៉ុន ( ស្ពានអ្នកលឿង ) កាលពីឆ្នាំ២០១៥។ **សម្តេចតេជោ**សង្ឃឹមថា វត្តមានរបស់ឯកឧត្តមមកកាន់កម្ពុជាសារជាថ្មីនេះ នឹងឃើញអំពីការអភិវឌ្ឍនិងភាពរីកចម្រើនរបស់កម្ពុជា ជាពិសេសតាមរយៈការជួយជ្រោមជ្រែងរបស់ជប៉ុនក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា។ ភាពរីកចម្រើនរបស់កម្ពុជា គឺមិនអាចផ្តាច់ចេញពីតួនាទីរបស់ជប៉ុន និង JICA បានឡើយ ក្នុងការចូលរួមចំណែកស្វែងរកសន្តិភាពនិងអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា។

ឯកឧត្តម TANAKA Akihiko បានសម្តែងនូវក្តីរីករាយដែលបានជួប**សម្តេចតេជោ**សារជាថ្មី ហើយបានបញ្ជាក់

ថា ពេលវេលាបានកន្លងទៅយ៉ាងលឿនបន្ទាប់ពីជួបគ្នាលើកមុន។ ឯកឧត្តមបានកោតសរសើរចំពោះការអភិវឌ្ឍរបស់កម្ពុជា និងលើកឡើងអំពីតួនាទីដ៏សំខាន់របស់ JICA ក្នុងការជួយអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា ដូចជា ការសាងសង់ស្ពានមិត្តភាពកម្ពុជា-ជប៉ុន ជ្រោយចង្វារ, ស្ពានគីសូណា, ស្ពានអ្នកលឿង, កំពង់ផែស្វយ័តព្រះសីហនុ រួមទាំងផ្លូវជាតិមួយចំនួន ដូចជា ផ្លូវជាតិលេខ១ ផ្លូវជាតិលេខ៥ ជាដើម។ល។

នៅក្នុងឱកាសនោះ **សម្តេចតេជោ** បានចែករំលែកនូវទស្សនាទានដែលជាចក្ខុវិស័យមួយចំនួន និងរំលឹកអំពីស្ថានភាពប្រវត្តិសាស្ត្រនិងការតស៊ូរបស់**សម្តេច**ក្នុងការរំដោះប្រទេសជាតិចេញពីរបបប្រល័យពូជសាសន៍ រួមទាំងការនាំកម្ពុជាមករកសន្តិភាពនៅចុងឆ្នាំ១៩៩៨និងការអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើនជាបន្តបន្ទាប់។ ជាមួយគ្នានោះ **សម្តេច**ក៏បានជម្រាប ឯកឧត្តម TANAKA Akihiko អំពីស្ថានភាពព្រំដែនកម្ពុជា-ថៃ ដែលជំហររបស់កម្ពុជាគឺធ្វើយ៉ាងណាចង់ឱ្យដោះស្រាយបញ្ហាដោយសន្តិវិធីនិងវិលត្រឡប់ទៅរកប្រក្រតីភាពឡើងវិញ។ ទន្ទឹមនឹងនោះ **សម្តេច**បានលើកឡើងអំពីការពង្រីកទំនាក់ទំនងពាណិជ្ជកម្មរវាងកម្ពុជា-ជប៉ុន និងស្នើឱ្យ JICA បន្តរួមចំណែកជំរុញសហប្រតិបត្តិការនៅវិស័យសំខាន់ៗជាច្រើនទៀតរវាងកម្ពុជា-ជប៉ុន។

ឯកឧត្តម TANAKA Akihiko បានសម្តែងការអរគុណចំពោះ**សម្តេចតេជោ** ដែលបានចែករំលែកបទពិសោធនិងប្រវត្តិនៃការតស៊ូ ការនាំប្រទេសកម្ពុជាមករកសុខសន្តិភាព និងវឌ្ឍនភាព។ ឯកឧត្តមបានបញ្ជាក់ថា JICA នឹងបន្តពង្រីកសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាលកម្ពុជា។ ពាក់ព័ន្ធនឹងបញ្ហាព្រំដែនកម្ពុជា-ថៃ ឯកឧត្តមសង្ឃឹមថា ភាគីទាំងពីរនឹងអាចឈានទៅរកការដោះស្រាយបញ្ហាដោយសន្តិវិធីនៅពេលខាងមុខ ហើយស្ថានភាពទំនាក់ទំនងរវាងប្រទេសទាំងពីរនឹងវិលមករកប្រក្រតីភាពឡើងវិញ។

ជាចុងក្រោយ **សម្តេចតេជោ** បានជូនពរដល់ឯកឧត្តម TANAKA Akihiko និងសហការី ឱ្យទទួលបានជោគជ័យក្នុងឱកាសបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា៕

ប្រភព៖ Telegram Channel សម្តេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

# កម្ពុជាមិនត្រូវការឱ្យប្រទេសណាថ្កោលទោសប្រទេសណាទេ ប៉ុន្តែអ្វីដែលកម្ពុជាចង់បានគឺធ្វើយ៉ាងណាជំរុញឱ្យភាគីទាំងពីរគោរពបទឈប់បាញ់ឱ្យមានប្រសិទ្ធភាព

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានគូសបញ្ជាក់ប្រាប់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**និងជារដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍តំបន់ និងជនបទ នៃប្រទេសម៉ាឡេស៊ីថា កម្ពុជាមិនត្រូវការឱ្យប្រទេសណាមួយ សម្ព័ន្ធមិត្ត ឬក៏មិត្តរបស់កម្ពុជា ទៅថ្កោលទោសប្រទេសណាទេ។ ប៉ុន្តែអ្វីដែលកម្ពុជាចង់បានគឺការធ្វើយ៉ាងណាជំរុញឱ្យភាគីទាំងពីរគោរពបទឈប់បាញ់ឱ្យមានប្រសិទ្ធភាព និងការស្វែងរកដំណោះស្រាយ ដើម្បីឈានទៅរកប្រក្រតីភាព នៃទំនាក់ទំនងរវាងកម្ពុជានិងថៃឡើងវិញ។

ការគូសបញ្ជាក់នេះ ត្រូវបានលើកឡើងក្នុងឱកាសដែល**សម្តេចតេជោ** អនុញ្ញាតឱ្យឯកឧត្តម Dato Seri' Ahmad Zahid bin Hamidi ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍តំបន់ និងជនបទ នៃប្រទេសម៉ាឡេស៊ី ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា នាព្រឹកថ្ងៃអង្គារ ទី១៤ ខែតុលា ឆ្នាំ២០២៥។





*ឯកឧត្តម Dato Seri' Ahmad Zahid bin Hamidi និងសម្តេចតេជោ ហ៊ុន សែន*

**សម្តេចតេជោ** បានពន្យល់អំពីស្ថានភាពនៃបញ្ហាព្រំដែនកម្ពុជា-ថៃ ដែលជាកង្វល់និងជាបញ្ហាមួយផុយស្រួយខ្លាំងណាស់ក្នុងការប៉ះទង្គិចគ្នាឡើងវិញ រួមទាំងការចាក់សំឡេងខ្មោច ឬសំឡេងផ្សេងៗពីភាគីថៃ ដែលរំខានដល់ពលរដ្ឋកម្ពុជា នៅភូមិជោគជ័យ និងភូមិព្រៃចាន់ ដែលបានកើតឡើងអស់រយៈពេលប្រមាណ៤យប់មកហើយ។ ទន្ទឹមគ្នានេះ **សម្តេច**បានផ្តាំផ្ញើនូវការនឹករលឹក និងអរគុណ ព្រមទាំងគោរពចំពោះតួនាទីស្នូលរបស់ឯកឧត្តម **អាន់វ៉ា អ៊ីប្រាហ៊ីម** នាយករដ្ឋមន្ត្រីម៉ាឡេស៊ី ដែលបានចូលរួមយ៉ាងសកម្មក្នុងការដោះស្រាយបញ្ហារវាងកម្ពុជានិងថៃ ក្នុងឋានៈឯកឧត្តមជាប្រធានអាស៊ាន។

**សម្តេចតេជោ** បានចាត់ទុកវត្តមានរបស់ឯកឧត្តមនិងសហការីនាពេលនោះ ជាផ្នែកដ៏សំខាន់ក្នុងការធ្វើឱ្យទំនាក់ទំនងរវាងកម្ពុជានិងម៉ាឡេស៊ី កាន់តែមានភាពជិតស្និទ្ធ និងរីកចម្រើនបន្ថែមទៀត។

នៅក្នុងឱកាសនោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងនិងសហប្រតិបត្តិការដ៏រឹងមាំរវាងរដ្ឋ និងប្រជាជននៃប្រទេសទាំងពីរ។ ឯកឧត្តមបានលើកឡើងអំពីការអភិវឌ្ឍវិស័យអាហារហាឡាល់នៅកម្ពុជា។ ឯកឧត្តមសង្ឃឹមថា នឹងមានគណៈកម្មការមួយ ដើម្បីពិភាក្សាទៅលើការងារនេះ។



*ទិដ្ឋភាពក្នុងជំនួបសម្ដែងការគួរសម*

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានរំលេចអំពីការពង្រីកនូវទំនាក់ទំនង និងសហប្រតិបត្តិការរវាងប្រទេសទាំងពីរលើវិស័យទេសចរណ៍ឱ្យកាន់តែរីកចម្រើន។ ប្រទេសម៉ាឡេស៊ីបានត្រៀមខ្លួនជាស្រេចក្នុងការទទួលអ្នកទេសចរកម្ពុជា ជាពិសេសទេសចរផ្នែកសុខាភិបាល ដែលទៅទទួលសេវាពិនិត្យសុខភាពនៅប្រទេសម៉ាឡេស៊ី។ ជាមួយគ្នានេះ ប្រទេសម៉ាឡេស៊ី នឹងពិនិត្យមើលលទ្ធភាពជាក់ស្ដែងក្នុងការបង្កើតមន្ទីរពេទ្យម៉ាឡេស៊ីនៅកម្ពុជា។

នៅក្នុងជំនួបនោះ **សម្ដេចតេជោ** បានឯកភាពចំពោះការលើកឡើងរបស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ចំពោះការពង្រីកទំនាក់ទំនងទ្វេភាគីរវាងកម្ពុជា និងម៉ាឡេស៊ី ឱ្យកាន់តែរីកចម្រើន។ **សម្ដេចតេជោ** បានកត់សម្គាល់ថា ដើម្បីឱ្យទំនាក់ទំនងរវាងប្រទេសទាំងពីរដើរទៅស្របគ្នាទាំងសេដ្ឋកិច្ចនិងនយោបាយ ការពង្រីកនូវទំនាក់ទំនងសេដ្ឋកិច្ច ពាណិជ្ជកម្ម ការវិនិយោគ និងទេសចរណ៍ រវាងប្រទេសទាំងពីរត្រូវតែធ្វើយ៉ាងណាឱ្យមានភាពរីកចម្រើនដូចគ្នាដែរ។

**សម្ដេចតេជោ** បានជំរុញឱ្យរដ្ឋាភិបាលប្រទេសទាំងពីរធ្វើយ៉ាងណា ជំរុញទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរឱ្យមានការកើនឡើងបន្ថែមទៀត។ **សម្ដេច**បានអរគុណប្រទេសម៉ាឡេស៊ី ដែលបានជួយទិញអង្ករពីកម្ពុជា និងជាប្រទេសទី១ ដែលនាំអង្ករពីកម្ពុជាច្រើនជាងគេ រហូតដល់ទៅ ៧ម៉ឺនតោន នៅឆ្នាំ២០២៤។ **សម្ដេច**សង្ឃឹមថា ប្រទេសម៉ាឡេស៊ីនឹងជួយទិញផលិតផលកសិកម្មផ្សេងទៀតពីកម្ពុជា។

ទាក់ទងនឹងវិស័យទេសចរណ៍សុខាភិបាល **សម្ដេចតេជោ** បានឯកភាពទៅនឹងការលើកឡើងរបស់**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ហើយ**សម្ដេច**បានផ្ដល់យោបល់ថា ប្រទេសម៉ាឡេស៊ីគួរតែបង្កើតមជ្ឈមណ្ឌលផ្ដល់ព័ត៌មាននៅកម្ពុជាអំពីការផ្ដល់សេវាសុខាភិបាលរបស់ម៉ាឡេស៊ី ដែលជាផ្នែកមួយឱ្យប្រជាពលរដ្ឋកម្ពុជា សិក្សានិងស្វែងរកជម្រើសក្នុងការទៅព្យាបាលនៅប្រទេសម៉ាឡេស៊ី។ ចំពោះអាហារហាឡាល់ **សម្ដេចតេជោ**បានលើកឡើងថា នេះជាបញ្ហាមួយដែលបានលើកឡើងជាយូរមកហើយ ដោយ**សម្ដេច**សង្ឃឹមថា នឹងលេចចេញជារូបរាងនៅពេលឆាប់ៗខាងមុខ ដែលប្រទេសទាំងពីរអាចធ្វើសហការជាមួយគ្នាបាន។

ជាចុងក្រោយ **សម្ដេចតេជោ** បានលើកឡើងអំពីបញ្ហាមីយ៉ាន់ម៉ា និងទីម័រឡេស្ដេ ដែលម៉ាឡេស៊ីក្នុងឋានៈជាប្រធានអាស៊ាន ក៏បានជួយសម្រួលឱ្យទីម័រឡេស្ដេចូលជាសមាជិកអាស៊ានពេញសិទ្ធិក្នុងពេលខ្លីខាងមុខនេះផងដែរ។

ប្រភព៖ Telegram Channel សម្ដេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តម អ៊ុច បូររិទ្ធ ដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ចុះជួបសំណេះសំណាលជាមួយមន្ត្រីរាជការ និងប្រជាពលរដ្ឋនៅស្រុកកោះសូទិន និងស្រុកស្រីសន្ធរ ខេត្តកំពង់ចាម



*ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញជាអធិបតីក្នុងពិធីសំណេះសំណាលជាមួយមន្ត្រីរាជការ អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋក្នុងស្រុកកោះសូទិន*

នាថ្ងៃអង្គារ ទី៣០ ខែកញ្ញា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្ដីទីព្រឹទ្ធសភានិងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ (ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ) បានអញ្ជើញដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ចុះជួបសំណេះសំណាលជាមួយមន្ត្រីរាជការ អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋក្នុងស្រុកកោះសូទិន និងស្រុកស្រីសន្ធរ ខេត្តកំពង់ចាម សរុបចំនួន៤៩៣នាក់។

នៅក្នុងពិធីសំណេះសំណាលទាំងពីរខាងលើ **ឯកឧត្តមប្រធានក្រុមភូមិភាគទី២** បាននាំប្រសាសន៍ផ្ដាំផ្ញើសួរសុខទុក្ខពីសំណាក់ សម្ដេចតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្ដីទីនិង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** និងបានជម្រាបជូនយ៉ាងក្បោះក្បាយអំពីមូលហេតុ និងសភាពការណ៍វិវត្តថ្មីៗនៅតាមបណ្ដោយព្រំប្រទល់កម្ពុជា-ថៃ ជាពិសេស សកម្មភាពឈ្លានពានយ៉ាងគឃ្លើន សាហាវព្រៃផ្សៃ អមនុស្សធម៌ និងល្បិចកលមិនចេះអៀនខ្មាសរបស់កងទ័ពថៃ មកលើបូរណភាពដែនដីរបស់កម្ពុជា។





*ឯកឧត្តម អ៊ុច បូររិទ្ធ សំណេះសំណាលជាមួយមន្ត្រីរាជការ អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋក្នុងស្រុកកោះសូទិន*





*ឯកឧត្តម អ៊ុច បូរិទ្ធ សំណេះសំណាលជាមួយមន្ត្រីរាជការ អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋក្នុងស្រុកស្រីសន្ធរ*



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាលជាមួយមន្ត្រីរាជការ អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋក្នុងស្រុកស្រីសន្ធរ*

ជាមួយនឹងការចូលរួមមរណទុក្ខ និងគោរពចំពោះវិញ្ញាណក្ខន្ធរបស់វីរយុទ្ធជនដែលបានពលីនៅក្នុងសមរភូមិ ដើម្បីប្រទេសជាតិ **ឯកឧត្តមប្រធានក្រុមភូមិភាគទី២** បានសម្តែងនូវគារវកិច្ចដ៏ជ្រាលជ្រៅបំផុតចំពោះវីរភាពដ៏អង់អាចក្លាហានរបស់វីរយុទ្ធជន ដែលបាននិងកំពុងឈរជើងយ៉ាងរឹងមាំ តស៊ូក្រាញននៀល ការពារទឹកដីមាតុភូមិកម្ពុជា។ ទន្ទឹមនឹងនេះ ឯកឧត្តមបានសម្តែងនូវមោទនភាពជាតិខ្ពស់ចំពោះការរួបរួមសាមគ្គី ឯកភាពជាតិជាធ្លុងមួយរបស់បងប្អូនប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ ទាំងក្នុងនិងក្រៅប្រទេសគាំទ្រទាំងកម្លាំងកាយ-ចិត្តនិងសម្ភារៈ ដល់វីរយុទ្ធជននៅសមរភូមិ និងបានអំពាវនាវដល់ថ្នាក់ដឹកនាំ និងប្រជាពលរដ្ឋក្នុងមូលដ្ឋានទាំងអស់បន្តរួបរួមសាមគ្គីគ្នាជុំវិញរាជរដ្ឋាភិបាល និងមានជំនឿជឿជាក់លើការដឹកនាំប្រកបដោយគតិបណ្ឌិត និងវៃឆ្លាតរបស់ **សម្តេចតេជោប្រធានព្រឹទ្ធសភា** និងសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីកម្ពុជា ក្នុងការចាត់វិធានការនានា ដើម្បីការពារបូរណភាពដែនដី និងដោះស្រាយវិវាទព្រំប្រទល់ជាមួយប្រទេសថៃដោយសន្តិវិធី ដោយផ្អែកលើច្បាប់អន្តរជាតិ លើធម្មនុញ្ញអង្គការសហប្រជាជាតិ និងធម្មនុញ្ញអាស៊ាន សំដៅធានាបាននូវសន្តិភាពប្រកបដោយចីរភាពជូនប្រជាជនទាំងពីរគឺ កម្ពុជានិងថៃ។

មុននឹងបញ្ចប់ **ឯកឧត្តមប្រធានក្រុមភូមិភាគទី២** បានផ្តាំផ្ញើដល់អាជ្ញាធរនិងបងប្អូនប្រជាពលរដ្ឋទាំងអស់នៅមូលដ្ឋានមេត្តាមានការប្រុងប្រយ័ត្នខ្ពស់ចំពោះរោហារសាស្ត្រអុជអាលបំបែកបំបាក់សង្គមជាតិរបស់ជនក្បត់ជាតិគជំនាន់ និងសុំឱ្យបងប្អូនវិនិច្ឆ័យចំពោះពាក្យពេចន៍របស់ជននេះដែលបានបន្ទុះបង្អាប់វីរភាពអង់អាចក្លាហានរបស់វីរយុទ្ធជន នៅក្នុងកាលៈទេសៈដែលប្រទេសជាតិកំពុងប្រឈមមុខនឹងអំពើឈ្លានពានមកលើបូរណភាពដែនដីរបស់ជាតិមាតុភូមិយើង៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញចូលរួមសន្និសីទគ្រឿងបរិក្ខារសមុទ្រពិភពលោក នៅសាធារណរដ្ឋប្រជាមានិតចិន



*ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញជួបពិភាក្សាការងារជាមួយឯកឧត្តម Zhao Long*

ក្នុងឱកាសអញ្ជើញចូលរួមសន្និសីទគ្រឿងបរិក្ខារសមុទ្រពិភពលោកឆ្នាំ២០២៥ ក្រោមមូលបទ «នាំក្តីសុបិនរបស់មនុស្សជាតិឆ្ពោះទៅកាន់អនាគតថ្មី» ពីថ្ងៃទី១៤-១៦ ខែតុលា ឆ្នាំ២០២៥ នៅទីក្រុងហ្វូចូវ ខេត្តហ្វូជៀន សាធារណរដ្ឋប្រជាមានិតចិន ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយ ឯកឧត្តម Zhao Long លេខាធិការរង នៃគណៈកម្មាធិការបក្សកុម្មុយនីស្តចិនប្រចាំខេត្តហ្វូជៀន និងជាអភិបាលខេត្តហ្វូជៀន។

នាឱកាសនោះ **ឯកឧត្តមអនុប្រធានទី១** បានថ្លែងអំណរគុណថ្នាក់ដឹកនាំខេត្តហ្វូជៀន ដែលបានអញ្ជើញកម្ពុជាចូលរួមក្នុងព្រឹត្តិការណ៍ដ៏សំខាន់នេះ ដើម្បីចែករំលែកបទពិសោធរបស់កម្ពុជានៅក្នុងការកសាងរចនាសម្ព័ន្ធសមុទ្រ។ ចំពោះទំនាក់ទំនងទ្វេភាគី ឯកឧត្តមបានគូសបញ្ជាក់ពីការយកចិត្តទុកដាក់ខ្ពស់បំផុតរបស់ **សម្តេចតេជោ** ប្រធានព្រឹទ្ធសភា និង**សម្តេចធិបតីនាយករដ្ឋមន្ត្រី** នៅក្នុងការពង្រឹងមិត្តភាព កិច្ចសហការយ៉ាងស៊ីជម្រៅ ការប្តេជ្ញាចិត្តរួមគ្នាក្នុងការលើកកម្ពស់ភាពជាដៃគូពិត ភាពរឹងមាំនៃមិត្តភាពដែកថែប ឆ្ពោះទៅកសាងសហគមន៍កម្ពុជា-ចិនជាមួយនឹងអនាគតរួមគ្នា ដោយឈរលើមូលដ្ឋានសាមគ្គីភាព ភាពធន់ ទំនុកចិត្ត និងមិត្តភាពយូរអង្វែង។

ជាការឆ្លើយតប ឯកឧត្តម Zhao Long បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់**ឯកឧត្តមអនុប្រធានទី១** ដែលបានអញ្ជើញដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមក្នុងសន្និសីទសមុទ្រដ៏មានសារៈសំខាន់នេះ។ ឯកឧត្តម Zhao Long បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងរវាងប្រទេសទាំងពីរ ដោយបានគូសបញ្ជាក់ថា កម្ពុជា-ចិន មានទំនាក់ទំនងជាប្រពៃណី កិច្ចសហប្រតិបត្តិការស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ និងជាមិត្តដែកថែប។

ដោយឡែក នៅក្នុងពិធីបើកសន្និសីទស្តីពីបរិក្ខារសមុទ្រពិភពលោកឆ្នាំ២០២៥ **ឯកឧត្តមអនុប្រធានទី១** បានអញ្ជើញថ្លែងសុន្ទរកថាក្នុងពិធីបើកសន្និសីទ ដែលមានការចូលរួមពីគណៈប្រតិភូជាថ្នាក់ដឹកនាំព្រឹទ្ធសភា រដ្ឋសភា និងរដ្ឋាភិបាលមកពីប្រទេសចំនួន២៧ ដោយឯកឧត្តមបានសង្កត់ធ្ងន់ថា «ក្នុងនាមជាសមាជិកដ៏មានមោទនភាពរបស់អាស៊ាន កម្ពុជានៅតែប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការជំរុញកិច្ចសហប្រតិបត្តិការសមុទ្រ និងសមាហរណកម្មតំបន់។ ភាពជាអ្នកដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភាកម្ពុជា ដែលបានឆ្លុះបញ្ចាំងនៅក្នុង







*ឯកឧត្តម អ៊ុច បូរិទ្ធ ឡើងថ្លែងសុន្ទរកថាក្នុងពិធីបើកសន្និសីទ*

គម្រោង**ព្រែកជីកហ្វូណនតេជោ** បានបង្ហាញពីការយកចិត្តទុកដាក់ខ្ពស់របស់កម្ពុជាចំពោះវឌ្ឍនភាពរយៈពេលវែងពាក់ព័ន្ធនឹងដែនសមុទ្រនិងការតភ្ជាប់ក្នុងតំបន់»។ ឯកឧត្តមបានបញ្ជាក់បន្ថែមថា «**ព្រែកជីកហ្វូណនតេជោ** មានលក្ខណៈលើសពីគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់ជាតិ ពោលគឺវាបានបង្កប់នូវស្មារតីនៃសន្និសីទនេះ ដែលបាននាំក្តីសង្ឃឹមរបស់ប្រជាជនយើងឆ្ពោះទៅរកវឌ្ឍនភាពនិងចីរភាព»។ ឯកឧត្តម បានបន្តថា កម្ពុជាគាំទ្រយ៉ាងមុតមាំចំពោះកិច្ចខិតខំប្រឹងប្រែង ដើម្បីសាងសង់កំពង់ផែបៃតង និងសន្សំសំចៃថាមពល តាមរយៈការវិនិយោគថាមពលនៅលើផ្ទៃការលើកដាក់ទំនិញប្រើអគ្គិសនី និងប្រព័ន្ធភស្តុភារកម្មឌីជីថល ដែលនឹងជួយការពារបរិស្ថាន និងបង្កើនប្រសិទ្ធភាពពាណិជ្ជកម្ម។ ខណៈដែលកម្ពុជាត្រៀមចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច រាជរដ្ឋាភិបាលកម្ពុជាកំពុងតម្រឹមគោលនយោបាយជាតិជាមួយនឹងវិស័យអាទិភាពចំនួន២ គឺកំណើនបៃតងនិងបរិវត្តកម្មឌីជីថល។ ក្នុងន័យនេះ ឧស្សាហកម្មសមុទ្រនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ចរបស់កម្ពុជា និងភ្ជាប់ការរីកលូតលាស់ប្រកបដោយចីរភាពរបស់កម្ពុជាជាមួយពាណិជ្ជកម្មតំបន់ និងពិភពលោក។

ក្រោយពីបានអញ្ជើញថ្លែងនៅក្នុងពិធីបើកសន្និសីទ **ឯកឧត្តមអនុប្រធានទី១** ក៏បានអញ្ជើញបន្តថ្លែងសុន្ទរកថាបើកកិច្ចពិភាក្សាតុមូល ក្រោមប្រធានបទ «កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍឧស្សាហកម្មសមុទ្រអាស៊ាន-ចិន ឆ្នាំ២០២៥»។ ក្នុងឱកាសនោះ ឯកឧត្តមបានជម្រាបជូនអ្នកចូលរួមអំពីអាទិភាពជាយុទ្ធសាស្ត្ររបស់កម្ពុជាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម តាមរយៈការដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ដែលបានឆ្លុះបញ្ចាំងពីសារៈសំខាន់នៃការផ្លាស់ប្តូរបៃតង និងបរិវត្តកម្មឌីជីថល។ ឯកឧត្តមបានសង្កត់ធ្ងន់ថា ភាពប្រកួតប្រជែងរយៈពេលវែងនៃវិស័យសមុទ្រ គឺអាស្រ័យទៅលើការធ្វើសមាហរណកម្មបច្ចេកវិទ្យានៃ ឧស្សាហកម្ម៤.០ តួយ៉ាងស្វ័យប្រវត្តិកម្មនិងប្រព័ន្ធភស្តុភារកម្មឌីជីថល។ ដូច្នេះ កម្ពុជាផ្តល់សារៈសំខាន់ទៅលើតួនាទីរបស់សហគ្រាសធុនតូចនិងមធ្យម (SMEs) នៅក្នុងដំណើរការផ្លាស់ប្តូរនេះ តាមរយៈការផ្តល់លទ្ធភាពដល់ SMEs ក្នុងការទទួលបាននូវស្តង់ដារបៃតង និងបញ្ជ្រាបខ្លួនទៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងតំបន់។ នៅចុងបញ្ចប់ **ឯកឧត្តមអនុប្រធានទី១** ក៏បានបង្ហាញការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការធ្វើការជាមួយដៃគូនៅក្នុងអាស៊ាន និងប្រទេសចិន សំដៅកសាងឧស្សាហកម្មដែនសមុទ្រដែលមានភាពធន់ សំឡឹងឆ្ពោះទៅមុខ និងប្រកបដោយចីរភាព៕

ប្រភព៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

# កម្ពុជាគ្មានបំណងចង់មានទំនាស់ជាមួយប្រទេសណាមួយឡើយ

ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានគូសបញ្ជាក់នៅក្នុងកិច្ចពិភាក្សាទូទៅនៃមហាសន្និបាតលើកទី១៥១ នៃសហភាពអន្តរសភា (IPU) នាទីក្រុងហ្សឺណែវ ប្រទេសស្វីស នាថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៥ ថាកម្ពុជាជាប្រជាជាតិដែល «បានរងទុក្ខវេទនាយ៉ាងខ្លាំងកាលពីអតីតកាល» ហើយ «ស្រឡាញ់និងការពារសុខសន្តិភាព» ជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍជាតិ កម្ពុជា «គ្មានបំណងចង់មានទំនាស់ជាមួយប្រទេសណាមួយឡើយ ជាពិសេសថៃ» ប៉ុន្តែ «ដើម្បីការពិត យើងខ្ញុំមានភាពចាំបាច់ត្រូវធ្វើការឆ្លើយតប»។



*ឯកឧត្តម អ៊ុច បូររិទ្ធ ឡើងថ្លែងបទអន្តរាគមន៍ក្នុងមហាសន្និបាតលើកទី១៥១ នៃសហភាពអន្តរសភា (IPU)*

**ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បានគូសបញ្ជាក់យ៉ាងដូច្នេះ ក្នុងឱកាសអញ្ជើញឡើងថ្លែងបទអន្តរាគមន៍ក្រោមមូលបទ «ការលើកកម្ពស់បទដ្ឋានមនុស្សធម៌និងការគាំទ្រសកម្មភាពមនុស្សធម៌ក្នុងពេលមានវិបត្តិ»។ ឯកឧត្តមបានអំពាវនាវឱ្យមានការគោរពបទដ្ឋានមនុស្សធម៌សកល ដោយបញ្ជាក់ថា «រង្វាស់ពិតប្រាកដនៃប្រជាជាតិមួយ គឺស្ថិតនៅលើការគោរពអនុសញ្ញាទីក្រុងហ្សឺណែវនិងសេចក្តីថ្លៃថ្នូររបស់មនុស្សខណៈដែលកំពុងរងការរំលោភបំពាន»។

**ឯកឧត្តមអនុប្រធានទី១** បានបញ្ជាក់យ៉ាងច្បាស់ថា ព្រំដែនរវាងប្រទេសទាំងពីរ «មិនមែនមិនទាន់បានកំណត់នោះទេ» តែមានមូលដ្ឋានក្នុង «លិខិតុបករណ៍អន្តរជាតិដែលចងកាតព្វកិច្ចអនុវត្ត» រួមទាំងអនុសញ្ញាបារាំង-សៀម ឆ្នាំ១៩០៤ សន្ធិសញ្ញា ឆ្នាំ១៩០៧ និងផែនទីឧបសម្ព័ន្ធ ដែលត្រូវបានបញ្ជាក់អះអាងឡើងវិញដោយសាលក្រមរបស់តុលាការយុត្តិធម៌អន្តរជាតិ (ICJ) ក្នុងឆ្នាំ១៩៦២ និងឆ្នាំ២០១៣។ ឯកឧត្តមបានសង្កត់ធ្ងន់ថា ជម្លោះកើតឡើង «កើតចេញពីការមិនគោរពលិខិតុបករណ៍ច្បាប់ ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិទាំងនេះ»។



*ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញចូលរួមមហាសន្និបាតលើកទី១៥១ នៃសហភាពអន្តរសភា (IPU)*

**ឯកឧត្តមអនុប្រធានទី១** បានសម្តែងក្តីព្រួយបារម្ភខណៈសន្តិភាពនៅតាមបណ្តោយព្រំដែននៅតែ «មានភាពផុយស្រួយ»។ ប្រជាពលរដ្ឋកម្ពុជានៅតែប្រឈមមុខនឹងការជម្លៀសចេញពីទីលំនៅ ការហ៊ុមព័ទ្ធ និងការគំរាមកំហែងបណ្តេញចេញ ហើយទាហានកម្ពុជា១៨នាក់ នៅតែបន្ត

ឃុំខ្លួនដោយខុសច្បាប់ ដែលរំលោភលើអនុសញ្ញាទីក្រុងហ្សឺណែវទី៣។ ឯកឧត្តមបានលើកឡើងអំពី «ការបំភិតបំភ័យផ្លូវចិត្ត» ដូចជា «ការចាក់បន្លឺសំឡេងខ្មោចនិងសំឡេងស្រែកត្រហូរយំនៅពេលយប់» ថាជា «ការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស» ដែលរំលោភលើអនុសញ្ញាទីក្រុងហ្សឺណែវទី៤។

ក្នុងការឆ្លើយតបទៅនឹងការចោទប្រកាន់នានា **ឯកឧត្តមអនុប្រធានទី១** បានច្រានចោលការអះអាងអំពី «ការធ្វើយោធូបនីយកម្ម» តំបន់បេតិកភណ្ឌពិភពលោក ថា «គ្មានមូលដ្ឋានទាល់តែសោះ» ដោយបញ្ជាក់ថា កម្ពុជាការពារប្រាសាទព្រះវិហារ «មិនមែនតាមរយៈការប្រើអាវុធនោះទេ ប៉ុន្តែតាមរយៈភាពជាបេតិកភណ្ឌ ច្បាប់ និងការអត់ធ្មត់» «ប្រាសាទមិនមែនគ្រាន់តែជាកេរដំណែលពីអតីតកាលប៉ុណ្ណោះទេ តែវាបង្កប់នូវការចងចាំ អត្តសញ្ញាណ និងដួងព្រលឹងនៃប្រជា-ជាតិ។ ការធ្វើឱ្យប៉ះពាល់ដល់បេតិកភណ្ឌទាំងនេះ គឺធ្វើឱ្យរបួសដល់មនុស្សជាតិទាំងមូល»។ ឯកឧត្តមបានបន្ថែមថា «ឥរិយាបថរបស់យើងត្រូវបានដឹកនាំដោយគោលការណ៍ មិនមែនដោយការឃោសនាឡើយ។ យើងដឹកនាំដោយច្បាប់ មិនមែនដោយមហិច្ឆតានោះទេ»។ ឯកឧត្តម ក៏បានហៅការចោទប្រកាន់ពីការដាក់គ្រាប់មីនថ្មីថា «ទាំងគ្មានមូលដ្ឋាន និងទាំងមិនអាចកើតឡើង» ដោយគូសបញ្ជាក់ពីកំណត់ត្រារបស់កម្ពុជាដែលបាន «បំផ្លាញគ្រាប់មីនជាងបីលានគ្រាប់» និងជា «អ្នកតស៊ូមតិនាំមុខគេក្នុងការដោះមីន ក្រោមអនុសញ្ញាអូតាវ៉ា»។

**ឯកឧត្តមអនុប្រធានទី១** បានអះអាងនូវជំហរ «ឥតងាករេ» របស់កម្ពុជា ដែលជឿជាក់ថា «ជម្លោះត្រូវតែដោះស្រាយដោយសន្តិវិធី តាមរយៈការសន្ទនា ការទូត និងការគោរពច្បាប់អន្តរជាតិ»។ «ការពិត និងតម្លាភាព» គឺចាំបាច់ ដើម្បីស្តារទំនុកចិត្ត។ ឯកឧត្តមបានបញ្ចប់ដោយសារយ៉ាងច្បាស់លាស់ថា «បទដ្ឋានមនុស្សធម៌ មិនអាចចរចាបានទេ។ សកម្មភាពមនុស្សធម៌ មិនត្រូវរងការរារាំងជាដាច់ខាត ហើយការពិតត្រូវតែឈ្នះលើព័ត៌មានមិនពិត»៕

ប្រភព៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន




*ទិដ្ឋភាពក្នុងការចូលរួមមហាសន្និបាតលើកទី១៥១ នៃសហភាពអន្តរសភា (IPU)*

# ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញជួបពិភាក្សាការងារ ជាមួយអគ្គលេខាធិការ IPU នៅប្រទេសស្វីស

ក្នុងឱកាសអញ្ជើញចូលរួមមហាសន្និបាតលើកទី១៥១ នៃសហភាពអន្តរសភា (IPU) នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស នៅថ្ងៃអាទិត្យ ទី១៩ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា និងជាប្រធានគណៈប្រតិភូសភាកម្ពុជា បានអញ្ជើញជួបពិភាក្សាការងារជាមួយឯកឧត្តម Martin Chungong អគ្គលេខាធិការ នៃសហភាពអន្តរសភា។



*ឯកឧត្តម Martin Chungong និងឯកឧត្តម អ៊ុច បូរិទ្ធ*

ឯកឧត្តម Martin Chungong បានថ្លែងអំណរគុណឯកឧត្តម **អ៊ុច បូរិទ្ធ** ដែលបានដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមមហាសន្និបាត IPU លើកទី១៥១ ដែលនេះបញ្ជាក់ពីការយកចិត្តទុកដាក់ និងរួមគ្នាជំរុញការទូតសភា កិច្ចសន្ទនានិងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងក្របខ័ណ្ឌ IPU។ ឯកឧត្តម **អ៊ុច បូរិទ្ធ** ក៏បានកោតសរសើរចំពោះអគ្គលេខាធិការសហភាពអន្តរសភា ដែលបាននិងកំពុងបំពេញតួនាទីប្រកបដោយប្រសិទ្ធភាព ក្នុងការដឹកនាំលេខាធិការដ្ឋាន នៃសហភាពអន្តរសភា ដើម្បីសម្រេចនូវបេសកកម្មដ៏ឧត្តុង្គឧត្តមរបស់សហភាពអន្តរសភា។

ឯកឧត្តម **អ៊ុច បូរិទ្ធ** និងឯកឧត្តម Martin Chungong បានផ្លាស់ប្តូរយោបល់ សំដៅរួមចំណែកដល់ IPU ក្នុងការលើកកម្ពស់សន្តិភាព អភិបាលកិច្ចល្អ ប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការអភិវឌ្ឍប្រកបដោយ ចីរភាពលើពិភពលោក។ ឯកឧត្តម **អ៊ុច បូរិទ្ធ** ស្នើ IPU បន្តកម្មវិធីបណ្តុះបណ្តាលលើកកម្ពស់សមត្ថភាពមន្ត្រី នៃអគ្គលេខាធិការដ្ឋាន នៃបណ្តាសភាលើពិភពលោក រួមមានសភាកម្ពុជាផងដែរ។

ឯកឧត្តម **អ៊ុច បូរិទ្ធ** បានសម្តែងការពេញចិត្តចំពោះប្រធានបទនៃកិច្ចពិភាក្សាទូទៅ ក្រោមមូលបទស្តីពី ការប្រកាន់ខ្ជាប់នូវបទដ្ឋានមនុស្សធម៌ និងគាំទ្រសកម្មភាពមនុស្សធម៌ក្នុងគ្រាមានវិបត្តិ (Upholding humanitarian norms and supporting humanitarian action in times of crisis) ដែលមូលបទនេះ សក្តិសមបំផុតចំពោះបរិបទពិភពលោកដែលពោរពេញដោយបញ្ហាប្រឈម ជាពិសេសវិបត្តិមនុស្សធម៌កើតឡើងដោយសង្គ្រាមនិងជម្លោះប្រើកម្លាំង។

ពាក់ព័ន្ធជម្លោះព្រំដែនកម្ពុជា-ថៃថ្មីៗនេះ ដែលបណ្តាលឱ្យមានការបាត់បង់អាយុជីវិតជនស៊ីវិល ការបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ ផ្ទះសម្បែង សាលារៀន វត្តអារាម ប្រាសាទបុរាណ និងជនភៀសសឹករាប់សែននាក់នៅកម្ពុជា ឯកឧត្តម **អ៊ុច បូរិទ្ធ** បានបញ្ជាក់ថា ប្រទេសដែលធ្លាប់ធ្លាក់ក្នុងភ្នក់ភ្លើងសង្គ្រាមដូចកម្ពុជាយល់យ៉ាងច្បាស់ពីតម្លៃមិនអាចកាត់ថ្លៃបាននៃសន្តិភាពនិងអះអាងថា កម្ពុជាបន្តរក្សាជំហរដោះស្រាយជម្លោះជាមួយប្រទេសជិតខាងដោយសន្តិវិធី ទាំងយន្តការទ្វេភាគីនិងពហុភាគី ស្របតាមច្បាប់អន្តរជាតិ។ កម្ពុជា ចង់បានតែសន្តិភាព និងទទូចស្នើភាគីថៃដោះលែងទាហានកម្ពុជាទាំង១៨រូប ដែលចាប់ខ្លួនដោយទាហានថៃ ក្រោយកិច្ចព្រមព្រៀងបទឈប់បាញ់ នៅថ្ងៃទី១៨ កក្កដា ២០២៥។

ពាក់ព័ន្ធសំណើសេចក្តីព្រាងសេចក្តីសម្រេចសម្រាប់របៀបវារៈបន្ទាន់ នៃមហាសន្និបាតនៃសហភាពអន្តរសភា អំពីការពង្រឹងសកម្មភាពសភាប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនតាមអ៊ីនធឺណិត ខណៈប្រកាន់ខ្ជាប់គោលការណ៍មនុស្សធម៌ (Strengthening parliamentary action against transnational cybercrime while upholding humanitarian principles) ឯកឧត្តម **អ៊ុច បូរិទ្ធ** បានជម្រាបជូនឯកឧត្តម Martin Chungong ថា ដើម្បីធានាភាពជឿជាក់ មានប្រសិទ្ធភាពក្នុងការអនុវត្ត និងមានលក្ខណៈបរិយាបន្ន កម្ពុជាសូមស្នើឱ្យជំរុញកែសម្រួលសេចក្តីព្រាងសេចក្តីសម្រេចខាងលើ ដើម្បីឆ្លុះបញ្ចាំងគោលការណ៍មិនលំអៀង មិនមានគោលដៅបម្រើជានយោបាយ និងមានភាពជាសកល ដែលការកែសម្រួលនេះ មហាសន្និបាតនឹងរៀបចំបាននូវសេចក្តីសម្រេចចិត្តមួយ ដែលបង្កើតការរួបរួមសហប្រតិបត្តិការ ជាជាងការបំបែកបំបាក់គ្នា នៅក្នុងបេសកកម្មរួមប្រឆាំងឧក្រិដ្ឋកម្មអនឡាញ និងប្រកាន់ខ្ជាប់នូវភាពថ្លៃថ្នូរនៃមនុស្សជាតិ។ ឯកឧត្តម Martin Chungong បានថ្លែងអំណរគុណចំពោះការចូលរួមប្រកបដោយស្ថាបនារបស់កម្ពុជា ក្នុងការងារអន្តរជាតិនេះ៕

ប្រភព៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

# មិត្តភាពកម្ពុជា-ជប៉ុន គឺពោរពេញដោយការគោរពស្រឡាញ់ និងការពារគ្នាទៅវិញទៅមក





*ឯកឧត្តមបណ្ឌិត ឆន់ វឌ្ឍនា និងឯកឧត្តម UENO Atsushi*

ឯកឧត្តមបណ្ឌិត **ឆន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា និងឯកឧត្តម UENO Atsushi ឯកអគ្គរាជទូតជប៉ុន បានបញ្ជាក់គ្នាជាថ្មីម្តងទៀត ក្នុងជំនួបទទួលទានអាហារពេលល្ងាចការងារ នាល្ងាចថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៥ នៅស្ថានទូតជប៉ុន រាជធានីភ្នំពេញ ថា មិត្តភាពកម្ពុជា-ជប៉ុន គឺពោរពេញដោយការគោរពស្រឡាញ់និងការពារគ្នាទៅវិញទៅមក។

**ឯកឧត្តមបណ្ឌិតអនុប្រធានទី២ព្រឹទ្ធសភា** បានរំលឹកអំពីទំនាក់ទំនងការទូតរវាងកម្ពុជា-ជប៉ុន ដែលមានឡើងតាំងពីឆ្នាំ១៩៥៣ ហើយត្រូវបានបន្តពង្រឹងពង្រីកកាន់តែរឹងមាំ ដោយថ្នាក់ដឹកនាំរាជរដ្ឋាភិបាល នៃប្រទេសទាំងពីរ។ លើសពីនេះ ប្រជាជនកម្ពុជាមានមនោសញ្ចេតនាល្អចំពោះប្រជាជននិងប្រទេសជប៉ុន ដែលតែងតែជួយកម្ពុជាទាំងក្នុងវិស័យច្បាប់ អប់រំ សង្គម កសិកម្ម និងការដោះមីនជាដើម ជាពិសេសចាប់តាំងពីឆ្នាំ១៩៩៣ រហូតមកដល់បច្ចុប្បន្ន។

នៅក្នុងជំនួបនោះ **ឯកឧត្តមបណ្ឌិត** និង**ឯកឧត្តមឯកអគ្គរាជទូតជប៉ុន** ក៏បានពិភាក្សាអំពី ស្ថានភាពពិភពលោក ដែលមានភាពតានតឹងផ្នែកសន្តិសុខ នយោបាយ និងពាណិជ្ជកម្ម។ ដោយឡែកស្ថានភាពនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ត្រូវបានមើលឃើញថា នៅតែផុយស្រួយ ទោះបីមានបទឈប់បាញ់ក៏ដោយ។ **ឯកឧត្តមបណ្ឌិត**បានជម្រាបជូនឯកឧត្តមឯកអគ្គរាជទូតថា កម្ពុជាត្រូវការសន្តិភាព និងបានព្យាយាមដោះស្រាយជម្លោះ តាមរយៈការចរចា ផ្អែកលើច្បាប់និងកិច្ចព្រមព្រៀង ប្រកបដោយភាពអត់ធ្មត់និងដោយបើកចំហ ពោលគឺកម្ពុជា រីករាយឱ្យមានការចូលរួមពីបណ្តាប្រទេសអាស៊ាន អាម៉េរិក ចិន និងជប៉ុនជាដើម។

**ឯកឧត្តមបណ្ឌិត** និង**ឯកឧត្តមឯកអគ្គរាជទូត** សង្ឃឹមថាបញ្ហាព្រំដែនកម្ពុជា-ថៃ នឹងវិលត្រឡប់ទៅរកប្រក្រតីភាពវិញក្នុងពេលឆាប់ខាងមុខនេះ ជាពិសេសគឺការដោះលែងត្រឡប់មកវិញនូវទាហានកម្ពុជា១៨រូប ដែលកងទ័ពថៃចាប់ធ្វើជាចំណាប់ខ្មាំង ក្រោយបទឈប់បាញ់ចូលជាធរមាន៕

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបការងារមុនទទួលទានអាហារពេលល្ងាច*

# កម្ពុជានិងហ្វីលីពីន នឹងបន្តរីកចម្រើនជាមួយគ្នា នៅលើវិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម និងបច្ចេកវិទ្យា

នាព្រឹកថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៥ នៅវិមានព្រឹទ្ធសភា ឯកឧត្តមបណ្ឌិត **ធន់ ខ្លៀនា** អនុប្រធានទី២ព្រឹទ្ធសភា បានទទួលជួបពិភាក្សាការងារជាមួយ លោកជំទាវ Flerida Ann Camille P.Mayo ឯកអគ្គរដ្ឋទូតហ្វីលីពីន ប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការលើវិស័យសភា កសិកម្ម អប់រំ ពាណិជ្ជកម្ម និងបច្ចេកវិទ្យា។

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត** បានចូលរួមរំលែកមរណទុក្ខ និងសោកស្តាយជាទីបំផុតជាមួយរដ្ឋាភិបាលហ្វីលីពីន ចំពោះគ្រោះរញ្ជួយដី ដែលបានវាយប្រហារហ្វីលីពីន កាលពីយប់ថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៥។

**ឯកឧត្តមបណ្ឌិត** បានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលនៃទំនាក់ទំនងកម្ពុជា-ហ្វីលីពីន ដែលកាន់តែរឹងមាំបន្ទាប់ពីមានការផ្លាស់ប្តូរដំណើរទស្សនកិច្ចកម្រិតកំពូលរវាង**នាយករដ្ឋមន្ត្រីកម្ពុជា**និង**ប្រធានាធិបតីហ្វីលីពីន** នាពេលថ្មីៗនេះ។ **ឯកឧត្តមបណ្ឌិត** បានបន្តថា ហ្វីលីពីន គឺជាសមាជិកដ៏សំខាន់ក្នុងអាស៊ាន ដែលជាកម្លាំងចលករមួយអាចជំរុញសេដ្ឋកិច្ច និងពាណិជ្ជកម្មក្នុងអាស៊ានឱ្យកាន់តែរឹងមាំ និងធន់នឹងវិបត្តិខាងក្រៅបាន។ ជាក់ស្តែង កំណើននៃការនាំចេញអង្ករគ្រាប់ធញ្ញជាតិ ផលិតផលកសិកម្ម និងទំនិញជាច្រើនមុខទៀតរបស់កម្ពុជា ទៅកាន់ហ្វីលីពីន។




*លោកជំទាវ Flerida Ann Camille P.Mayo (រូបទី១.ស្តាំ) ជួបពិភាក្សាការងារជាមួយឯកឧត្តមបណ្ឌិត ធន់ ខ្លៀនា អនុប្រធានទី២ព្រឹទ្ធសភា (រូបទី២.កណ្តាល)*

**ឯកឧត្តមបណ្ឌិតនិងលោកជំទាវឯកអគ្គរដ្ឋទូត** បានផ្លាស់ប្តូរយោបល់ពីបញ្ហាអន្តរជាតិ និងជាពិសេសបញ្ហាជម្លោះនៅក្នុងតំបន់អាស៊ាន។ ចំពោះស្ថានភាពតំបន់ព្រំដែនកម្ពុជា-ថៃ នៅតែមានភាពតានតឹង និងផុយស្រួយ ទោះបីមានបទឈប់បាញ់ក៏ដោយ។ ឯកឧត្តម បញ្ជាក់ថាកម្ពុជា នឹងអត់ធ្មត់ដល់ទីបំផុតចំពោះការញុះញង់និងបានព្យាយាមដោះស្រាយតាមការចរចាផ្អែកលើច្បាប់និងកិច្ចព្រមព្រៀង ដើម្បីសន្តិភាព និងការវិលត្រឡប់ទៅរកប្រក្រតីភាពក្នុងពេលឆាប់ខាងមុខនេះ ជាពិសេសគឺការដោះលែង ត្រឡប់មកវិញនូវទាហានកម្ពុជា១៨រូប ដែលកងទ័ពថៃចាប់ធ្វើជាចំណាប់ខ្មាំង ក្រោយបទឈប់បាញ់ចូលជាធរមាន។

**ឯកឧត្តមបណ្ឌិត** និង**លោកជំទាវឯកអគ្គរដ្ឋទូត** យល់ស្របថា ហ្វីលីពីននិងកម្ពុជា ត្រូវចាប់ឱកាសក្នុងបញ្ហាប្រឈមក្នុងស្ថានភាពពិភពលោកបែបនេះ ដើម្បីពង្រឹងទំនាក់ទំនងឱ្យកាន់តែរឹងមាំនិងបន្តការរីកចម្រើនជាមួយគ្នា នៅលើវិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម និងវិស័យផ្សេងៗទៀត៕

អត្ថបទ៖ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា គាំទ្រយ៉ាងពេញទំហឹងសម្រាប់ដៃគូសហការរវាងវិស័យឯកជន និងគ្រឹះស្ថានសាធារណៈរដ្ឋបាល



ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អនុប្រធានទី២ព្រឹទ្ធសភា

នារសៀលថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានទទួលជួបពិភាក្សានិងសម្របសម្រួលឱ្យវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប និងក្រុមហ៊ុនស្អាត សហការគ្នាដើម្បីជំរុញការសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលជំនាញកសិកម្មផ្សារភ្ជាប់នឹងបច្ចេកវិទ្យា។

ក្នុងនាមសមាជិកព្រឹទ្ធសភា **ឯកឧត្តមបណ្ឌិត** បានសម្តែងនូវការគាំទ្រយ៉ាងពេញទំហឹងនិងលើកទឹកចិត្តឱ្យមានកិច្ចសហការគ្នាយ៉ាងជិតស្និទ្ធរវាងវិស័យឯកជន និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្នុងការងារស្រាវជ្រាវ និងបណ្តុះបណ្តាល ដើម្បីជំរុញភាពច្នៃប្រឌិតថ្មីៗ ដែលផ្តល់ផលប្រយោជន៍ដល់សិស្ស និស្សិត និងប្រជាពលរដ្ឋ ជាពិសេសការចូលរួមចំណែកអភិវឌ្ឍវិស័យកសិកម្មកម្ពុជាប្រកបដោយចីរភាព។

**ឯកឧត្តមបណ្ឌិត** បានលើកឡើងអំពីតួនាទីយ៉ាងសំខាន់នៃបច្ចេកវិទ្យាឌីជីថល ដែលជួយដល់កសិករយើងក្នុងការកែលម្អផលិតភាព កាត់បន្ថយការប្រើប្រាស់ធនធានលើសប្រមាណនិងបន្ថយការប៉ះពាល់ដល់បរិស្ថានជាអតិបរមា។

គួរកត់សម្គាល់ផងដែរថា ក្នុងចំណោមបច្ចេកវិទ្យាដែលមានសក្តានុពលខ្ពស់ Drone កសិកម្ម មានគុណសម្បត្តិច្រើនយ៉ាងរួមមាន៖

**-ការជួយស្ទង់មើលស្ថានភាពដំណាំនិងគ្រប់គ្រងការប្រើប្រាស់ជី ថ្នាំកសិកម្ម និងទឹកប្រកបដោយប្រសិទ្ធភាព**

**-ការកាត់បន្ថយពេលវេលានិងចំណេញកម្លាំងពលកម្ម និង**

**-ការជួយបង្កើនផលចំណេញនិងថែរក្សាបរិស្ថាន។**

នៅក្នុងឱកាសនោះ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប ក៏បានចុះអនុស្សរណៈយោគយល់គ្នា (MOU) ជាមួយក្រុមហ៊ុនស្អាតផងដែរ៕

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន





ទិដ្ឋភាពក្នុងជំនួបពិភាក្សាការងារ និងថតរូបអនុស្សាវរីយ៍

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នាថ្ងៃចន្ទទី២៩ ខែកញ្ញា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានសមាគមអតីតយុទ្ធជនកម្ពុជា បានអញ្ជើញជាអធិបតីក្នុងមហាសន្និបាតវិសាមញ្ញតំណាងសមាគមអតីតយុទ្ធជនកម្ពុជាទូទាំងប្រទេស នៅទីស្តីការក្រសួងមហាផ្ទៃ។




❈នាថ្ងៃអាទិត្យ ទី១២ ខែតុលា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** បានអញ្ជើញទទួលព្រះរាជដំណើរយាងនិវត្តន៍របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** បន្ទាប់ពីព្រះអង្គបានយាងទៅកាន់ទីក្រុងប៉េកាំង ប្រទេសចិនដើម្បីពិនិត្យព្រះរាជសុខភាព។



❈នារសៀលថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមក្នុងពិធីបុណ្យគម្រប់ខួបមួយឆ្នាំនៃមរណភាពរបស់ឯកឧត្តម **ជា ចាន់តូ** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ និងជាអគ្គទេសាភិបាលកិត្តិយសធនាគារជាតិនៃកម្ពុជា។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នាព្រឹកថ្ងៃអង្គារ ទី៣០ ខែកញ្ញា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញគោរពវិញ្ញាណក្ខន្ធសព ឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ **មាឃ ផល** ម្តាយក្មេករបស់ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា នៅសង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។




❈នាព្រឹកថ្ងៃចន្ទ ទី១៣ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំ ដើម្បីត្រៀមលក្ខណៈចូលរួមមហាសន្និបាតលើកទី១៥១ នៃសហភាពអន្តរសភា (IPU-151) និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។



❈នាព្រឹកថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥ នៅអាកាសយានដ្ឋានអន្តរជាតិតេជោ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់សភាកម្ពុជាអញ្ជើញចូលរួមសន្និសីទគ្រឿងបរិក្ខារសមុទ្រពិភពលោកឆ្នាំ២០២៥ នៅទីក្រុងហ្វូចូវ ខេត្តហ្វូចៀន ប្រទេសចិន និងបន្តចូលរួមមហាសន្និបាតសហភាពអន្តរសភាលើកទី១៥១ (IPU-151) និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ពីថ្ងៃទី១៤-២៥ ខែតុលា ឆ្នាំ២០២៥។



❈នាព្រឹកថ្ងៃចន្ទ ទី២០ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា និងគណៈប្រតិភូសភាកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី២១៦ (216 session of the Governing Council ) នៃមហាសន្និបាតសហភាពអន្តរសភាលើកទី១៥១ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នារសៀលថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយឯកឧត្តម Nur Jazlan MOHAMED អនុប្រធានព្រឹទ្ធសភាម៉ាឡេស៊ី នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។



❈នាថ្ងៃអង្គារ ទី២១ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានទទួលជួបឯកឧត្តម Raffy Tulfo, ព្រឹទ្ធសមាជិកនៃព្រឹទ្ធសភាហ្វីលីពីន និងជាប្រធានគណៈកម្មាធិការស្តីពី ពលករទេសន្តរប្រវេសន៍ នៃព្រឹទ្ធសភាហ្វីលីពីន នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។



❈នាថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូសភាកម្ពុជាធ្វើមាតុភូមិនិវត្តន៍វិញ បន្ទាប់ពីអញ្ជើញចូលរួមសន្និសីទគ្រឿងបរិក្ខារសមុទ្រពិភពលោកឆ្នាំ២០២៥ នៅទីក្រុងហ្វូចូវ ខេត្តហ្វូចៀន ប្រទេសចិន និងចូលរួមមហាសន្និបាតសហភាពអន្តរសភាលើកទី១៥១ (IPU-151) និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។



❈នាថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខឡុនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកញ្ញា របស់ខុទ្ទកាល័យអនុប្រធានទី២ព្រឹទ្ធសភា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ



❈នារសៀលថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ដើម្បីពិនិត្យនិងពិភាក្សាពីវឌ្ឍនភាពការងាររបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ នៅចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។




❈នារសៀលថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា និងជាប្រធានក្រុមសមាជិកប្រចាំភូមិភាគទី១ បានដឹកនាំគណៈប្រតិភូក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ អញ្ជើញគោរពវិញ្ញាណក្ខន្ធសពឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ **មាឃ ផល** ម្ដាយក្មេករបស់ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា និងឯកឧត្តមបណ្ឌិត **ចែម វីឌ្យ៉ា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបុណ្យខួបគម្រប់៧ថ្ងៃ និង១០០ថ្ងៃ ដើម្បីឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធសពមហាឧបាសិកា **អ៊ុច ប្ញ** ម្ដាយក្មេកឯកឧត្តម **ខួន សុជាតិ** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ចាម នៅរាជធានីភ្នំពេញ។



❈នារសៀលថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានជួបពិភាក្សានិងសម្របសម្រួលឱ្យសមាគមកាហ្វេកម្ពុជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ក្រុមហ៊ុន នីលីដា និងអង្គការ CAPRED ធ្វើការជាមួយគ្នា ដើម្បីជំរុញការផលិតនិងការកែច្នៃកាហ្វេក្នុងស្រុកបន្ថែមសម្រាប់ផ្គត់ផ្គង់ទីផ្សារ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នារសៀលថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខ្ឡ្យុនា** អនុប្រធានទី២ព្រឹទ្ធសភា សមាជិក សមាជិកាព្រឹទ្ធសភានិងថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបុណ្យទក្ខិណានុប្បទានគម្រប់ខួប៧ថ្ងៃ ឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ **មាឃ ផល** ម្តាយក្មេករបស់ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខ្ឡ្យុនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំប្រចាំខែនិងបូកសរុបលទ្ធផលការងារចន្លោះសម័យប្រជុំលើកទី៣ និងទី៤ ជាមួយគណៈកម្មការទាំង១០ និងក្រុមភូមិភាគទាំង៨ របស់ព្រឹទ្ធសភា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខ្ឡ្យុនា** អនុប្រធានទី២ព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ នៅមណ្ឌប «ព្រះបរមរតនកោដ្ឋ» នាសួនច្បារខាងកើតវិមានឯករាជ្យ រាជធានីភ្នំពេញ។



❈នាថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខ្ឡ្យុនា** អនុប្រធានទី២ព្រឹទ្ធសភា អមដំណើរដោយឯកឧត្តមបណ្ឌិត **ចែម វីឌ្យ៉ា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរខួបលើកទី៦៨ នៃថ្ងៃបុណ្យជាតិ ប្រទេសម៉ាឡេស៊ី នៅ Shangri-La Phnom Penh៕



# គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា អញ្ជើញទស្សនកិច្ចឈ្វេងយល់ក្រុមហ៊ុន អេអាយ ហ្វាម

នាព្រឹកថ្ងៃសុក្រ ទី១៧ ខែតុលា ឆ្នាំ២០២៥ គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា (គណៈកម្មការទី២) ដឹកនាំដោយឯកឧត្តម **យស ផានីត្ថា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញទស្សនកិច្ចក្រុមហ៊ុន អេអាយ ហ្វាម (AI FARM ROBOTICS) ក្រោមការទទួលស្វាគមន៍ពីលោកជំទាវ **ហោខ ស្រីស** អគ្គនាយិកាក្រុមហ៊ុន អេអាយ ហ្វាម ដែលមានទីតាំងស្ថិតក្នុងសង្កាត់ព្រែស ខណ្ឌដង្កោ រាជធានីភ្នំពេញ។

ឯកឧត្តម **យស ផានីត្ថា** ប្រធានគណៈកម្មការ បានជម្រាបអំពីគោលបំណងរបស់គណៈកម្មការដែលអញ្ជើញទស្សនកិច្ច គឺជាចំណុចចាប់ផ្តើមនៃការស្គាល់គ្នា ហើយអាចឈានទៅធ្វើការរួមគ្នានាពេលខាងមុខ និងស្វែងយល់អំពីបេសកកម្ម ចក្ខុវិស័យ សក្តានុពល និងផែនការនាពេលអនាគតរបស់ក្រុមហ៊ុន ដោយផ្តោតលើបញ្ញាសិប្បនិម្មិត (AI) វិស្វកម្ម និងវិទ្យាសាស្ត្រឌីជីថល។

**ឯកឧត្តមប្រធាន** ក៏បានជម្រាបអំពីតួនាទីនិងភារកិច្ចរបស់ព្រឹទ្ធសភា គណៈកម្មការជំនាញទាំង១០ និងគណៈកម្មការទី២ព្រឹទ្ធសភាផងដែរ។



*ទិដ្ឋភាពក្នុងជំនួបជាមួយក្រុមហ៊ុន អេអាយ ហ្វាម*

ក្នុងឱកាសនោះ លោកជំទាវ **ហោខ ស្រីស** អគ្គនាយិកាក្រុមហ៊ុន អេអាយ ហ្វាម បានស្វាគមន៍និងជម្រាបជូនគណៈប្រតិភូអំពីក្រុមហ៊ុន AI FARM ដែលបានបង្កើតឡើងក្នុងឆ្នាំ២០២១ ហើយជាក្រុមហ៊ុនបច្ចេកវិទ្យាដំបូងបង្អស់របស់កម្ពុជា ដែលផ្តោតលើគ្រឿងយន្តរ៉ូបូត បញ្ញាសិប្បនិម្មិត (AI-based robotics) និងស្វ័យប្រវត្តិកម្ម (automation) និងបច្ចេកវិទ្យាដ្រូន ដោយមានចក្ខុវិស័យប្រែក្លាយកម្ពុជាឱ្យក្លាយជាប្រទេសដែលពឹងផ្អែកលើបច្ចេកវិទ្យានាំមុខគេមួយក្នុងតំបន់ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ក្រុមហ៊ុនផ្តល់ជូននូវដំណោះស្រាយ ៣ផ្នែកធំៗ រួមមាន៖ **១**-ផ្នែកផលិតផលក្រុមហ៊ុនបានបង្កើតនិងផលិតដោយផ្ទាល់នូវរ៉ូបូតឧស្សាហកម្ម រ៉ូបូតសេវាកម្មពាណិជ្ជកម្ម ដ្រូន (UAV) រួមទាំងការផលិតបន្ទះឈីប (Board) **២**-ផ្នែកសេវាកម្មអាជីវកម្មនិងដំណោះស្រាយវិស្វកម្ម **៣**-ផ្នែកអប់រំក្រុមហ៊ុនបានចូលរួមចំណែកយ៉ាងសកម្ម









*គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា អញ្ជើញទស្សនកិច្ចក្រុមហ៊ុន អេអាយ ហ្វាម*

ក្នុងការបង្កើតធនធានមនុស្សជំនាន់ក្រោយ តាមរយៈការផ្តល់នូវសេវាកម្មបង្រៀន STEM ការរៀបចំមន្ទីរពិសោធ STEM និងកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកវិទ្យា AI/Robotics។

ក្រោយពីការខិតខំព្យាយាមអស់រយៈពេលជាច្រើនឆ្នាំមកនេះ ក្នុងឆ្នាំ២០២៥ ក្រុមហ៊ុនទទួលបានផ្លែផ្កាជាវិជ្ជមានគួរឱ្យកត់សម្គាល់និងទទួលបានការគាំទ្រជាបន្តបន្ទាប់ ដោយបានចុះកិច្ចព្រមព្រៀងស្តីពី កិច្ចសហប្រតិបត្តិការជាដៃគូយុទ្ធសាស្ត្រជាមួយស្ថាប័នធំៗ ទាំងរដ្ឋនិងឯកជនជាច្រើន។

មុននឹងបញ្ចប់ គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា បានផ្តល់នូវយោបល់មួយចំនួនលើផ្នែកដឹកនាំគ្រប់គ្រង ផ្សព្វផ្សាយ បទពិសោធនៅប្រទេសនានា និងការធ្វើផែនការអាជីវកម្ម ជាពិសេសជំរុញ និងលើកទឹកចិត្តដល់ថ្នាក់ដឹកនាំក្រុមហ៊ុនឱ្យខិតខំប្រឹងប្រែងបន្តទៀត ដើម្បីជាប្រយោជន៍សម្រាប់សង្គមជាតិទាំងមូល៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ ជាមួយក្រុមហ៊ុន អេអាយ ហ្វាម*

# គណៈប្រតិភូព្រឹទ្ធសភា អញ្ជើញសួរសុខទុក្ខនិងនាំយកអំណោយ គ្រឿងឧបភោគ បរិភោគ សម្ភារៈប្រើប្រាស់ ជូនវីរកងទ័ពជួរមុខ នៅបញ្ជាការដ្ឋានកងពលតូចអន្តរាគមន៍លេខ៩ និងកងវរសេនាតូចលេខ៣៩៤

នាព្រឹកថ្ងៃសៅរ៍ ទី១៨ ខែតុលា ឆ្នាំ២០២៥ គណៈប្រតិភូគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី នៃព្រឹទ្ធសភា (គណៈកម្មការទី៨) និងក្រុមសមាជិកាព្រឹទ្ធសភា ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការ និងជាប្រធានក្រុមសមាជិកា និងមានការយាងចូលរួមពី សម្តេចរាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងជាសមាជិកាព្រឹទ្ធសភា បានយាងនិងអញ្ជើញចុះសួរសុខទុក្ខ និងនាំយកព្រះរាជអំណោយថ្នាំពេទ្យ អំណោយជាគ្រឿងឧបភោគ បរិភោគ សម្ភារៈប្រើប្រាស់ជូនវីរកងទ័ពជួរមុខ នៅបញ្ជាការដ្ឋានកងពលតូចអន្តរាគមន៍លេខ៩ និងកងវរសេនាតូចលេខ៣៩៤ ខេត្តព្រះវិហារ។



*លោកជំទាវ មាន សំអាន ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា*

ក្នុងឱកាសនោះ **លោកជំទាវប្រធាន** បាននាំយកនូវប្រសាសន៍ផ្តាំផ្ញើសួរសុខទុក្ខនិងក្តីបារម្ភខ្ពស់បំផុតរបស់ **សម្តេចតេជោប្រធានព្រឹទ្ធសភា ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** និង**ឯកឧត្តមបណ្ឌិត អនុប្រធានទី២ព្រឹទ្ធសភា** ដែលតែងតែយកចិត្តទុកដាក់ចំពោះសុខទុក្ខរបស់កងទ័ពនិងក្រុមគ្រួសារយុទ្ធជនគ្រប់រូប។

**លោកជំទាវប្រធាន** បានមានប្រសាសន៍ថា ចំពោះមុខភាពគឃ្លើននៃការឈ្លានពានរបស់ថៃមកលើបូរណភាពទឹកដីកម្ពុជា បានបង្ហាញឱ្យឃើញអំពីឫសគល់និងស្ថានភាពពិតនៃជម្លោះព្រំដែន ការព្យាយាមអត់ធ្មត់និងការប្រកាន់គោលជំហររបស់កម្ពុជា ក្នុងការដោះស្រាយជម្លោះដោយសន្តិវិធី អនុលោមតាមច្បាប់អន្តរជាតិ និងបានស្នើអន្តរជាតិជួយអន្តរាគមន៍ទប់ស្កាត់ការពង្រីកជម្លោះរបស់ភាគីថៃនិងជំរុញអនុវត្តនូវបទឈប់បាញ់ដែលបានព្រមព្រៀងគ្នា ដើម្បីអាចវិលទៅរកប្រក្រតីភាពនៃទំនាក់ទំនងឡើងវិញ។





*គណៈប្រតិភូព្រឹទ្ធសភា អញ្ជើញសួរសុខទុក្ខបញ្ជាការដ្ឋានកងពលតូចអន្តរាគមន៍លេខ៩ និងកងវរសេនាតូចលេខ៣៩៤*



*សម្តេចរាជបុត្រីព្រះអនុជ នរោត្តម អរុណរស្មី ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ*

ជាមួយគ្នានោះ **លោកជំទាវប្រធាន** បានសម្តែងនូវការដឹងគុណវីរកងទ័ពជួរមុខដ៏អង់អាចក្លាហានទាំងអស់ដែលបានខិតខំតស៊ូការពារបូរណភាពទឹកដីជូនជាតិ មាតុភូមិ និងប្រជាពលរដ្ឋ និងបានថ្លែងនូវការគោរពនិងកោតសរសើរយ៉ាងជ្រាលជ្រៅបំផុតចំពោះវីរភាពដឹកនាំប្រកបដោយភាពវាងវៃ និងមនសិការស្នេហាជាតិដ៏ស្មោះសរខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចតេជោប្រធានព្រឹទ្ធសភា** និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចធិបតីនាយករដ្ឋមន្ត្រី** ដែលមានភាពប៉ិនប្រសប់ក្នុងការដឹកនាំ គ្រប់គ្រងសភាពការណ៍របស់ប្រទេសជាតិ និងតែងតែស្ថិតនៅរួមសុខរួមទុក្ខជាមួយប្រជាពលរដ្ឋគ្រប់កាលៈទេសៈទាំងអស់។

ព្រះរាជអំណោយថ្នាំពេទ្យ អំណោយជាគ្រឿងឧបភោគ បរិភោគ សម្ភារៈប្រើប្រាស់ជូនវីរកងទ័ពជួរមុខ គឺជាព្រះរាជទានដ៏ថ្លៃថ្លាបំផុតរបស់ សម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត **ឯកឧត្តមបណ្ឌិតអនុប្រធានទី២ព្រឹទ្ធសភា** គណៈកម្មការទី៨ព្រឹទ្ធសភា និងក្រុមសមាជិកាព្រឹទ្ធសភា។ បន្ថែមពីនេះ គណៈប្រតិភូក៏បានឧបត្ថម្ភថវិកាមួយចំនួន ជូនបញ្ជាការដ្ឋានកងពលតូចអន្តរាគមន៍លេខ៩ និងកងវរសេនាតូចលេខ៣៩៤ ផងដែរ។

បន្ទាប់មកនៅរសៀលថ្ងៃដដែល គណៈប្រតិភូបានយាងនិងអញ្ជើញសួរសុខទុក្ខ និងឧបត្ថម្ភថវិកាមួយចំនួនជូនដល់អ្នកជំងឺដែលកំពុងសម្រាកព្យាបាល ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន និងនាំយកព្រះរាជអំណោយថ្នាំពេទ្យជូនមណ្ឌលសុខភាពគូលែន ស្ថិតក្នុងស្រុកគូលែន ខេត្តព្រះវិហារ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*គណៈប្រតិភូព្រឹទ្ធសភា អញ្ជើញសំណេះសំណាលជាមួយវីរកងទ័ពនៃបញ្ជាការដ្ឋានកងពលតូចអន្តរាគមន៍លេខ៩ និងកងវរសេនាតូចលេខ៣៩៤*





*គណៈប្រតិភូព្រឹទ្ធសភា នាំយកអំណោយជូនបញ្ជាការដ្ឋានកងពលតូចអន្តរាគមន៍លេខ៩ និងកងវរសេនាតូចលេខ៣៩៤*

# គណៈកម្មការទី៩ព្រឹទ្ធសភា អញ្ជើញទស្សនកិច្ចឈ្វេងយល់អំពីវិស័យរបស់ខ្លួន នៅអាកាសយានដ្ឋានអន្តរជាតិតេជោ និងវិទ្យាស្ថានបណ្ដុះបណ្ដាលចំនួន៤




*គណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភា អញ្ជើញទស្សនកិច្ចអាកាសយានដ្ឋានអន្តរជាតិតេជោ*

នៅចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ព្រឹទ្ធសភា នីតិកាលទី៥ គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៃព្រឹទ្ធសភា (គណៈកម្មការទី៩) ដឹកនាំដោយឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការ បានអញ្ជើញទស្សនកិច្ចឈ្វេងយល់អំពីវិស័យរបស់គណៈកម្មការ នៅអាកាសយានដ្ឋានអន្តរជាតិតេជោ, វិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, វិទ្យាស្ថានតេជោសែន សាធារណការ និងដឹកជញ្ជូន, វិទ្យាស្ថានបណ្ដុះបណ្ដាលពាណិជ្ជកម្ម និងស្រាវជ្រាវ និងវិទ្យាស្ថានអភិបាលកិច្ចឌីជីថល នាថ្ងៃទី២៦ ខែកញ្ញា និងថ្ងៃទី១ ទី២ ខែតុលា ឆ្នាំ២០២៥ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារដែលអាកាសយានដ្ឋាននិងវិទ្យាស្ថានសម្រេចបានពាក់ព័ន្ធនឹងគោលនយោបាយ យុទ្ធសាស្ត្រ ការបណ្ដុះបណ្ដាលជំនាញ បញ្ហាប្រឈម និងដំណោះស្រាយ ព្រមទាំងទិសដៅនិងផែនការសកម្មភាព។





*គណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភា ជួបជាមួយវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍*

នៅគ្រប់ទីកន្លែងដែលគណៈប្រតិភូបានអញ្ជើញទស្សនកិច្ច តំណាងអាកាសយានដ្ឋាន និងវិទ្យាស្ថាន បានជម្រាបជូនគណៈប្រតិភូជ្រាប អំពីសមិទ្ធផលការងារដែលសម្រេចបាន បញ្ហាប្រឈម និងដំណោះស្រាយ ព្រមទាំងធ្វើបទបង្ហាញស្ដីពី ដំណើរការការងារសំខាន់ៗរបស់វិទ្យាស្ថាន មានជាអាទិ៍៖ ១-សាវតារអំពីវិទ្យាស្ថាន ២-អង្គការលេខ និងតួនាទីភារកិច្ច ៣-អំពីកម្មវិធីសិក្សា និងការបណ្ដុះបណ្ដាល ៤-លិខិតបទដ្ឋានគតិយុត្តរបស់វិទ្យាស្ថាន ៥-កិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិ។

បន្ទាប់ពីបានស្ដាប់សេចក្ដីរាយការណ៍យ៉ាងក្បោះក្បាយរួចមក ក្នុងនាមគណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភា **ឯកឧត្តមប្រធាន** បាននាំយកប្រសាសន៍ផ្ដាំផ្ញើសួរសុខទុក្ខ និងជូនពរសព្ទសាធុការពីសំណាក់សម្ដេចអគ្គមហា-

សេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី, ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា និងឯកឧត្តមបណ្ឌិត **ធន់ ខឡូនា** អនុប្រធានទី២ព្រឹទ្ធសភា ជូនចំពោះថ្នាក់ដឹកនាំនិងមន្ត្រីរាជការ នៃក្រសួង ស្ថាប័នទាំងអស់ដោយក្តីនឹករលឹក។




*គណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភា អញ្ជើញទស្សនកិច្ចវិទ្យាស្ថានតេជោសែន សាធារណការ និងដឹកជញ្ជូន*

ទន្ទឹមនឹងនោះ **ឯកឧត្តមប្រធាន** បានសម្តែងនូវការគាំទ្រនិងការកោតសរសើរ ព្រមទាំងលើកទឹកចិត្តដល់ថ្នាក់ដឹកនាំនិងសហការីនៃអាកាសយានដ្ឋាន និងវិទ្យាស្ថាន ដើម្បីដឹកនាំនិងអភិវឌ្ឍអង្គភាពឱ្យកាន់តែរីកចម្រើនឡើងថែមទៀតស្របតាមការអនុវត្តតាមក្របខ័ណ្ឌគោលនយោបាយ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។




*គណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភា ជួបជាមួយវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ*

សូមបញ្ជាក់ថា អាកាសយានដ្ឋានអន្តរជាតិតេជោ ស្ថិតក្រោមរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, វិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្ថិតក្រោមក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, វិទ្យាស្ថានតេជោសែន សាធារណការនិងដឹកជញ្ជូន ស្ថិតក្រោមក្រសួងសាធារណការនិងដឹកជញ្ជូន, វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្មនិងស្រាវជ្រាវ ស្ថិតក្រោមក្រសួងពាណិជ្ជកម្ម និងវិទ្យាស្ថានអភិបាលកិច្ចឌីជីថល ស្ថិតក្រោមក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន




*គណៈកម្មការទី៩ព្រឹទ្ធសភា អញ្ជើញទស្សនកិច្ចវិទ្យាស្ថានអភិបាលកិច្ចឌីជីថល*

# គណៈកម្មការទី១០ព្រឹទ្ធសភា ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយសមាគមពេទ្យព្យាបាលដោយចលនាកម្ពុជា

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី២៥ ខែកញ្ញា ឆ្នាំ២០២៥ គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ នៃព្រឹទ្ធសភា(គណៈកម្មការទី១០)ដឹកនាំដោយឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការ បានអនុញ្ញាតឱ្យគណៈប្រតិភូសមាគមពេទ្យព្យាបាលដោយចលនាកម្ពុជា ដឹកនាំដោយលោក **ហៀម ហឿង** ប្រធាននិងឯកឧត្តម **សុខ សំណាង** ប្រធានកិត្តិយស ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



*ឯកឧត្តម ម៉ម ប៊ុននាង ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា*

ក្នុងឱកាសជំនួបពិភាក្សាការងារនោះ **ឯកឧត្តមប្រធាន**បានថ្លែងស្វាគមន៍យ៉ាងកក់ក្តៅចំពោះគណៈប្រតិភូ និងបានជម្រាបអំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសការបំពេញមុខងារស្នូលរបស់គណៈកម្មការទី១០ ដែលរួមមាន មុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារព័ត៌មាន ព្រមទាំងសមិទ្ធផលនៃការបំពេញមុខងារសហប្រតិបត្តិការជាមួយអង្គការ សមាគមជាតិនិងអន្តរជាតិ។

ឯកឧត្តមប្រធានគណៈកម្មការ បានគូសបញ្ជាក់ថា ក្រោមការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពរបស់ឯកឧត្តម **សុខ សំណាង** ប្រធានកិត្តិយសនៃសមាគមគ្រូពេទ្យព្យាបាលដោយចលនាកម្ពុជា គណៈកម្មការទី១០ព្រឹទ្ធសភា បានចុះអនុស្សរណៈនៃការយោគយល់ជាមួយមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ ដើម្បីទទួលអំណោយមនុស្សធម៌ផ្នែកសុខាភិបាល ដែលរួមមានឱសថ ឧបករណ៍វេជ្ជសាស្ត្រ និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ ក្នុងទំហំទឹកប្រាក់ប្រមាណជា ៥០លានដុល្លារអាម៉េរិក ដែលអនុវត្តសម្រាប់រយៈពេល៥ឆ្នាំ (២០២៥-២០២៩)។ ជំនួយមនុស្សធម៌ខាងលើនេះ ត្រូវបានគ្រប់គ្រងនិងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

ក្នុងឱកាសនោះ លោក **ហៀម ហឿង** ប្រធានសមាគមពេទ្យព្យាបាលដោយចលនាកម្ពុជា បានធ្វើសេចក្តីរាយការណ៍ដោយសង្ខេបអំពីសាវតារនិងសមិទ្ធផលនានារបស់សមាគមថា សមាគមពេទ្យព្យាបាលដោយចលនាកម្ពុជាត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៤ ហើយទទួលស្គាល់ជាផ្លូវការដោយក្រសួងមហាផ្ទៃនៅឆ្នាំ១៩៩៧ និងបានក្លាយជាសមាជិករបស់សមាគម





*គណៈកម្មការទី១០ព្រឹទ្ធសភា និងសមាគមពេទ្យព្យាបាលដោយចលនាកម្ពុជា*





*គណៈកម្មការទី១០ព្រឹទ្ធសភា និងសមាគមពេទ្យព្យាបាលដោយចលនាកម្ពុជា*

ពេទ្យព្យាបាលដោយចលនាពិភពលោក ដែលមានសមាជិក១២៧ប្រទេស នៅឆ្នាំ២០២៥នេះ។ ពាក់ព័ន្ធនឹងសមិទ្ធផលនាពេលកន្លងទៅ សមាគមបានសហការយ៉ាងជិតស្និទ្ធជាមួយដៃគូនិងអ្នកជំនាញការអន្តរជាតិ មានមកពីប្រទេសសិង្ហបុរី ជប៉ុន អូស្ត្រាលី និងអង់គ្លេស ដើម្បីធ្វើការអប់រំ បណ្តុះបណ្តាល ការផ្តល់សេវាសុខភាព និងស្តារលទ្ធភាពពលកម្ម និងការបង្ការជំងឺមិនឆ្លង ដល់និស្សិតពីថ្នាក់បរិញ្ញាបត្ររង ដល់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។

ក្នុងឱកាសនោះផងដែរ អង្គប្រជុំបានស្តាប់បទបង្ហាញរបស់លោកស្រីសាស្ត្រាចារ្យ **ស៊ីលៀ តាន់** អ្នកជំនាញការមកពីប្រទេសសិង្ហបុរី ស្តីពីសមិទ្ធផលនៃសហប្រតិបត្តិការជាមួយសមាគម ក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈព្យាបាលដោយចលនាដល់និស្សិតនាពេលកន្លងទៅ ព្រមទាំងវិធីបង្ការការដួលរបស់មនុស្សចាស់ និងការព្យាលបាលដោយចលនាដើម្បីស្តារលទ្ធភាពពលកម្ម។ ទន្ទឹមនឹងនេះ អង្គប្រជុំក៏បានស្តាប់បទបង្ហាញរបស់លោកស្រី **អេលីហ្សាបែត អេនដឺសុន** តំណាងសមាគមគ្រូពេទ្យព្យាបាលដោយចលនាពិភពលោក ស្តីពីពេទ្យព្យាបាលដោយចលនានៅទូទាំងពិភពលោក រួមទាំងកម្ពុជា និងបទបង្ហាញរបស់លោក **សុខ ចាន់ចំណាប់** ស្តីពីកម្មវិធី ACCESS 2 ក្នុងការគាំទ្រផ្នែកបរិយាបន្នពិការភាព ផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) និងផ្នែកស្តារលទ្ធភាពពលកម្ម។

ឯកឧត្តម **សុខ សំណាង** ប្រធានកិត្តិយសសមាគម បានបញ្ជាក់ថា សមាគមពេទ្យព្យាបាលដោយចលនាកម្ពុជា គឺជាសមាគមតំណាងវិជ្ជាជីវៈព្យាបាលដោយចលនាតែមួយគត់នៅកម្ពុជា ដើម្បីអភិវឌ្ឍវិជ្ជាជីវៈព្យាបាលដោយចលនា និងចូលរួមចំណែកក្នុងការផ្តល់សេវាស្តារលទ្ធភាពពលកម្ម ជូនប្រជាពលរដ្ឋឱ្យត្រឡប់មកប្រក្រតីភាពឡើងវិញ។

បន្ទាប់ពីបានស្តាប់បទបង្ហាញនិងពិភាក្សាយ៉ាងផុលផុស ឯកឧត្តម **ម៉ម ប៊ុននាង** បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះសកម្មភាពដ៏ថ្លៃថ្លានិងសមិទ្ធផលដ៏ធំធេងរបស់សមាគមគ្រូពេទ្យព្យាបាលដោយចលនាកម្ពុជា ជាពិសេសទទួលបាននូវកិច្ចសហការនិងការគាំទ្រពីលោកស្រីសាស្ត្រាចារ្យ **ស៊ីលៀ តាន់** និងលោកស្រី **អេលីហ្សាបែត អេនដឺសុន** និងលោក **សុខ ច័ន្ទចំណាប់**។ **ឯកឧត្តម** ជឿជាក់ថា សិស្សនិស្សិតនិងប្រជាពលរដ្ឋកម្ពុជា នឹងទទួលបាននូវចំណេះដឹងខ្ពស់និងការព្យាបាលដោយចលនា ប្រកបដោយគុណភាព សុវត្ថិភាព ប្រសិទ្ធភាព និងសមធម៌៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបពិភាក្សាការងារជាមួយសមាគមពេទ្យព្យាបាលដោយចលនាកម្ពុជា*

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ សហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ប្រទេសបារាំង ចុះពិនិត្យព្យាបាលជំងឺទូទៅដោយមិនយកកម្រៃ ជូនប្រជាពលរដ្ឋនៅខណ្ឌឫស្សីកែវ និងខណ្ឌពោធិ៍សែនជ័យ




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ សហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តប្រទេសបារាំង ពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋនៅខណ្ឌឫស្សីកែវ*

នាថ្ងៃទី២២ និងថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៥ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ (រាជធានីភ្នំពេញ) ដឹកនាំដោយ ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានក្រុម ឯកឧត្តមបណ្ឌិត **ចែម ទីឡាំ** លេខាធិការក្រុមនិងឯកឧត្តម **ខ៊ែត ចន្ថាទី** សមាជិកក្រុម តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិត **ធន់ ចឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ បានសហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគម (AMH) របស់ប្រទេសបារាំង អញ្ជើញចុះទៅពិនិត្យព្យាបាលជំងឺទូទៅដោយមិនយកកម្រៃជូនប្រជាពលរដ្ឋ នៅក្នុងសង្កាត់ច្រាំងចម្រេះទី២ ខណ្ឌឫស្សីកែវ និងសង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ក្នុងឱកាសនោះ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ បានពាំនាំនូវការផ្ដាំផ្ញើសាកសួរសុខទុក្ខពីសំណាក់ **សម្ដេចតេជោប្រធានព្រឹទ្ធសភា** ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ឯកឧត្តមបណ្ឌិត **ធន់ ចឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា ជូនថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់និងបងប្អូនប្រជាពលរដ្ឋទាំងពីរខណ្ឌ ព្រមទាំងបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ជាពិសេសអាជ្ញាធរខណ្ឌ និងក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគម (AMH) របស់ប្រទេសបារាំង ដែលបានជួយសម្របសម្រួល និងសហការយ៉ាងរលូនឱ្យមានពិធីពិនិត្យព្យាបាលជំងឺទូទៅដោយមិនយកកម្រៃពីប្រជាពលរដ្ឋ។



*ទិដ្ឋភាពពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋនៅខណ្ឌឫស្សីកែវ*

ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ បានគូសបញ្ជាក់ថា វិស័យសុខាភិបាល គឺជាវិស័យអាទិភាពមួយ ដែលរាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់រំកិលសេវាឱ្យ

ទៅកៀកជិតដល់មូលដ្ឋានរស់នៅរបស់ប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់សុខមាលភាព ដែលជាកត្តាចម្បងក្នុងការទទួលបាននូវសុខភាពល្អ និងការរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ លើសពីនេះ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ក៏បានជម្រាបជូនអំពីស្ថានភាពព្រំដែននៅពេលថ្មីៗនេះ និងបានផ្តាំផ្ញើដល់បងប្អូនប្រជា-ពលរដ្ឋ ដែលអញ្ជើញមកចូលរួមទាំងអស់ត្រូវខិតខំយកចិត្តទុកដាក់ថែរក្សាសុខភាពឱ្យបានល្អនិងត្រូវប្រើប្រាស់ថ្នាំតាមវេជ្ជបញ្ជារបស់គ្រូពេទ្យឱ្យបានទៀងទាត់ និងពិសាអាហារណាដែលមានអនាម័យ តមអាហារប្រៃនិងផ្អែមផងដែរ។



*ទិដ្ឋភាពពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋនៅខណ្ឌពោធិ៍សែនជ័យ*

ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ក៏បានកោតសរសើរចំពោះទឹកចិត្តដ៏ថ្លៃថ្លារបស់ក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគម (AMH) របស់ប្រទេសបារាំង ដែលបានមកពិនិត្យព្យាបាល ព្រមទាំងផ្តល់ថ្នាំជូនទៅតាមប្រភេទជំងឺ ក្នុងស្មារតីមនុស្សធម៌ ដែលស្តែងចេញពីទឹកចិត្តសប្បុរស ក្តីស្រឡាញ់ ព្យាបាលមិនប្រកាន់បក្សពួក ជាតិសាសន៍ សាសនា និងនិន្នាការនយោបាយ  ហើយសង្ឃឹមថា ក្រុមវេជ្ជបណ្ឌិតស្ម័គ្រចិត្តបារាំង នឹងបន្តធ្វើការងារមនុស្សធម៌ជូនប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជា ក៏ដូចជាចុះជួយនៅភូមិភាគទី១ បន្តទៀត និងគោរពជូនពរក្រុមវេជ្ជបណ្ឌិតស្ម័គ្រចិត្តបារាំង ជួបតែសំណាងល្អ និងជោគជ័យក្នុងបេសកកម្មរបស់ខ្លួនផងដែរ។

ជាលទ្ធផល ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ បានរៀបចំពិធីនេះឡើងមានរយៈពេលពេញពីរថ្ងៃ ដោយបានពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋក្នុងខណ្ឌទាំងពីរ សរុបចំនួន ៣៦៩នាក់ (ក្នុងនោះស្ត្រីចំនួន២០២នាក់ កុមារចំនួន១៧នាក់៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋនៅខណ្ឌពោធិ៍សែនជ័យ*



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ថតរូបអនុស្សាវរីយ៍ ជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តប្រទេសបារាំង*

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ អញ្ជើញជួបសំណេះសំណាល ជាមួយអាជ្ញាធរស្រុកឈូក ខេត្តកំពត

នាព្រឹកថ្ងៃអង្គារ ទី៣០ ខែកញ្ញា ឆ្នាំ២០២៥ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ (ខេត្តកំពត ខេត្តតាកែវ និង ខេត្តកែប) ដឹកនាំដោយឯកឧត្តម **ឈួន ឆាម** ប្រធានស្តីទីក្រុម បានអញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំស្រុក ក្រុមប្រឹក្សាឃុំ ស្មៀនឃុំនិងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ ស្រុកឈូក ខេត្តកំពត សរុបចំនួន១៣៦នាក់។



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥*

ក្នុងឱកាសនោះ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥និងអង្គពិធីទាំងមូលបានធ្វើការគោរពវិញ្ញាណក្ខន្ធចំពោះវីរយុទ្ធជនកម្ពុជា ដែលបានពលីជីវិតក្នុងបុព្វហេតុការពារជាតិមាតុភូមិ ពីការឈ្លានពានរបស់ថៃ។

ក្នុងពិធីសំណេះសំណាល **ឯកឧត្តមប្រធានស្តីទីក្រុម**បាននាំនូវការផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនចំពោះបងប្អូនថ្នាក់ដឹកនាំខេត្ត មន្ត្រីរាជការ កងកម្លាំងនៅមូលដ្ឋានគ្រប់លំដាប់ថ្នាក់និងប្រជាពលរដ្ឋក្នុងស្រុកឈូកនិងទីរួមខេត្តកំពត ប្រកបដោយក្តីនឹករលឹកបំផុត។ ឯកឧត្តមក៏បានជម្រាបជូនអង្គពិធីអំពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់ព្រឹទ្ធសភា ព្រមទាំងវឌ្ឍនភាពការងាររបស់ព្រឹទ្ធសភានីតិកាលទី៥និងសមិទ្ធផលសំខាន់ៗរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥។

ការរៀបចំពិធីសំណេះសំណាល គឺផ្តោតលើការអនុវត្តតួនាទី ភារកិច្ចរបស់អាជ្ញាធរមូលដ្ឋាន ជាពិសេសប្រមូលផ្តុំបញ្ហាប្រឈម តម្រូវការ និងសំណូមពរនានា ដើម្បីរួមគ្នារិះរកដំណោះស្រាយ រួមចំណែកលើកកម្ពស់ការអភិវឌ្ឍនៅមូលដ្ឋាន និងការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព ដើម្បីធានាបាននូវសុខសុវត្ថិភាពជូនប្រជាពលរដ្ឋឱ្យកាន់តែមានភាពល្អប្រសើរឡើង ព្រមទាំងគិតគូរអំពីសុខទុក្ខរបស់ក្រុមគ្រួសារកងទ័ព ក្រុមគ្រួសារយុទ្ធជនពលី របួស ពិការ ជនភៀសសឹក និងពលករខ្មែរវិលត្រឡប់ពីប្រទេសថៃវិញ។



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*

បន្ថែមពីនេះ ក្រុមភូមិភាគទី៥ ក៏បានជម្រាបជូនអំពីលទ្ធផលនៃសមាជរដ្ឋសភានិងព្រឹទ្ធសភានាពេលកន្លងទៅ ដែលបានអនុម័តលើប្រធានបទសំខាន់ចំនួន៣ គឺទី១-ប្រព័ន្ធគាំពារសង្គម ទី២-សេដ្ឋកិច្ចក្រៅប្រព័ន្ធ និងទី៣-វិស័យកសិកម្ម។ អង្គសមាជរដ្ឋសភានិងព្រឹទ្ធសភា គឺបានគាំទ្រ





*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*

ទាំងស្រុងនូវគោលនយោបាយទូទៅ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងកម្មវិធីគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ដែលជាគោលនយោបាយដ៏ត្រឹមត្រូវ ស្របនឹងស្ថានភាពសេដ្ឋកិច្ច និងសង្គមកម្ពុជាបច្ចុប្បន្ន និងទៅអនាគត។

ក្នុងឱកាសនោះផងដែរ **ឯកឧត្តមប្រធានស្ដីទីក្រុម** ក៏បានផ្ដាំផ្ញើដល់ថ្នាក់ដឹកនាំស្រុក ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ នៃស្រុកឈូក សូមបន្តយកចិត្តទុកដាក់អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវកិច្ចការថែរក្សាការពារសន្តិភាពក្នុងមូលដ្ឋាន បន្តបម្រើនិងផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព។ ក្រៅពីនេះ **ឯកឧត្តមប្រធានស្ដីទីក្រុម** បានជម្រាបនូវសភាពការណ៍វិវត្តថ្មីៗនៅព្រំដែនកម្ពុជា-ថៃ ដែលស្ថិតនៅក្នុងភាពស្រួចស្រាល ដោយសារកងកម្លាំងយោធាថៃ មិនគោរពបទឈប់បាញ់ឱ្យបានពេញលេញ តែងតែបង្កអរិភាពមកលើទឹកដីកម្ពុជាឥតឈប់ឈរ ហើយប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជា នៅតែប្រកាន់ជំហររក្សាសុខសន្តិភាព មិត្តភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍជាមួយប្រទេសជិតខាង ហើយប្តេជ្ញាដាច់ខាតការពារបូរណភាពទឹកដី មិនឱ្យបរទេសណាឈ្លានពានបានឡើយ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ថតរូបអនុស្សាវរីយ៍ ជាមួយអាជ្ញាធរស្រុកឈូក*

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ អញ្ជើញឈ្វេងយល់ អំពីសភាពការណ៍ថ្មីៗ នៅខេត្តពោធិ៍សាត់ និងខេត្តកោះកុង

នៅថ្ងៃទី២៩ និងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៥ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ (ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តកោះកុង ខេត្តពោធិ៍សាត់ និងខេត្តព្រះសីហនុ) ដឹកនាំដោយឯកឧត្តមបណ្ឌិត **ម៉ុង ឬទ្ធី** ប្រធានក្រុម បានអញ្ជើញជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខេត្តពោធិ៍សាត់ និងខេត្តកោះកុង ដើម្បីឈ្វេងយល់និងទទួលបានព័ត៌មានអំពីសភាពការណ៍ថ្មីៗពាក់ព័ន្ធផលប៉ះពាល់នៅក្នុងខេត្តដែលបណ្តាលមកពីសមរភូមិព្រំដែនកម្ពុជា-ថៃ ក្នុងក្របខ័ណ្ឌរបស់ខេត្ត ស្ថានភាពនៃប្រជាជនភៀសសឹក និងការដោះស្រាយរបស់អាជ្ញាធរខេត្តកន្លងមក ស្ថានភាពពលករត្រឡប់មកពីប្រទេសថៃ និងការជួយជ្រោមជ្រែង រួមទាំងការផ្តល់ការងារ ការជួយឧបត្ថម្ភគាំទ្រកងទ័ពសមរភូមិមុខ បញ្ហាប្រឈមផ្សេងៗទៀត និងការងារចំពោះមុខដែលត្រូវបន្តដោះស្រាយតាមសមត្ថកិច្ច និងតាមលទ្ធភាពជាក់ស្តែង ព្រមទាំងរៀបចំរបាយការណ៍អំពីលទ្ធផលនៃដំណើរចុះបំពេញការងារនៅខេត្តទាំងពីរនេះដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ។



*ឯកឧត្តមបណ្ឌិត ម៉ុង ឬទ្ធី ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧*

ក្នុងឱកាសចុះបំពេញបេសកកម្មនៅខេត្តទាំងពីរ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ បានអញ្ជើញជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខេត្តពោធិ៍សាត់  ដឹកនាំដោយឯកឧត្តម **ខូយ រីដា** អភិបាល នៃគណៈអភិបាលខេត្ត និងថ្នាក់ដឹកនាំខេត្តកោះកុង ដឹកនាំដោយលោកជំទាវ **ឈី ឆ៉ា** អភិបាល នៃគណៈអភិបាលខេត្ត ព្រមទាំងមានការចូលរួមពីក្រុមប្រឹក្សាខេត្ត កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ រួមជាមួយនឹងប្រធានមន្ទីរនិងអង្គភាពនានាជុំវិញខេត្ត។

បន្ទាប់ពីបានស្តាប់របាយការណ៍ និងពិភាក្សាគ្នាយ៉ាងល្អិតល្អន់ **ឯកឧត្តមបណ្ឌិតប្រធានក្រុម** បានវាយតម្លៃខ្ពស់ចំពោះប្រសិទ្ធភាពការងាររបស់ថ្នាក់ដឹកនាំខេត្ត អាជ្ញាធរគ្រប់ជាន់ថ្នាក់ និងបានអំពាវនាវដល់ប្រជាពលរដ្ឋត្រូវតស៊ូ អត់ធ្មត់ ត្រូវជឿទុកចិត្តទៅលើថ្នាក់ដឹកនាំរាជរដ្ឋាភិបាល និងវីរភាពដ៏អង់អាចក្លាហានរបស់វីរយុទ្ធជនយើង និងរួមសាមគ្គីគ្នាជាធ្លុងមួយឱ្យបានរឹងមាំក្នុងគ្រាដែលប្រទេសជាតិកំពុងជួបប្រទះការឈ្លានពានពីកងទ័ពថៃ។ជាមួយគ្នានោះ **ឯកឧត្តមបណ្ឌិត**





*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ ជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខេត្តពោធិ៍សាត់*




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ ជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខេត្តកោះកុង*

បានថ្លែងនូវការគោរពកោតសរសើរយ៉ាងជ្រាលជ្រៅចំពោះវីរភាពដឹកនាំប្រកបដោយមនសិការស្នេហាជាតិដ៏ស្មោះសរខ្ពង់ខ្ពស់បំផុតរបស់សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានិងសម្តេចធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលមានភាពប៉ិនប្រសប់ក្នុងការដឹកនាំគ្រប់គ្រងស្ថានការណ៍របស់ប្រទេសជាតិ និងតែងតែស្ថិតនៅរួមសុខរួមទុក្ខជាមួយប្រជាពលរដ្ឋគ្រប់កាលៈទេសៈ។

**ឯកឧត្តមបណ្ឌិត** បានអំពាវនាវដល់ថ្នាក់ដឹកនាំខេត្តទាំងពីរ សូមបន្តធ្វើការលើកទឹកចិត្តដល់ប្រជាពលរដ្ឋបន្តរក្សាស្មារតីសាមគ្គីភាព ឯកភាពជាតិ ការពារសន្តិភាព ដែលបានមកដោយលំបាកតាមរយៈការធ្វើពលិកម្មរបស់សម្តេចតេជោ **ហ៊ុន សែន** និងថ្លែងនូវការកោតសរសើរចំពោះទឹកចិត្តស្នេហាជាតិ សាមគ្គីភាពរបស់បងប្អូនប្រជាជនយើងដែលបានចូលរួមគាំទ្រជាសម្ភារៈ ស្បៀងអាហារ និងថវិកា ជូនដល់បងប្អូនជនភៀសសឹក និងវីរកងទ័ព ក្នុងកិច្ចការពារបូរណភាពទឹកដី និងអធិបតេយ្យភាពកម្ពុជាពីការឈ្លានពានរបស់ថៃ។

ក្នុងឱកាសនោះ **ឯកឧត្តមបណ្ឌិតប្រធានក្រុម** បានឧបត្ថម្ភថវិកាចំនួន៥ពាន់ដុល្លារអាម៉េរិក លោកជំទាវ **ម៉ែន ស៊ុន ម៉ុខឫទ្ធី** ឧបត្ថម្ភថវិកា១លានរៀលនិងសមាជិក សមាជិកាក្រុម៧រូបក្នុងមួយរូបៗ១លានរៀល សម្រាប់ចូលរួមក្នុងការសាងសង់លេណដ្ឋានជូនកងទ័ពឈរជើងជួរមុខនៅតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ខេត្តកោះកុង។

បន្ទាប់មកនៅថ្ងៃដដែលនោះ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ បានអញ្ជើញបន្តទស្សនកិច្ចពិនិត្យមើលសកម្មភាព នៅច្រកទ្វារព្រំដែនអន្តរជាតិចាំយាម និងពិនិត្យមើលវឌ្ឍនភាពតំបន់ទេសចរណ៍ សហគមន៍តំបន់ការពារធម្មជាតិពាមក្រសោប ស្ថិតក្នុងឃុំពាមក្រសោប ស្រុកមណ្ឌលសីមា ខេត្តកោះកុង៕

អត្ថបទ និងរូបភាពៈ នាយកដ្ឋានព័ត៌មាន




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ អញ្ជើញពិនិត្យមើលសកម្មភាព នៅច្រកទ្វារព្រំដែនអន្តរជាតិចាំយាម*

# កិច្ចប្រជុំគណៈកម្មការទាំង១០ ក្រុមភូមិភាគ និងក្រុមនានានៃព្រឹទ្ធសភា

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី២ព្រឹទ្ធសភា ចំនួន១លើក



នារសៀលថ្ងៃអង្គារទី៣០ ខែកញ្ញា ឆ្នាំ២០២៥ ឯកឧត្តម **យស ផានីត្តា** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-របាយការណ៍ប្រចាំខែ

២-ស្តាប់បទបង្ហាញរបស់ក្រុមហ៊ុនធុរវឌ្ឍន៍ស្តីពី គ្រីបតូ

៣-បញ្ហាផ្សេងៗ។

### ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី១) ចំនួន១លើក



នារសៀលថ្ងៃសុក្រ ទី១៧ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **យស ផានីត្តា** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី១) ដើម្បីពិនិត្យពិភាក្សា និងត្រៀមមានយោបល់ក្នុងសម័យប្រជុំលើកទី៤ ព្រឹទ្ធសភា នីតិកាលទី៥ លើសេចក្តីព្រាងច្បាប់ចំនួន៥ ស្តីពី៖

១-ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ក្របខ័ណ្ឌបទប្បញ្ញត្តិសុវត្ថិភាពម្ហូបអាហារអាស៊ាន

២-ការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងអាស៊ានស្តីពី បម្លាស់ទីរូបវន្តបុគ្គល

៣-ការអនុម័តយល់ព្រមលើពិធីសារទីមួយ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន

៤-ការអនុម័តយល់ព្រមលើពិធីសារទីពីរ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់

៥-ការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពី ការបង្កើតអង្គការអន្តរជាតិសម្រាប់សន្ទានកម្ម។

### ❈កិច្ចប្រជុំជាមួយតំណាងក្រសួង ចំនួន២លើក៖

ឯកឧត្តម **យស ផានីត្តា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារដូចខាងក្រោម៖



-ជួបពិភាក្សាការងារជាមួយតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដឹកនាំដោយឯកឧត្តមបណ្ឌិតសភាចារ្យ **ផាន់ ផល្លា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើប្រធានបទស្តីពី «ខឿនការពារជាតិប្រជាជន» ឃុំក្នុងភូមិសាស្ត្រ ខេត្តព្រះវិហារ ស្ទឹងត្រែង និងខេត្តរតនគិរី ជាប់ព្រំដែនឡាវ នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា នារសៀលថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៥។



-ជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំធនាគារជាតិ នៃកម្ពុជា ដឹកនាំដោយឯកឧត្តម **រ័ត្ន សុវណ្ណានរៈ** ទេសាភិបាលរងស្តីពី សាធនភាព នៅសាលប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា នាព្រឹកថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៥។

### ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី២) ចំនួន១លើក



នាព្រឹកថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **នាង ផាត** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី២) ដើម្បីពិនិត្យនិងត្រៀមមានយោបល់ក្នុងសម័យប្រជុំលើកទី៤ ព្រឹទ្ធសភា នីតិកាលទី៥ លើសេចក្តីព្រាងច្បាប់ចំនួន៥ ស្តីពី៖

១-ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ក្របខ័ណ្ឌបទប្បញ្ញត្តិសុវត្ថិភាពម្ហូបអាហារអាស៊ាន

២-ការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងអាស៊ានស្តីពី បម្លាស់ទីរូបវន្តបុគ្គល

៣-ការអនុម័តយល់ព្រមលើពិធីសារទីមួយ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន

៤-ការអនុម័តយល់ព្រមលើពិធីសារទីពីរ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់

៥-ការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពី ការបង្កើតអង្គការអន្តរជាតិសម្រាប់សន្ទានកម្ម។

### ❈គណៈកម្មការទី៤ព្រឹទ្ធសភា ជួបភ្ញៀវអន្តរជាតិ ចំនួន១លើក



នាព្រឹកថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **នាង ផាត** ប្រធានគណៈកម្មការ បានទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូនៃរដ្ឋសភាសាធារណរដ្ឋកូរ៉េ ដឹកនាំដោយឯកឧត្តម **គីម ឃ្យុងហោ** សមាជិករដ្ឋសភា និងជាប្រធានក្រុមការងារការពារជនជាតិកូរ៉េនៅក្រៅប្រទេស នៃគណបក្សប្រជាធិបតេយ្យកូរ៉េ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៥ព្រឹទ្ធសភា ចំនួន៦លើក៖

ឯកឧត្តមបណ្ឌិត **ចែម វីឡា** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖



-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ នាព្រឹកថ្ងៃទី១ ខែតុលា ឆ្នាំ២០២៥ ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-បូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំខែកញ្ញា និងនព្វមាស ឆ្នាំ២០២៥

២-បញ្ហាផ្សេងៗ។

-កិច្ចប្រជុំផ្ទៃក្នុងជាមួយក្រុមជំនួយការគណៈកម្មការ នាថ្ងៃទី៧ ទី១៤ និងទី១៧ ខែតុលា ឆ្នាំ២០២៥ នៅបន្ទប់បណ្ណាល័យគណៈកម្មការទី៥ព្រឹទ្ធសភា ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-សេចក្តីព្រាងច្បាប់ចំនួន៥ ដែលរដ្ឋសភាបញ្ជូនមកព្រឹទ្ធសភានាពេលខាងមុខ

២-បញ្ហាផ្សេងៗ។

-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ នាព្រឹកថ្ងៃទី៩ ខែតុលា



ឆ្នាំ២០២៥ ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី៖

១-ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ក្របខ័ណ្ឌ

បទប្បញ្ញត្តិសុវត្ថិភាពម្ហូបអាហារអាស៊ាន

២-ការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងអាស៊ានស្តីពី បម្លាស់ទីរូបវន្តបុគ្គល

៣-ការអនុម័តយល់ព្រមលើពិធីសារទីមួយ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន

៤-ការអនុម័តយល់ព្រមលើពិធីសារទីពីរ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់

៥-ការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពី ការបង្កើតអង្គការអន្តរជាតិសម្រាប់សន្ទានកម្ម។

**❈កិច្ចប្រជុំជាមួយគណៈកម្មការនានា ចំនួន១លើក**



នារសៀលថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ចែម វីរ៉ា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំជាមួយឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា ដើម្បីត្រៀមរបាយការណ៍និងពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ចំនួន៥ ជាសមត្ថកិច្ចរបស់គណៈកម្មការទាំងពីរ នៅសាលប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា។

**❈កិច្ចប្រជុំអន្តរគណៈកម្មការ ចំនួន១លើក**



នាព្រឹកថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ចែម វីរ៉ា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំអន្តរគណៈកម្មការជាមួយតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយលោកជំទាវ **ចម និម្មល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងសហការី នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងស្តីពីៈ

១-ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ក្របខ័ណ្ឌបទប្បញ្ញត្តិសុវត្ថិភាពម្ហូបអាហារអាស៊ាន

២-ការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងអាស៊ានស្តីពី បម្លាស់ទីរូបវន្តបុគ្គល

៣-ការអនុម័តយល់ព្រមលើពិធីសារទីមួយ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន

៤-ការអនុម័តយល់ព្រមលើពិធីសារទីពីរ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់

៥-ការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពី ការបង្កើតអង្គការអន្តរជាតិសម្រាប់សន្ទានកម្ម។

**❈គណៈកម្មការទី៥ព្រឹទ្ធសភា ជួបភ្ញៀវជាតិនិងអន្តរជាតិ ចំនួន២លើកៈ**

ឯកឧត្តមបណ្ឌិត **ចែម វីរ៉ា** ប្រធានគណៈកម្មការ បានទទួលជួបភ្ញៀវអន្តរជាតិដូចខាងក្រោមៈ

-ទទួលជួបលោកឧកញ៉ា **ឌិន សុមេធារិទ្ធ** ប្រធានសហព័ន្ធទេសចរណ៍កម្ពុជា និងលោក Jean Paul Vogels នៅគណៈកម្មការទី៥ព្រឹទ្ធសភា នាព្រឹកថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៥។

-ទទួលជួបលោក Buon TAN នៅគណៈកម្មការទី៥ព្រឹទ្ធសភា នារសៀលថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៥។

**❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៧ព្រឹទ្ធសភា ចំនួន២លើកៈ**

-នាព្រឹកថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម



**ឈិត សុខុន** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យនិងពិភាក្សាលើរបាយការណ៍ស្តីពីលទ្ធផលការងាររបស់គណៈកម្មការប្រចាំខែតុលា និង



ទិសដៅការងារ ខែវិច្ឆិកា ឆ្នាំ២០២៥ និងបញ្ហាផ្សេងៗ។

-នាព្រឹកថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងជាមួយមន្ត្រីការិយាល័យជំនួយការ ដើម្បីពិនិត្យតាមដានព័ត៌មានអំពីវឌ្ឍនភាពការងារធម្មការ និងសាសនា ក្នុងការរួមចំណែកថែរក្សាសន្តិភាព និងការរួបរួមសាមគ្គីគ្នាការពារអធិបតេយ្យជាតិ បូរណភាពទឹកដី។

**❋កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៨ព្រឹទ្ធសភា ចំនួន១លើក**



នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-របាយការណ៍សកម្មភាពនិងលទ្ធផលការងាររបស់គណៈកម្មការប្រចាំខែកញ្ញា ឆ្នាំ២០២៥ និងទិសដៅខែតុលា ឆ្នាំ២០២៥

២-របាយការណ៍បូកសរុបសកម្មភាពនិងលទ្ធផលការងាររបស់គណៈកម្មការ នៅចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ ព្រឹទ្ធសភានីតិកាលទី៥

៣-បញ្ហាផ្សេងៗ។

**❋កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៩ព្រឹទ្ធសភា ចំនួន១លើក**

នាថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី៖



១-ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ក្របខ័ណ្ឌបទប្បញ្ញត្តិសុវត្ថិភាពម្ហូបអាហារអាស៊ាន

២-ការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងអាស៊ានស្តីពី បម្លាស់ទីរូបវន្តបុគ្គល

៣-ការអនុម័តយល់ព្រមលើពិធីសារទីមួយធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន

៤-ការអនុម័តយល់ព្រមលើពិធីសារទីពីរធ្វើវិសោធនកម្មកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់

៥-ការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពី ការបង្កើតអង្គការអន្តរជាតិសម្រាប់សន្ធានកម្ម។

**❋កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៥) ចំនួន១លើក**



នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៥) នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីពិនិត្យនិងត្រៀមមានយោបល់ក្នុងសម័យប្រជុំលើកទី៤ ព្រឹទ្ធសភានីតិកាលទី៥ លើសេចក្តីព្រាងច្បាប់ចំនួន៥ស្តីពី៖

១-ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ក្របខ័ណ្ឌបទប្បញ្ញត្តិសុវត្ថិភាពម្ហូបអាហារអាស៊ាន

២-ការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងអាស៊ានស្តីពី បម្លាស់ទីរូបវន្តបុគ្គល

៣-ការអនុម័តយល់ព្រមលើពិធីសារទីមួយ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន

៤-ការអនុម័តយល់ព្រមលើពិធីសារទីពីរ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់

៥-ការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពី ការបង្កើតអង្គការអន្តរជាតិសម្រាប់សន្ទានកម្ម។

**❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី១០ព្រឹទ្ធសភា ចំនួន១លើក**

នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យនិងសម្រេចលើសេចក្តីព្រាងរបាយការណ៍ស្តីពីសកម្មភាពលទ្ធផលការងារប្រចាំខែតុលា របស់គណៈកម្មការ និងលើកទិសដៅការងារបន្ត៕



## ការទទួលពាក្យបណ្តឹង

❈ក្នុងខែតុលា ឆ្នាំ២០២៥ គណៈកម្មការទី១ព្រឹទ្ធសភា បានទទួលពាក្យបណ្តឹងចូលចំនួន៧បណ្តឹង បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធចំនួន៧បណ្តឹង កំពុងពិនិត្យសិក្សាចំនួន៦បណ្តឹង តម្កល់ទុកមិនចាត់ការចំនួន២បណ្តឹង ធ្វើលិខិតរំលឹកជំរុញការដោះស្រាយចំនួន២បណ្តឹង ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹងចំនួន១១បណ្តឹង ទទួលឯកសារជូនជ្រាបពីក្រសួងស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការចំនួន៨បណ្តឹង៕

## សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស



❈ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **យស ផានីត្តា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមសន្និសីទសមាជិកសភាស្តីពីការអប់រំសម្រាប់ជីវិត សុវត្ថិភាព និងសេចក្តីថ្លៃថ្នូររបស់មនុស្ស (The Asian Population and Development Association-APDA) នៅទីក្រុងតូក្យូ ប្រទេសជប៉ុន។

❈កាលពីថ្ងៃទី២៣ ខែសីហា ដល់ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៥ សម្តេចរាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានយាងអមព្រះរាជដំណើរព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទៅគង់ប្រថាប់ពិនិត្យព្រះរាជសុខភាពនៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន។

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារ នៅតាមបណ្ដាភូមិភាគទាំង៨



❋នាថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ខិ ច័ន្ទ្រផល** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា ឯកឧត្តម **ម៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា ឯកឧត្តមសន្តិបណ្ឌិត **តេង សាវឌ្ឍ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តមបណ្ឌិត **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីសំណេះសំណាលនិងចែកម៉ូតូជូនសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនិទ្ទេសA ចំនួន១៥៥នាក់ ឆ្នាំសិក្សា២០២៤-២០២៥ ក្នុងខេត្តបាត់ដំបង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅសាលមហោស្រពស្ទឹងសង្កែ ខេត្តបាត់ដំបង។

❋ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងដឹកនាំក្រុមការងារ ចុះពិនិត្យមើលការជួសជុលផ្លូវ ដើម្បីបម្រើសេចក្ដីត្រូវការដល់កម្មករ និងប្រជាពលរដ្ឋ នៅភូមិមហាលំពាំងទី១ ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៥។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋជាកសិករកំពុងធ្វើចំការស្រែ នៅភូមិព្រៃខ្យាំ ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៥។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋអញ្ជើញមកសម្រាកកម្សាន្ត នៅរូបសំណាកដំរី៥០៥ក្បាល និងស្ពានខ្ពស់ជាងគេ នៃព្រះរាជាណាចក្រកម្ពុជា នៅស្រុកវាលវែង ខេត្តពោធិ៍សាត់ នាព្រឹកថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៥។

-ដឹកនាំក្រុមការងារបច្ចេកទេសចុះពិនិត្យមើលក្រុមការងារគ្រឿងចក្រចាប់ផ្ដើមបើកការដ្ឋាន សាងសង់គ្រឹះផ្លូវក្រាលគ្រួសក្រហមប្រវែង៤.៨០០ម៉ែត្រ នៅភូមិស្វាយដង្គុំ ឃុំស្ពុះ ព្រមទាំងបានអញ្ជើញមកទទួលដំណើរទស្សនកិច្ចសិក្សារបស់លោកគ្រូ អ្នកគ្រូ ចំនួន១៣២នាក់មកពីវិទ្យាល័យកំពង់ធំ ដើម្បីទស្សនកិច្ចសិក្សាស្វែងយល់ពីការអភិវឌ្ឍលើវិស័យកសិកម្ម កសិ-ទេសចរណ៍ ដំណាំឈើហូបផ្លែ ពិនិត្យហេដ្ឋារចនាសម្ព័ន្ធដែលបានស្ថាបនា ទស្សនាសួនសត្វ និងជិះឡូរីកម្សាន្តនៅក្នុងតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅភូមិសំរោងជើងភ្នំ ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៥។

-ដឹកនាំក្រុមការងារចុះមកពិនិត្យមើលសកម្មភាពក្រុមការងារសាងសង់ស្ថានីយ៍ប្រេងឥន្ធនៈ និងក្រុមការងារគ្រឿងចក្រកំពុងតែនាំគ្នាសម្រុកស្ថាបនាគ្រឹះផ្លូវ ដើម្បីចាក់ក្រាលកៅស៊ូ DBST ផ្លូវនេះតភ្ជាប់មកពីភូមិព្រៃខ្យាំ មកដល់ភូមិស្វាយដង្គំ ឃុំស្ពុះ ប្រវែងសរុប៥.៦០០ម៉ែត្រ នៅភូមិព្រៃខ្យាំ ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៥។

-ដឹកនាំក្រុមការងារចុះមកពិនិត្យមើលសកម្មភាពស្ថាបនាផ្លូវទាំងពីរខ្សែចាក់ក្រាលកៅស៊ូ DBST ដើម្បីបម្រើតម្រូវការដល់កម្មករ ក៏ដូចជាប្រជាពលរដ្ឋ នៅឃុំសែនដី និងឃុំស្ពុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៥។



-ដឹកនាំក្រុមការងារកសិកម្មចុះមកពិនិត្យមើលសកម្មភាពគ្រឿងចក្រផ្ដួលរំលំកាត់ចិញ្រ្ចាំដើមដូងប្រេង និងត្រៀមគម្រោងដាំសារឡើងវិញចំនួន៦០.០០០ដើម ស្មើ៥០០ហិកតា នៅចំការដូងប្រេង ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ

នាព្រឹកថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៥។



-ជួបសំណេះសំណាល និងសួរសុខទុក្ខជាមួយសិស្ស ដែលមកពីវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ខេត្តកំពង់ឆ្នាំង ចំនួន៥នាក់ ដែលបានមកធ្វើកម្មសិក្សារយៈពេល២ខែ ដើម្បីដកស្រង់បទពិសោធ និងបង្កើនចំណេះដឹងថ្មីៗ លើជំនាញបច្ចេកទេសកសិកម្មនៅក្នុងតំបន់រមណីយដ្ឋានអភិវឌ្ឍន៍ កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ ភូមិសំរោងជើងភ្នំ ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៥។



-ដឹកនាំក្រុមការងារសំណង់និងកសិកម្ម ពិនិត្យមើលក្រុមគ្រឿងចក្រសាងសង់ស្ពាបនាទំនប់ស្ទាក់ទឹកដែលហូរចុះមកពីលើភ្នំម្រះព្រៅ ដើម្បីស្ទាក់ទឹកឱ្យហូរចូលស្រះសម្រាប់ទុកប្រើប្រាស់រដូវប្រាំងវិញ នៅភូមិមហាលំពាំងទី២ ឃុំស្គុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៥។



-ទទួលជួបពិភាក្សាការងារជាមួយក្រុមអ្នកវិនិយោគទុនមកពីប្រទេសវៀតណាមចំនួន៦នាក់ មានជំនាញបច្ចេកទេសខាងផ្នែកវេជ្ជសាស្ត្រ ព្យាបាលជំងឺលើសឈាម និងជំងឺមហារីក ដោយប្រើឱសថបូរាណ និងចាប់សរសៃ នៅភូមិស្វាយដង្គុំ ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៥។



-ដឹកនាំក្រុមការងារចុះមកពិនិត្យមើលសកម្មភាពរោងចក្រផលិតចំណីសត្វ ដែលមានកម្លាំងផលិតចំណីសត្វបាន៥០តោនក្នុងមួយម៉ោង នៅភូមិមនោរម្យ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៥។

-ដឹកនាំក្រុមការងារមកពិនិត្យសកម្មភាពនៃការចិញ្ចឹមត្រី



ជាច្រើនប្រភេទ និងការចិញ្ចឹមកង្កែប នៅតំបន់១០០ហិកតា ភូមិឫទ្ធី១ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ព្រមទាំងបានអញ្ជើញពិនិត្យសកម្មភាពក្រុមការងារកាត់សំអាតស្មៅ និងព្រៃនៅតាមបណ្តោយផ្លូវបណ្ឌិត ម៉ុង ឫទ្ធី ប្រវែង១៦គីឡូម៉ែត្រ តភ្ជាប់ពីកំពង់ផែឧកញ៉ាម៉ុង មកដល់ផ្លូវជាតិលេខ៤ ភូមិតានៃ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៥។

❈នាថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **នាង ផាត** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារ៩ខែ ឆ្នាំ២០២៥ និងលើកទិសដៅបន្តរបស់ក្រុមការងារចុះមូលដ្ឋានខេត្តកំពង់ធំ ក្រោមអធិបតីភាពឯកឧត្តម **វង្សី វិស្សុត** ឧបនាយក-រដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសាលាខេត្តកំពង់ធំ។

❈នាថ្ងៃសុក្រ ទី១០ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ឈិត សុខុន** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីសំណេះសំណាល និងប្រគល់រង្វាន់ជូនសិស្សានុសិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិដែលទទួលបាននិទ្ទេសA ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចពិជ័យសេនា **ទៀ បាញ់** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅសាលមហោស្រព ខេត្តកោះកុង។

❈នាថ្ងៃព្រហស្បតិ៍ ទី៩ ខែតុលា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា សហការជាមួយនឹងក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃសមាគមអភិវឌ្ឍន៍សុខុមាលភាពកម្ពុជា-បារាំងប្រចាំនៅកម្ពុជា ចុះពិនិត្យ និងព្យាបាលជំងឺទូទៅជូនដល់បងប្អូនប្រជាពលរដ្ឋដោយមិនយកកម្រៃ នៅសាលាស្រុកពាមជរ ខេត្តព្រៃវែង។

❈នាថ្ងៃសៅរ៍ ទី១៨ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុំ សារិទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា និងឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមប្រជុំបូកសរុបលទ្ធផលការអនុវត្តការងារប្រចាំខែកញ្ញា និងទិសដៅភារកិច្ចសំខាន់ៗ ប្រចាំខែតុលា ឆ្នាំ២០២៥ របស់ខេត្តស្វាយរៀង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំថ្មី ខេត្តស្វាយរៀង។

❈ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមប្រជុំការងាររដ្ឋបាលខេត្តខេត្តព្រៃវែង ដើម្បីបូកសរុបលទ្ធផលការងារ និងលើកទិសដៅបន្ត ក្រោមអធិបតីភាពឯកឧត្តម **ស្មោន សារ៉ាត** ប្រធានក្រុមប្រឹក្សាខេត្តព្រៃវែង នៅសាលាខេត្តព្រៃវែង នាថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៥។

-ចូលរួមពិធីសម្ពោធសមិទ្ធផលនានា នៅសាលាបឋមសិក្សាទ្រា ក្រោមអធិបតីភាពឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្ថិតក្នុងភូមិទ្រា ឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង នារសៀលថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៥។

-ចូលរួមប្រជុំការងារស្រុក ដើម្បីបូកសរុបលទ្ធផលការងារ និងលើកទិសដៅការងារបន្ត ក្រោមអធិបតីភាពឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅស្រុកពាមជរ ខេត្តព្រៃវែង នាថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៥។

❈នាថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុកថ្មបាំង និងក្រុមប្រឹក្សាឃុំឫស្សីជ្រុំ ស្ថិតក្នុងស្រុកថ្មបាំង ខេត្តកោះកុង។



❈ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមប្រជុំជាមួយក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីស្តាប់របាយការណ៍ស្តីពីលទ្ធផលការងារខែកញ្ញា និងទិសដៅការងារខែតុលា ឆ្នាំ២០២៥ បន្តពង្រឹងការការពារសុខសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋ ព្រមទាំងបានឧបត្ថម្ភថវិកាជួយថែទាំការពារសុខភាពមនុស្សចាស់ប្រចាំខែ នាថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៥។

-ចូលរួមប្រជុំការងារស្តីពី សភាពការណ៍ទូទៅប្រចាំខែ និងទិសដៅការងារបន្តឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅសង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ នាថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៥។

-ចូលរួមជាមួយសាខាកាកបាទក្រហម និងក្រុមការងារ



សមាគមសិស្ស និស្សិត អ.ម.ត ខណ្ឌទួលគោក រាជធានីភ្នំពេញ ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋចាស់ជរា ជនពិការ ប្រជាការពារចំនួន៥០គ្រួសារ និងប្រគល់ប័ណ្ណក្រីក្រ ជូនគ្រួសារងាយរងហានិភ័យចំនួន៧គ្រួសារ ស្របតាមគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល ព្រមទាំងបានឧបត្ថម្ភអង្ករ មី កន្សែងពោះគោ និងថវិកាមួយចំនួន ក្នុងសង្កាត់ទាំង១០ ខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី៨ ដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៥។



-ចូលរួមពិធីដង្ហែអង្គកឋិនទានសាមគ្គីទៅកាន់វត្តច័ន្ទបុរីវង្ស នៅខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ដើម្បីវេរប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សាអស់កាលត្រីមាស ព្រមទាំងបច្ច័យ និងទេយ្យវត្ថុមួយចំនួន សម្រាប់ព្រះសង្ឃកសាងវិស័យពុទ្ធសាសនាក្នុងទីវត្តអារាម នាថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៥។



-ចូលរួមពិធីដង្ហែអង្គកឋិនទានសាមគ្គីទៅកាន់វត្តពុទ្ធមណ្ឌល វិបស្សនាធុរៈ ស្រុកពញាឮ ខេត្តកណ្ដាល ដើម្បីវេរប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សាអស់កាលត្រីមាស ព្រមទាំងបច្ច័យ និងទេយ្យវត្ថុមួយចំនួន សម្រាប់ព្រះសង្ឃកសាងវិស័យពុទ្ធសាសនាក្នុងទីវត្តអារាម ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៥។

❈នាព្រឹកថ្ងៃចន្ទ ទី១៣ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចុះសួរសុខទុក្ខលោកព្រឹទ្ធាចារ្យ **សូ ខាត់** ត្រូវជាឪពុកក្មេកឯកឧត្តម **នរៈ រតនវឌ្ឍនោ** រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ដែលកំពុងសម្រាកព្យាបាលជំងឺ នៅគេហដ្ឋានស្ថិតក្នុងឃុំវល្លិ៍ស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

❈នាថ្ងៃចន្ទ ទី១៣ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញសំណេះសំណាល និងចុះសួរសុខទុក្ខចាស់ជរាចំនួន២គ្រួសារ និងប្រជាការពារភូមិចំនួន១០នាក់ ព្រមទាំងបានឧបត្ថម្ភខោអាវម្នាក់១កំប្លេ នៅភូមិត្រោក ឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។

❈នាថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ស៊ាក ឡេង** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញជាកិត្តិយសក្នុងពិធីអបអរសាទរជូនសិស្សានុសិស្សដែលទើបប្រឡងជាប់មធ្យមសិក្សាទុតិយភូមិឆ្នាំ២០២៥ និងទិវាគ្រូបង្រៀន ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួនដល់អង្គពិធី នៅស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។

❈នាថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៥ ឯកឧត្តម **ឌឹម លាវ** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភា និងលោកជំទាវបណ្ឌិត **អ៊ុក ម៉ាលី** សមាជិកាគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីសំណេះសំណាល និងប្រគល់រង្វាន់ដល់សិស្សប្រលងទុតិយភូមិ និទ្ទេសA ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ម៉ា ឈឿន** អនុប្រធានគណៈកម្មការទី៣រដ្ឋសភា នៅស្រុកជើងព្រៃ ខេត្តកំពង់ចាម។

❈ឯកឧត្តមបណ្ឌិត **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមពិធីបុណ្យគម្រប់ខួប៣ឆ្នាំ ឧបាសិកា **ញឹក សារ៉េត** និងឧបាសក **ព្រុំ គង** ព្រមទាំងញាតិ៧សណ្តាន ដែលបានចែកឋាននាពេលកន្លងទៅ ព្រមទាំងឧទ្ទិសផលបុណ្យជូនដល់វិញ្ញាណក្ខន្ធវីរយុទ្ធជនកងទ័ពកម្ពុជា ដែលបានពលីកម្មការពារទឹកដីពីពួកសៀមឈ្លានពានទឹកដីកម្ពុជា នៅវត្តជ្រៃក្តោង (ហៅវត្តតានូ) ភូមិតានូ ឃុំចំបក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង នាព្រឹកថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៥។

-ជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តការងារប្រចាំខែកញ្ញា និងទិសដៅភារកិច្ចសម្រាប់អនុវត្តខែតុលា ឆ្នាំ២០២៥ នៅស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៥។

❈ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញ៖



-ជាអធិបតីក្នុងពិធីបើកបវេសនកាលឆ្នាំសិក្សាថ្មី ឆ្នាំ២០២៥-២០២៦ និងចែកវិញ្ញាបនបត្រ ប័ណ្ណសរសើរ លិខិតសរសើរ សម្ភារៈសិក្សាដល់សិស្សានុសិស្ស ចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី១០ នៃសាលាសេហ្វហេរ៉ិន ស្ថិតក្នុងភូមិកូនដំរី សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ នាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៥។



-ចូលរួមជាមួយក្រុមប្រឹក្សាខេត្ត អភិបាលស្រុក ចុះពិនិត្យលូទឹក ផ្លូវលេខ២៥៦១ (គីឡូម៉ែតលេខ២) ដែលធ្វើឱ្យទឹកហូរមិនទាន់លិចស្រូវប្រជាពលរដ្ឋ ចំនួនជាង៧០ហិចតា នៅឃុំតាបែន ព្រមទាំងចុះសួរសុខទុក្ខនិងឧបត្ថម្ភថវិកាមួយចំនួនដល់ក្រុមការងារស្រុក ក្រុមប្រឹក្សាឃុំ មេភូមិ ប្រជាការពារនៅភូមិចក់ពួក ឃុំស្លក្រោម ភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៥។



-ជាអធិបតីពិធីចែកវិញ្ញាបនបត្រ ប័ណ្ណសរសើរ និងរង្វាន់ជូនដល់សិស្សឆ្នើមឆ្នាំសិក្សា២០២៣-២០២៤ និង២០២៤-២០២៥ នៃសាលារៀនផឹធឹង នៅខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៥។

❈លោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា លោកជំទាវ **ចឹក ហេង** សមាជិកាគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តម **ញៀម សាម៉ន** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញ៖

-ជាតំណាងឯកឧត្តមបណ្ឌិត **នាង ផាត** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ នាំយកអង្ករចំនួន៣តោន របស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ប្រគល់ជូនរដ្ឋបាលខេត្តរតនគិរី ដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការជួយសម្រួលដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដែលទទួលរងគ្រោះដោយសារទឹកជំនន់ នៅខេត្តរតនគិរី និងខេត្តមណ្ឌលគិរី នាថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៥។

-ចូលរួមពិធីសូត្រមន្ត និងដង្ហែអង្គកឋិនទាន ដើម្បីវេរប្រគេនព្រះភិក្ខុសង្ឃ ដែលគង់ចាំព្រះវស្សាអស់ត្រីមាស នៅក្នុងពុទ្ធសីមាវត្តឥន្ទ្របត្តបុរី (ហៅវត្តអង្គរ តូចខាងត្បូង)ស្ថិតក្នុងភូមិក្រវ៉ាន់ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប នាព្រឹកថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៥។

❈ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញ៖

-ចុះពិនិត្យទីតាំងសម្រាប់ក្រុមគ្រូពេទ្យបារាំង មកពិនិត្យ និងព្យាបាលជំងឺទូទៅ ជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ ស្ថិតនៅមន្ទីរពេទ្យបង្អែកស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៥។

-ជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយសិស្សានុ-

សិស្សជ័យលាភី ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឆ្នាំ២០២៥ សរុបចំនួន២.៣១២នាក់ ក្នុងទូទាំងស្រុកអូររាំងឪ ស្រុកពញាក្រែក និងស្រុកត្បូងឃ្មុំ ក្រោមអធិបតីភាពឯកឧត្តម បណ្ឌិត **អ៊ាង សុផល្លែត** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ស្ថិតនៅខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៥។

❈ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញ៖



-ជួបសំណេះសំណាល និងសួរសុខទុក្ខបងប្អូនប្រជាពលរដ្ឋ ដើម្បីពង្រឹងស្មារតីសាមគ្គីភាពជឿជាក់ គាំទ្ររាជរដ្ឋាភិបាល ព្រមទាំងចូលរួមថែរក្សាសន្តិភាព ស្រឡាញ់សន្តិភាព និងចូលរួមអនុវត្តភូមិសង្កាត់មានសុវត្ថិភាពជាមួយអាជ្ញាធរមូលដ្ឋានឱ្យបានល្អប្រសើរ នៅភូមិស្រែ ភូមិបឹងតាព្រាម សង្កាត់ត្រើយកោះ ក្រុងកំពត ខេត្តកំពត នារសៀលថ្ងៃទី២៦ ខែកញ្ញា និងល្ងាចថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៥។



-ចូលរួមរំលែកមរណទុក្ខ និងគោរពវិញ្ញាណក្ខន្ធសព ប្រជាពលរដ្ឋ នៅភូមិទទឹងថ្ងៃ សង្កាត់បឹងទូក ក្រុងបូកគោ ខេត្តកំពត នារសៀលថ្ងៃ២៩ ខែកញ្ញា ឆ្នាំ២០២៥។



-ចូលរួមរំលែកមរណទុក្ខនិងគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប ព្រមទាំងគោរពវិញ្ញាណក្ខន្ធសពអតីតអនុប្រធានភូមិអន្លង់ម៉ាក់ប្រាង្គ នៅភូមិអន្លង់ម៉ាក់ប្រាង្គ ឃុំស្ទឹងកែវ ស្រុកទឹកឈូ ខេត្តកំពត នាថ្ងៃទី២ និងថ្ងៃទី៧ ខែតុលា ឆ្នាំ ២០២៥។

❈ឯកឧត្តម **គង់ មុនីភា** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញ៖

-ជួបសំណេះសំណាលនិងសួរសុខទុក្ខបងប្អូនប្រជាពលរដ្ឋ នៅភូមិព្រៃរំ ឃុំពានរោង ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង នាព្រឹកថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលនិងសួរសុខទុក្ខបងប្អូនប្រជាពលរដ្ឋ នៅឃុំល្វា ស្រុកព្រះស្ដេច ខេត្តព្រៃវែង នាព្រឹកថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលនិងសួរសុខទុក្ខក្រុមប្រឹក្សាឃុំ ព្រមទាំងបងប្អូនប្រជាពលរដ្ឋ នៅឃុំសំបួរ ស្រុកពាមជ ខេត្តព្រៃវែង នារសៀលថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលនិងសួរសុខទុក្ខបងប្អូនប្រជាពលរដ្ឋ ដែលមកពីឃុំគោកគង់ខាងកើត ឃុំគោកគង់ខាងលិច និងឃុំភ្លើងរាយ ស្រុកកញ្ជៀច ខេត្តព្រៃវែង នាថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលនិងសួរសុខទុក្ខបងប្អូនប្រជាពលរដ្ឋ នៅឃុំស្មោងខាងត្បូង ស្រុកកំចាយមារ ខេត្តព្រៃវែង នាថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលជាមួយបងប្អូនប្រជាពលរដ្ឋដែលចង់ស្វែងយល់អំពីសិទ្ធិមនុស្ស ស្ថិតនៅឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាព្រឹកថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលជាមួយបងប្អូនប្រជាពលរដ្ឋដែលចង់ស្វែងយល់អំពីសិទ្ធិមនុស្ស ស្ថិតនៅសង្កាត់ប៉ាលហាល ក្រុងព្រះវិហារ ខេត្តព្រះវិហារ នារសៀលថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៥។

❈នាព្រឹកថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៥ លោកជំទាវបណ្ឌិត **អ៊ុក ម៉ាលី** សមាជិកាគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញអមដំណើរសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ក្នុងពិធីប្រគល់ព្រះរាជអំណោយរបស់សម្ដេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ដល់ប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ ចំនួន ១.៨០០គ្រួសារ មកភូមិចំនួន១៤ ក្នុងឃុំ៣ នៃស្រុកត្បូងឃ្មុំ



នៅទីទួលសុវត្ថិភាពឧកញ៉ា **ច័ន ប៊ុនថៃ** ភូមិទន្លេបិទលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

❉ឯកឧត្តម **ញ៉ូវ សុខ** សមាជិកគណៈកម្មការទី២ ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមប្រគល់សម្ភារៈការពារសុវត្ថិភាពដល់រដ្ឋបាលខេត្តពោធិ៍សាត់ រួមមាន អាវក្រោះ និងមួកចំនួន១១៩ឈុត មួកសុវត្ថិភាព ម៉ាសការពារផ្សែងពុល និងឧបករណ៍ការពារត្រចៀកចំនួន៦០០ឈុត ដើម្បីប្រគល់ជូនកងទ័ព និងប្រជាជនតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ដែលកំពុងជួបការលំបាកព្រមទាំងបានឧបត្ថម្ភឧបករណ៍សុវត្ថិភាព១០០ឈុត នៅខេត្តពោធិ៍សាត់ នាថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៥។

-ដង្ហែអង្គកឋិនទានប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សាអស់ត្រីមាសនៅវត្តព្រៃខ្លុង ស្ថិតក្នុងឃុំរកាត ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ នាព្រឹកថ្ងៃទី១៨ ខែតុលា ២០២៥។

-ចូលរួមកម្មវិធីបុណ្យកឋិនទានសាមគ្គី ដែលនឹងដង្ហែ និងវេរប្រគេនព្រះសង្ឃគង់ចាំព្រះវស្សាអស់ត្រីមាសនៅក្នុងវត្តពោធិ៍សុវណ្ណរង្សី (ហៅវត្តពោធិ៍) ស្ថិតក្នុងឃុំអន្លង់វិល និងវត្ត នទីសេដ្ឋា (ហៅវត្តបន្ទាយយួន) ក្នុងឃុំស្យា នៃស្រុកកណ្តៀង ខេត្តពោធិ៍សាត់ នារសៀលថ្ងៃទី១៨ ខែតុលា ឆ្នាំ ២០២៥។

❉លោកជំទាវ **មុំ សណ្ដាប់** សមាជិកាគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមក្នុងកិច្ចប្រជុំបូកសរុបរបាយការណ៍របស់ខណ្ឌចំការមន ប្រចាំខែកញ្ញា និងទិសដៅការងារបន្តខែតុលា ឆ្នាំ២០២៥ ជាមួយសមាជិក សមាជិកា ក្រុមប្រឹក្សាសង្កាត់មកពីសង្កាត់ទាំង៥ ស្ថិតក្នុងខណ្ឌចំការមន រាជធានីភ្នំពេញ នាថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៥។



-ជួបសំណេះសំណាលជាមួយចលនាសហជីពមកពីភូមិ១ សរុបចំនួន៩គ្រួសារ ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួន ក្នុងសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ នាថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៥។

❉ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមពិធីសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងចែកអំណោយជូនប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយទឹកជំនន់ ចំនួន២៦៥គ្រួសារ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** ទេសរដ្ឋមន្ត្រី ស្ថិតក្នុងបរិវេណវត្តថ្មល់ឈើទាល ឃុំផ្លូវទូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៥។

-ចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែតុលានិងទិសដៅការងារបន្ត ឆ្នាំ២០២៥ នៅសាលាស្រុកជល់គីរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៥។



-ចូលរួមពិធីដង្ហែអង្គកឋិនទានសាមគ្គីទៅកាន់វត្តបល្ល័ង្គ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដើម្បីវេរប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សាអស់កាលត្រីមាស ព្រមទាំងបច្ច័យ និងទេយ្យវត្ថុមួយចំនួន សម្រាប់ព្រះសង្ឃកសាងវិស័យពុទ្ធសាសនាក្នុងទីវត្តអារាម នាថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៥។



-ចូលរួមជាមួយក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការជុំវិញខេត្ត ក្រុមយុវជនកាយរិទ្ធ និងយុវជនកាកបាទក្រហមខេត្ត ក្នុងពិធីគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណា «**ព្រះបរមរតនកោដ្ឋ**» គម្រប់ខួប១៣ឆ្នាំ នៅសាលប្រជុំសាលាខេត្តកំពង់ឆ្នាំង នាថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៥។



❈នាថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុន ខណ្ណា** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងពិធីជួបសំណេះសំណាលនិងប្រគល់លិខិតសរសើរ សៀវភៅសរសេរ៣៤០ក្បាល ប៊ិច៣៤០ដើម ព្រមទាំងថវិកាមួយចំនួនចែកជូនសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និទ្ទេសA ចំនួន៣៦នាក់ និងលោកនាយកវិទ្យាល័យទាំង៨ ក្នុងស្រុកព្រៃកប្បាស នៅសាលាស្រុកព្រៃកប្បាស ខេត្តតាកែវ។

❈ឯកឧត្តម **សេង ម៉ារឌី** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញ៖

-ជួបសំណេះសំណាលនិងសួរសុខទុក្ខជាមួយសមាជិកក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក និងប្រជាពលរដ្ឋប្រមាណ៣០០នាក់ នៅភូមិរូង ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី២៨ ខែកញ្ញា និងថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៥។

-ជួបសំណេះសំណាល និងសួរសុខទុក្ខជាមួយសមាជិកក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក និងប្រជាពលរដ្ឋប្រមាណ១៣០នាក់ នៅភូមិអូរខ្លែងព័រ សង្កាត់ប៉ាលហាល ក្រុងព្រះវិហារ ខេត្តព្រះវិហារ នារសៀលថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៥។

-ជួបសំណេះសំណាល និងសួរសុខទុក្ខជាមួយសមាជិកក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក និងប្រជាពលរដ្ឋប្រមាណ១៥០នាក់ នៅភូមិគាប សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ នាព្រឹកថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៥។

-នាំយកជំនួយជាអង្ករ និងគ្រឿងបរិភោគមួយចំនួនសម្រាប់ជួយដល់ប្រជាពលរដ្ឋរងគ្រោះដោយអំពើឈ្លានពានពីសំណាក់កងទ័ពថៃ នៅវត្តព្រៃចាន់ ភូមិព្រៃចាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ នារសៀលថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៥។

❈លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញ៖

-នាំយកថវិកាមួយចំនួនចូលបច្ច័យបុណ្យកឋិនទានមហាសាមគ្គី ដែលរៀបចំដោយលោកជំទាវ **ថាក់ ឡានី** សមាជិកាក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ នៅវត្តអារញ្ញរាម ខេត្តរតនគិរី នាព្រឹកថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៥។

-ចុះសួរសុខទុក្ខឧបាសិកា **អ៊ុំ សំឡី** ប្រជាពលរដ្ឋដែលកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន និងបានឧបត្ថម្ភថវិកាមួយចំនួន នៅភូមិទ្រាំង ក្រុងសៀមរាប នាព្រឹកថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៥។

-ចូលរួមពិធីបុណ្យកឋិនទានសាមគ្គីនៅវត្តព្រះឥន្ទកោសា និងវត្តព្រះឥន្ទ្រកោសីយ៍ ព្រមទាំងបានចូលបច្ច័យបុណ្យមួយចំនួន ស្ថិតនៅក្រុងសៀមរាប ខេត្តសៀមរាប នារសៀលថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៥។

-ចូលរួមពិធីបុណ្យកឋិនទានសាមគ្គីនៅវត្តព្រះព្រហ្មរ័ត្ននិងវត្តស្វាយរមៀត ព្រមទាំងបានចូលបច្ច័យបុណ្យមួយចំនួនស្ថិតនៅក្រុងសៀមរាប ខេត្តសៀមរាប នាព្រឹកថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៥៕

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៥ សមាជិក សមាជិកា ព្រឹទ្ធសភា ចំនួន២៥រូប បានអញ្ជើញចូលរួមស្ដាប់បាឋកថា ស្ដីពី ភាពធន់នៃសេដ្ឋកិច្ចកម្ពុជា៖ ការពង្រឹងសមត្ថភាពឧស្សាហកម្មក្នុងស្រុក ដោយឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ស៊ីផាន់ណា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានគណៈកម្មការពិសេសជំរុញការដោះស្រាយបញ្ហាវិស័យឯកជន នៅវិមានរដ្ឋសភា។



❈នាព្រឹកថ្ងៃចន្ទ ទី៦ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ឱ ច័ន្ទ្រផល** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណ្ខន្ធសពឯកឧត្តម **ឆាន់ សាផាន** ទីប្រឹក្សារាជរដ្ឋាភិបាល និងជាអតីតរដ្ឋលេខាធិការ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅបុរីហ្វ្រេនភ្នំពេញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

❈នាថ្ងៃចន្ទ ទី២៩ ខែកញ្ញា ឆ្នាំ២០២៥ ឯកឧត្តម **យស ផានីត្តា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសពឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **មាឃ ផល** ម្ដាយក្មេកឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា។

❈ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមកម្មវិធីពិព័រណ៍ផលិតផលខ្មែរ ក្រោមប្រធានបទ «ខ្មែរធ្វើបាន ចូលរួម ជំរុញ គាំទ្រ ផលិតផលក្នុងស្រុក» នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ នារសៀលថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៥។

-ចូលរួមពិធីប្រកាសសមាសភាពក្រុមការងារចុះមូលដ្ឋាន



ក្រុងកំពង់សោម ក្រោមអធិបតីភាពឯកឧត្តម **សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅផ្សារកោះគ្រោះក្នុង សង្កាត់បឹងតាព្រហ្ម ក្រុងកំពង់សោម ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៥។

-ចូលរួមពិធីប្រកាសសមាសភាពក្រុមការងារចុះមូលដ្ឋានក្រុងកោះរ៉ុង និងវេទិកាសាធារណៈ ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមអធិបតីភាពឯកឧត្តម **សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅក្រុងកោះរ៉ុង ខេត្តព្រះសីហនុ នារសៀលថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៥។



-ចូលរួមពិធីសំណេះសំណាលជាមួយសិស្សជ័យលាភីនិទ្ទេសA ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅខេត្តព្រះសីហនុ សម័យប្រឡង ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៥ ក្រោមអធិបតីភាពឯកឧត្តម **សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ

ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៥។



❈នាល្ងាចថ្ងៃទី១ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ម៉ុង ឬទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីអបអរទិវាជាតិនិងខួបលើកទី៧៧ នៃទិវាកងពល នៃសាធារណរដ្ឋកូរ៉េ នៅសណ្ឋាគារ Sofitel Phnom Penh។




❈នាព្រឹកថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ម៉ុង ឬទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា ឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា និងលោកជំទាវ **សួស សារ៉ាម** សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អាកាសយានដ្ឋានអន្តរជាតិតេជោក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត **ពេជ ចន្ទមុនី ហ៊ុនម៉ាណែត** ស្ថិតនៅភូមិតាព្រហ្ម ឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។



❈នារសៀលថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **នាង ផាត** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តមបណ្ឌិត **ចែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីជប់លៀងដោយទទួលស្វាគមន៍នៅលើនាវាកងទ័ពជើងទឹករបស់អូស្ត្រាលី HMAS Ballarat តបតាមការអញ្ជើញរបស់លោក Tony Peck ប្រធានក្រុមអនុព័ន្ធការពារជាតិអូស្ត្រាលីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងលោក Dean Uren មេបញ្ជាការកប៉ាល់ HMAS Ballarat នៅខេត្តព្រះសីហនុ។

❈នាថ្ងៃពុធ ទី៣ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ចែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា ព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ធម្មិកោ** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្តម **សេង ម៉ារឌី** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញ/យាងចូលរួមកម្មវិធីបុណ្យជាតិលើកទី៣៥ នៃប្រទេសសាធារណរដ្ឋអាល្លឺម៉ង់ នៅសណ្ឋាគារ Rosewood រាជធានីភ្នំពេញ។

❈ឯកឧត្តមបណ្ឌិត **ចែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមក្នុងពិធីសម្ពោធពិព័រណ៍មិនអចិន្ត្រៃយ៍ ក្រោមប្រធានបទ «ការលេចត្រដែតឡើងវិញ៖ ការបាត់បង់ និងការរកឃើញឡើងវិញនូវគំនូរក្នុងវិហារ ព្រះកែវមរកតនៃព្រះបរមរាជវាំង» នៅសារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុព្រះស្រីព្រៀសានវ៉្រេន នាព្រឹកថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៥។

-ចូលរួមគោរពវិញ្ញាណក្ខន្ធនិងដង្ហែរសពឯកឧត្តម **ឆាន់ សាផាន** ទីប្រឹក្សារាជរដ្ឋាភិបាល ទៅបូជានៅវត្តចន្ទបុរីវង្ស នាព្រឹកថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៥។

-ទស្សនាបណ្ណាល័យតម្កល់ស្លឹករឹត នៅវត្តឧណ្ណាលោម នារសៀលថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៥។

-ចូលរួមគោរពវិញ្ញាណក្ខន្ធលោកជំទាវឧកញ៉ា **ឈិន អ៉ែម**



ភរិយាឯកឧត្តម **ឈៀង យ៉ាណារ៉ា** ទេសរដ្ឋមន្ត្រីទទួលបេសកកម្មពិសេស និងជាអនុប្រធានទី២ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នៅវត្តលង្កាព្រះកុសុមារាម ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៥។

❈នាថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ចែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា ឯកឧត្តម **សាយ ម៉ូរិន** សមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា និងឯកឧត្តម **ខៀត ចន្ថាវី** សមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាបច្ច័យក្នុងពិធីបុណ្យកឋិនទានមហាសាមគ្គីរបស់លោកជំទាវ **ថាត់ ឡានី** សមាជិកាព្រឹទ្ធសភា នៅវត្តអរញ្ញរាម។

❈លោកជំទាវបណ្ឌិត **ខាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញ៖



-ដឹកនាំគណៈប្រតិភូគណៈកម្មការទី៦ព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធសពឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ **មាឃ ផល** ម្ដាយក្មេករបស់ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា។

-ចូលរួមកិច្ចប្រជុំសមាជិកក្រុមសិក្សាស្រាវជ្រាវលើប្រធានបទទី៣ ផ្នែកទី១ «ការកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា» ដឹកនាំសម្របសម្រួលដោយឯកឧត្តមបណ្ឌិត **ស៊ា ម៉ៅ** រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី អនុប្រធាន និងជាអគ្គលេខាធិការក្រុមប្រឹក្សាអ្នកច្បាប់ ដើម្បីពិនិត្យនិងពិភាក្សាលើការត្រៀមរៀបចំសិក្ខាសាលាស្ដីពី ប្រព័ន្ធច្បាប់កម្ពុជា នៅទីស្ដីការគណៈរដ្ឋមន្ត្រី នាព្រឹកថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៥។



❈នាព្រឹកថ្ងៃពុធ ទី១ ខែតុលា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធសពឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ **មាឃ ផល** ម្ដាយក្មេករបស់ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា។

❈នាព្រឹកថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៥ លោកជំទាវ



**មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា លោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា និងឯកឧត្តម **ហេង ហាលីម** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញទទួលព្រះរាជអំណោយដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្ដេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ

តាមរយៈសម្តេចរាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី** សមាជិកាព្រឹទ្ធសភា ដើម្បីចែកជូនរីកងទ័ពការពារព្រំដែន និងប្រជានុរាស្ត្រភៀសសឹក នៅតំបន់រងគ្រោះដោយសារការឈ្លានពានរបស់ក្រុមទាហានសៀម នៅសាលប្រជុំគណៈកម្មការទី៨ព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា និងលោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីសំណេះសំណាលជាមួយសមាគមនារីកម្ពុជា ដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ នៅទូទាំងប្រទេសក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា តាមរយៈប្រព័ន្ធវីដេអូ។

❈នារសៀលថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបុណ្យគម្រប់ខួប៧ថ្ងៃ ឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **មាឃ ផល** ម្តាយក្មេកឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា។

❈នាថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភា ឯកឧត្តម **គិន ណៃាត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភា លោកជំទាវបណ្ឌិត **អ៊ុក ម៉ាលី** សមាជិកាគណៈកម្មការទី២ព្រឹទ្ធសភា និងឯកឧត្តម **ញៀវ សុខ** សមាជិកគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពី «ភាពធន់នៃសេដ្ឋកិច្ចកម្ពុជា៖ ការពង្រឹងសមត្ថភាពឧស្សាហកម្មក្នុងស្រុក» ក្រោមអធិបតីភាពលោកជំទាវ **និន សាផុន** ប្រធានគណៈកម្មការទី៩រដ្ឋសភា នៅវិមានរដ្ឋសភា។

❈នាថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ឈួន ឆាម** អនុប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីប្រកាសផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្រោមអធិបតីភាពឯកឧត្តម **ចន្ទ វិសុទ្ធ** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈ-រដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគាររ៉េស៊ីដង់ សុខាភ្នំពេញ។

❈នារសៀលថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា និងលោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបុណ្យគម្រប់ខួប៧ថ្ងៃ ឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **មាឃ ផល** ម្តាយក្មេករបស់ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៥ លោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងកម្មវិធីចេញផ្សាយរបាយការណ៍ ស្តីពីការតាមដានលើការអនុវត្តអនុសញ្ញា ស៊ី-ដ សម្រាប់ឆ្នាំ២០២៣ និង២០២៤ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។

❈លោកជំទាវបណ្ឌិត **អ៊ុក ម៉ាលី** សមាជិកាគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមពិធីបុណ្យកឋិនទានមហាសាមគ្គីវត្តមុនីសុវណ្ណ (វត្តចំពុះក្អែក) ស្ថិតក្នុងសង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នាល្ងាចថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៥។

-ជាតំណាងដ៏ខ្ពង់ខ្ពស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ចូលរួមបុណ្យកឋិនទានសាមគ្គី ដើម្បីវេរប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សាអស់ត្រីមាសក្នុងព័ទ្ធសីមា វត្តមុនីសុវណ្ណ (វត្តចំពុះក្អែក) ព្រមទាំងបានវេរប្រគេនត្រៃចីវរចំនួន២៧ និងបច្ច័យមួយចំនួន ស្ថិតក្នុងសង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៥។



❈នារសៀលថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ង៉ែត ចន្ថាវី** សមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធលោកជំទាវ **ឈិន រ៉ែម** ភរិយា ឯកឧត្តម **ឈៀង យ៉ាណារ៉ា** ទេសរដ្ឋមន្ត្រីទទួលបេសកកម្មពិសេស និងជាអនុប្រធានទី២ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នៅវត្តលង្កាព្រះកុសុមារាម ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

❈នាថ្ងៃអាទិត្យ ទី៧ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចុះសួរសុខទុក្ខលោក **សូ ខាត់** អតីតមន្ត្រីសុខាភិបាល មាន



ជន្មាយុ៩២ឆ្នាំ ដែលត្រូវជាឪពុកលោកជំទាវ **សូ សុគន្ធារី** និងជាឪពុកក្មេករបស់ឯកឧត្តម **នរៈ រតនវឌ្ឍនោ** រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា កំពុងសម្រាកព្យាបាលជំងឺ នៅមន្ទីរពេទ្យកាល់ម៉ែតរាជធានីភ្នំពេញ។



❈នាថ្ងៃសៅរ៍ ទី១៣ ខែតុលា ឆ្នាំ២០២៥ លោកជំទាវ **ម៉ុំ សណ្ដាប់** សមាជិកាគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយមនុស្សវ័យចាស់ ដើម្បីចូលរួមអបអរសាទរទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ លើកទី២៧ ក្រោមប្រធានបទ «វ័យចាស់ដោយសេចក្តីថ្លៃថ្នូរ» ក្រោមអធិបតីភាពឯកឧត្តម **ឃួង ស្រេង** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ នៅសាលារាជធានីភ្នំពេញ។

❈នាព្រឹកថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៥ សម្តេចរាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានយាងប្រារព្ធព្រះរាជពិធីខួបគម្រប់១៣ឆ្នាំ នៃការយាងចូលទិវង្គត ព្រះករុណា សម្តេចព្រះបាទ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យបូរណភាពទឹកដី និងឯកភាពជាតិខ្មែរ «**ព្រះបរមរតនកោដ្ឋ**» ស្ថិតក្នុងព្រះបរមរាជវាំង៕

# ការប្រមាថមកលើសម្តេចតេជោ និងឥស្សរជនកម្ពុជា គឺជាការប្រមាថយ៉ាងធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ តម្លៃ សីលធម៌ និងការគោរពគ្នាទៅវិញទៅមករវាងប្រជាជាតិនិងប្រជាជាតិ



*ឯកឧត្តម ឡោក ឆាយ   ឯកឧត្តម ឡាយ សំកុល   ឯកឧត្តម ខេង សិទ្ធិគុណ   ឯកឧត្តម អោក ប៉ូវ៉ា*

មានប្រសាសន៍ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកញ្ញានិងកំណត់ទិសដៅការងារខែតុលា ឆ្នាំ២០២៥ នាព្រឹកថ្ងៃព្រហស្បតិ៍ ទី៩ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានគូសបញ្ជាក់អំពី ការប្រកាសថ្កោលទោសរបស់ព្រឹទ្ធសភា ចំពោះការប្រមាថមកលើសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានិងឥស្សរជនកម្ពុជាផ្សេងទៀត ដែលជាការប្រមាថយ៉ាងធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ តម្លៃ សីលធម៌ និងការគោរពគ្នាទៅវិញទៅមករវាងប្រជាជាតិ និងប្រជាជាតិ។ ទង្វើបែបនេះ បានធ្វើឱ្យប៉ះពាល់ទៅដល់ស្មារតីនៃភាពជាអ្នកជិតខាងល្អ មិត្តភាព នៃទំនាក់ទំនងរវាងកម្ពុជា និងថៃ ក្នុងនាមជាសមាជិកអាស៊ាន និងសហគមន៍អន្តរជាតិ។

បន្ថែមពីលើលទ្ធផលនិងទិសដៅការងារ ដែលបានចាក់បញ្ចាំងក្នុងវីដេអូបូកសរុបលទ្ធផលការងារប្រចាំខែកញ្ញា និងទិសដៅការងារខែតុលា ឆ្នាំ២០២៥ **ឯកឧត្តមអគ្គលេខាធិការ** បានណែនាំដល់អង្គភាពពាក់ព័ន្ធ តាមដានសេចក្តីព្រាងច្បាប់មួយចំនួន ដែលរដ្ឋសភានឹងបញ្ជូនមកនិងត្រៀមរៀបចំរបាយការណ៍ចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ ព្រឹទ្ធសភានីតិកាលទី៥ ដើម្បីស្នើសុំមតិណែនាំដ៏ខ្ពង់ខ្ពស់ពី **សម្តេចតេជោប្រធានព្រឹទ្ធសភា** រៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍និងសម័យប្រជុំព្រឹទ្ធសភា។ ជាមួយគ្នានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បាននិងកំពុងត្រៀមរៀបចំដំណើរទស្សនកិច្ចរបស់គណៈប្រតិភូព្រឹទ្ធសភា ទៅកាន់សាធារណរដ្ឋប្រជាមានិតចិន និងប្រទេសស្វីស ព្រមទាំងត្រៀមដំណើរទស្សនកិច្ចរបស់**សម្តេចតេជោ** ទៅក្រៅប្រទេសនៅចុងឆ្នាំ២០២៥។

ចំពោះមុខងារអភិវឌ្ឍន៍ស្ថាប័ន **ឯកឧត្តមអគ្គលេខាធិការ**បានជម្រាបអំពីការត្រៀមបើកការដ្ឋានសាងសង់ប្រព័ន្ធរំដោះទឹកភ្លៀងក្នុងបរិវេណព្រឹទ្ធសភា ដែលជាជំនួយគាំទ្រពីសាលារាជធានីភ្នំពេញ នឹងចាប់ផ្តើមពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៥ ដល់ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៦។ ទន្ទឹមនឹងនេះ ឯកឧត្តមក៏បានជម្រាបអំពីការប្រសិទ្ធនាមឈ្មោះ អគារថ្មីនៃព្រឹទ្ធសភា និងបន្ទប់ក្នុងអគារថ្មី ដែលទទួលបានការសម្រេចដ៏ខ្ពង់ខ្ពស់ពី **សម្តេចតេជោប្រធានព្រឹទ្ធសភា**។ ព្រមជាមួយគ្នានោះ ក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិស្ថាបត្យកម្មអគារដែលជាកេរមរតកក្នុងព្រឹទ្ធសភា បាននិងកំពុងខិតខំចងក្រងរៀបចំបោះពុម្ពជាសៀវភៅ ដែលជាមរតករបស់ព្រះករុណា «**ព្រះបរមរតនកោដ្ឋ**» បន្តមកសម្តេចអគ្គមហាធម្មពោធិសាល

**ជា ស៊ីម** សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** និងរហូតមកដល់ស្ថាបត្យកម្មថ្មីរបស់ព្រឹទ្ធសភានីតិកាលទី៥ ដែលជាស្នាដៃរបស់ **សម្តេចតេជោប្រធានព្រឹទ្ធសភា** សម្រាប់ទុកជាឯកសារប្រវត្តិសាស្ត្រនិងសម្រាប់ចែកជូនភ្ញៀវជាតិនិងអន្តរជាតិជាវត្ថុអនុស្សាវរីយ៍ នាឱកាសពិធីសម្ពោធជាផ្លូវការអគារថ្មីនាពេលខាងមុខ។ បន្ថែមពីនេះ អគ្គលេខាធិការដ្ឋានក៏នឹងរៀបចំសិក្ខាសាលាស្តីពី AI and Digital Governance នៅចុងឆ្នាំនេះផងដែរ។



*ឯកឧត្តម ឡាយ សំកុល អញ្ជើញមានប្រសាសន៍ក្នុងកិច្ចប្រជុំបូកសរុប*

ក្នុងឱកាសនោះផងដែរ **ឯកឧត្តមអគ្គលេខាធិការ** ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលបានអញ្ជើញគោរពវិញ្ញាណក្ខន្ធនិងចូលរួមរំលែកទុក្ខ ចំពោះមរណភាពម្តាយក្មេករបស់**ឯកឧត្តមអគ្គលេខាធិការ** កាលពីសប្តាហ៍មុន។

ជាទីបញ្ចប់ **ឯកឧត្តមអគ្គលេខាធិការ** បានណែនាំដល់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការទាំងអស់ បន្តខិតខំយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់សេវាឱ្យបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយជូនស្ថាប័ន ព្រមទាំងជូនពរសូមឱ្យធ្វើដំណើរប្រកបដោយសុខសុវត្ថិភាព ក្នុងឱកាសព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក នាខែវិច្ឆិកាពេលខាងមុខ៕

ខ្លឹមសារ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន









*ទិដ្ឋភាពក្នុងពិធីប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកញ្ញា និងកំណត់ទិសដៅការងារខែតុលា ឆ្នាំ២០២៥*

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

❈នាព្រឹកថ្ងៃអាទិត្យ ទី៥ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភានិងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ បានរៀបចំប្រារព្ធពិធីបុណ្យគម្រប់ខួប៧ថ្ងៃ ដើម្បីឧទ្ទិសមហាកុសលជូនដល់ដួងវិញ្ញាណក្ខន្ធ ឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ **មាឃ ផល** ត្រូវជាម្តាយក្មេករបស់ឯកឧត្តម។



❈នាព្រឹកថ្ងៃព្រហស្បតិ៍ ទី៩ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភានិងជាអនុប្រធានគណៈកម្មការសាងសង់អគារថ្មីព្រឹទ្ធសភា ព្រមទាំងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រុមការងារបច្ចេកទេសសាងសង់អគារ បានអញ្ជើញចុះពិនិត្យមើលវឌ្ឍនភាពនៃដំណើរការសាងសង់អគារថ្មី នៃព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃអង្គារ ទី១៤ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានទទួលជួបឯកឧត្តម Kyaw Soe Min ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការ វិមានព្រឹទ្ធសភា។



❈ពីថ្ងៃទី២០ ដល់ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំសមាគមអគ្គលេខាធិការសភា (ASGP) ក្នុងក្របខ័ណ្ឌ នៃសហភាពអន្តរសភា (IPU) នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។




❈នារសៀលថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៥ ឯកឧត្តម **ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញគោរពវិញ្ញាណក្ខន្ធសពឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ **មាឃ ផល** ម្តាយក្មេក ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

❈នារសៀលថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ខេង សិទ្ធិគុណ** អគ្គលេខាធិការស្តីទីព្រឹទ្ធសភា រួមជាមួយថ្នាក់ដឹកនាំ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងអាជ្ញាធរសង្កាត់ព្រែកតាសេក បានអញ្ជើញនាំយកបច្ច័យចូលរួមក្នុងពិធីបុណ្យកឋិនទានសាមគ្គី នៅវត្តមង្គលសត្ថាវ៉ៃ (ហៅវត្តព្រែកតាគង់) ស្ថិតក្នុងសង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ខេង សិទ្ធិគុណ** អគ្គលេខាធិការស្តីទីព្រឹទ្ធសភានិង ឯកឧត្តម **អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអមដំណើរឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាប្រធានគណៈកម្មការសាងសង់អគារថ្មីនៃព្រឹទ្ធសភា អញ្ជើញចុះត្រួតពិនិត្យមើលវឌ្ឍនភាពនៃដំណើរការសាងសង់អគារថ្មី នៃព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃពុធ ទី១ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកញ្ញា និងកំណត់ទិសដៅការងារខែតុលា ឆ្នាំ២០២៥ របស់អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី និងអគ្គនាយកដ្ឋានស្រាវជ្រាវ នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❈នាថ្ងៃទី២០ និងថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម **ឡាយ សំគុល** អគ្គលេខាធិការព្រឹទ្ធសភា បានដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មមនុស្សធម៌នៃប្រទេសបារាំងប្រចាំនៅកម្ពុជា ចុះទៅពិនិត្យ និងព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋឥតយកកម្រៃ នៅវត្តវារិន្ទព្រែកលៀប និងវត្តបុទុមគង្គារ ហៅវត្តបាក់ខែង ស្ថិតក្នុងសង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា




❈នារសៀលថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៥ ឯកឧត្តម **ឈឹម យីស៊ាង** នាយកខុទ្ទកាល័យសម្តេចតេជោ ប្រធានព្រឹទ្ធសភា បានដឹកនាំប្រតិភូខុទ្ទកាល័យសម្តេចតេជោ ប្រធានព្រឹទ្ធសភា អញ្ជើញគោរពវិញ្ញាណក្ខន្ធសពឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ **មាឃ ផល** ម្តាយក្មេក ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃសៅរ៍ ទី៤ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ឈឹម យីស៊ាង** នាយកខុទ្ទកាល័យសម្តេចតេជោ ប្រធានព្រឹទ្ធសភា បានដឹកនាំប្រតិភូខុទ្ទកាល័យសម្តេចតេជោ ប្រធានព្រឹទ្ធសភា អញ្ជើញចូលរួមសម្ពោធពិព័រណ៍មិនអចិន្ត្រៃយ៍ «ការលេចត្រដែតឡើងវិញ៖ ការបាត់បង់ និងការរកឃើញឡើងវិញនូវគំនូរក្នុងវិហារព្រះកែវមរកត នៃព្រះបរមរាជវាំង» នៅសារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ ព្រះស្រីឦសានវរ្ម័ន។




❈នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **រៀង ពិសី** នាយករងខុទ្ទកាល័យសម្តេចតេជោ ប្រធានព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពលោកជំទាវឧកញ៉ាធម្មសីលានុរក្ខិតានី អគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ **ឈិន រ៉ែម** ទីប្រឹក្សាអមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ភរិយារបស់ឯកឧត្តម **ឈៀង យ៉ាណារ៉ា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស អនុប្រធានទី២ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នៅវត្តលង្កាព្រះកុសុមារាម (វត្តលង្កា) រាជធានីភ្នំពេញ។




❈នាព្រឹកថ្ងៃអង្គារ ទី៣០ ខែកញ្ញា ឆ្នាំ២០២៥ ឯកឧត្តម **ទេព ចរិយា** ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក) នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូ ស.ស.យ.ក នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញគោរពវិញ្ញាណក្ខន្ធសព ឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ **មាឃ ផល** ម្តាយក្មេក ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា៕

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ
ទូរសព្ទ៖ (855) 23 211 441, 211 442, 211 443 ទូរសារ៖ (855) 23 211 446
E-mail: secretariat@senate.gov.kh
www.senate.gov.kh www.elibrary.senate.gov.kh
senate of cambodia